ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការយុទ្ធសាស្ត្រថវិកា
# ២០២៣ - ២០២៥

ខែមិថុនា ឆ្នាំ ២០២២

## I. សេចក្តីផ្តើម

ស្របពេលដែលស្ថានភាពជំងឺកូវីដ-១៩ មានការថមថយ និងអាចគ្រប់គ្រងបាន ក្រសួងអប់រំ យុវជន និងកីឡា នៅតែបន្តឈរលើមូលដ្ឋានគ្រឹះរឹងមាំដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍវិស័យអប់រំរបស់ខ្លួនក្នុងការផ្តល់សេវាអប់រំមូលដ្ឋានប្រកបដោយសមធម៌ បរិយាបន្ន និងមានគុណភាពខ្ពស់ក្នុងការឈានទៅសម្រេចវត្ថុបំណងគោលនយោបាយអប់រំ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំយ៉ាងសស្រាក់សស្រាំ ដោយប្រកាន់ខ្ជាប់នូវក្របខណ្ឌសសរស្តម្ភទាំង៥ ដែលជាគោលការណ៍មូលដ្ឋានគ្រឹះ ក្នុងនោះរួមមាន៖ ១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២) ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា ៣) ការដាក់ឱ្យអនុវត្តអធិការកិច្ច ៤) ការពង្រឹងវង្វាយតម្លៃសិក្សា និង៥) ការកែទម្រង់ឧត្តមសិក្សា។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ដាក់ចេញនូវអាទិភាពគន្លឹះចំនួន៨ ក្នុងអង្គសន្និបាតសម្រាប់ឆ្នាំសិក្សា២០២១-២០២២ កន្លងទៅនេះ ដោយផ្តោតលើ៖ (១) ការកសាងប្រព័ន្ធអប់រំ និងការអភិវឌ្ឍសមត្ថភាព (២) ការធ្វើកំណែទម្រង់សាលារៀន (៣) ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១ (៤) ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (៥) ការអប់រំឌីជីថល (៦) កំណែទម្រង់សាលាគរុកោសល្យ (៧) ការលើកកម្ពស់សុខភាពសិក្សា និង (៨) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា។

សកម្មភាពអាទិភាពគន្លឹះទាំង៨ សម្រាប់ឆ្នាំសិក្សា២០២១-២០២២ ខាងលើនេះ នឹងបន្តផ្តោតលើការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យកាន់តែរីកចម្រើនជាលំដាប់ ដែលក្នុងនោះអាទិភាពនីមួយៗត្រូវបានបញ្ជាក់លម្អិតដូចខាងក្រោម៖

### (១) ការកសាងប្រព័ន្ធអប់រំ និងការអភិវឌ្ឍសមត្ថភាព

- ការដាក់ឱ្យអនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល៖ ការបង្កើតយន្តការគ្រប់គ្រង និងបែងចែកជាតុចូល ដែលមានគុណភាព និងតម្រង់ទៅរកលទ្ធផល ជាតុចូលដែលគាំទ្រដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស និងការបណ្តុះបណ្តាលធនធានមនុស្សដែលមានគុណភាពល្អ និងភាពជាពលរដ្ឋល្អ
- ការគ្រប់គ្រងផ្តោតលើលទ្ធផលឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ៖ ពង្រឹងការគ្រប់គ្រង និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រចាំឆ្នាំ
- រៀបចំគោលការណ៍អនុវត្តដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ៖ ការពិនិត្យឡើងវិញមុខងារនិងភារកិច្ច ការរៀបចំផែនការប្រចាំឆ្នាំ ការអនុវត្តគន្លងអាជីព ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាន និងវាយតម្លៃ
- ពង្រឹងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស៖ ការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន ជាអ្នកដឹកនាំនិងគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃ ជាមួយគ្នានេះត្រូវបង្កើតយន្តការតម្រង់ទិសការងារ ការចុះជួយដឹកដៃការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ កែលម្អប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍគន្លងអាជីព ក៏ដូចជាការទទួលស្គាល់អ្នកជំនាញអប់រំ តាមរយៈ

ការលើកកម្ពស់ការប្រណាំងប្រជែង ការវាយតម្លៃនាយកសាលាល្អគ្រូបង្រៀនល្អ គ្រូបង្រៀនល្អភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង និងនាយកសាលាល្អជាដើម ដោយប្រើប្រាស់ប្រព័ន្ធវង្វាយតម្លៃការបំពេញការងារប្រចាំឆ្នាំ

- ពង្រឹងប្រព័ន្ធនិងផ្លាស់ប្តូររបៀបធ្វើការៈ ដោយប្រែក្លាយឧត្តមានុវត្តន៍នៃការអនុវត្តគម្រោងនានា មកជាការពង្រឹងប្រព័ន្ធការរៀបចំគោលនយោបាយ និងគោលការណ៍ណែនាំកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ២) កំណែទម្រង់សាលារៀន

- **សាលារៀនជំនាន់ថ្មី**
- **ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SBM)**

**កំណែទម្រង់សាលារៀនផ្តោតលើគោលការណ៍ធំៗ ដូចតទៅៈ**

- កែលម្អកម្មវិធី និងឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន និងនាយកសាលារៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដោយឈរលើមូលដ្ឋាននៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដានាយកសាលារៀន និងស្តង់ដាសាលារៀនមានប្រសិទ្ធភាព
- ពិនិត្យឡើងវិញ និងរៀបចំសេចក្តីណែនាំប្រតិបត្តិ សម្រាប់ការគ្រប់គ្រងសាលារៀននៅលើផ្នែកទាំងបួនៈ ១) ការគ្រប់គ្រងទូទៅនិងគ្រប់គ្រងរដ្ឋបាល ២) ការរៀននិងបង្រៀន ៣) ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ ៤) ការគ្រប់គ្រងបុគ្គលិក
- អនុវត្តអភិក្រមនៃការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព ដោយពង្រឹងវង្វាយតម្លៃសមត្ថភាពរបស់សិស្ស បង្កើនស្វ័យភាពក្នុងដឹកនាំនិងគ្រប់គ្រងនៅកម្រិតសាលារៀន បង្កើនគណនេយ្យភាពនៅកម្រិតសាលារៀន និងបង្កើនការចូលរួមរបស់សហគមន៍ និងអ្នកពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសាលារៀន
- រៀបចំប្រព័ន្ធសម្រាប់លើកគុណវុឌ្ឍិរបស់នាយកសាលា និង គ្រូបង្រៀន តាមរយៈយន្តការសហការរវាងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិអប់រំវិទ្យាស្ថានគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែលមានសក្តានុពល
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រងសាលារៀន និងការបង្រៀននិងរៀន ដោយបំពាក់នូវសម្ភារ ឧបករណ៍ពិសោធន៍ និងការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា
- ប្រែក្លាយសាលារៀនដែលមានសក្តានុពលទៅជាសាលារៀនជំនាន់ថ្មី និងសាលារៀនផ្តោតលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការវាស់វែងអំពីប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ដើម្បីទទួលមូលនិធិបន្ថែមពីរាជរដ្ឋាភិបាល និងបង្កើនការចូលរួមវិភាគទានពីមាតាបិតា និងសហគមន៍
- ផ្សារភ្ជាប់ការសិក្សានៅក្នុងសាលារៀនទៅនឹងឧត្តមសិក្សា សហគ្រាសឯកជន និងការរកប្រាក់ចំណូលតាមរយៈការបង្កើតកិច្ចសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា សហគ្រាសវិជ្ជាជីវៈ និងការបណ្តុះស្មារតីសហគ្រិនភាព។

### ៣) ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១

- បង្កើតកម្មវិធីអភិវឌ្ឍយុវជនទាំងបំណិនរឹង និងបំណិនទន់៖ ដោយផ្តោតលើបំណិនសតវត្សរ៍ទី២១ និងលើកកម្ពស់ភាពជាអ្នកដឹកនាំ
- បណ្តុះបណ្តាលយុវជន ឱ្យចូលរួមដោះស្រាយបញ្ហារួមរបស់ប្រទេសជាតិ មានភាពក្លាហាន និងមានភាពឈ្លាសវៃក្នុងការបញ្ចេញមតិ មានសមត្ថភាពត្រិះរិះពិចារណា សិក្សាស្រាវជ្រាវ ចែករំលែកគំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ
- ផ្តល់ឱកាសឱ្យយុវជនបញ្ចេញគំនិតយោបល់ បង្ហាញទេពកោសល្យ ដើម្បីបង្កើតសង្គមពុទ្ធិ និងស្វែងរកសុខដុមនីយកម្មសម្រាប់ទាំងអស់គ្នា បង្កើតទំនាក់ទំនងល្អរវាងយុវជន និងយុវជន និងលើកកម្ពស់តម្លៃមិត្តភាព
- បង្កើតជាថ្នាលសម្រាប់យុវជនហាត់ការឱ្យរឹងមាំ មានភាពចាស់ទុំនៃគំនិត និងចេះគិតយ៉ាងហ្មត់ចត់ ដោយបើកទូលាយដល់គ្រប់សាលារៀនទាំងអស់
- ពង្រឹងសមត្ថភាពស្ថាប័ន និងបន្តរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីឱ្យបានជាប់ជាប្រចាំ ដើម្បីបំពាក់បំប៉នជំនាញបន្ថែមលើការងារអភិវឌ្ឍកម្មវិធីសម្រាប់កុមារ និងយុវជនឱ្យឆ្លើយតបតាមបរិបទថ្មីៗ និងតម្រូវការរបស់សង្គម
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន អង្គការដៃគូ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីកៀរគរធនធានគាំទ្របន្ថែមដល់ការអនុវត្តកម្មវិធីប្រចាំឆ្នាំរបស់ខ្លួន
- មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរាជធានី ត្រូវបន្តយកចិត្តទុកដាក់ដល់ការងារពង្រឹងក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា ក្លឹបសិក្សា និងមុខវិជ្ជាផ្សេង តាមរយៈការជំរុញចលនាប្រឡងប្រណាំងពាល្អ នៅតាមគ្រឹះស្ថានសិក្សា
- មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរាជធានី ត្រូវបន្តទំនាក់ទំនងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍ និងអង្គភាពពាក់ព័ន្ធ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបំពាក់សម្ភារបរិក្ខារ ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញខ្ចីផ្សេងៗ ដែលឆ្លើយតបទៅតម្រូវការទីផ្សារការងារ ដើម្បីដាក់ឱ្យអនុវត្តនៅតាមមជ្ឈមណ្ឌលជាតិយុវជន និងរាជធានី ខេត្ត
- ពង្រឹងទំនាក់ទំនងការងារជាមួយអង្គការពិភពលោកនៃចលនាកាយរឹទ្ធិ ការិយាល័យប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងអង្គការ/សមាគមកាយរឹទ្ធិតាមបណ្តាប្រទេសនានា ដើម្បីកៀរគរធនធានគាំទ្រដល់សកម្មភាពកាយរឹទ្ធិ។ ការអភិវឌ្ឍសមត្ថភាពមន្ត្រី និងគ្រូឧទ្ទេសជំនាញកាយរឹទ្ធិកម្ម ត្រូវរៀបចំផែនការឱ្យបានច្បាស់លាស់ និងឆ្លើយតបទៅនឹងអប់រំបែបឌីជីថល ជាពិសេសយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៤) ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បង្កើនចំនួន និងទាក់ទាញសិស្សនៅមធ្យមសិក្សា និងឧត្តមសិក្សាឱ្យចូលរៀនផ្នែកវិទ្យាសាស្ត្រ ដោយបង្កើនចំនួនសាលារៀនជំនាន់ថ្មី សាលារៀនស្វែម និងបង្កើនម៉ោងបង្រៀន និងការបង្រៀនផ្តោតលើមេរៀនសំខាន់ៗ

- វិនិយោគបន្ថែម និងបង្កើនគុណភាពនៃការបណ្តុះបណ្តាលគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (ស្ទែម) ឱ្យដល់កម្រិតស្តង់ដាវិជ្ជាជីវៈ តាមរយៈការបង្កើតក្រុមការងារកែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជា បណ្តុះបណ្តាលគ្រូឧទ្ទេស និងពង្រឹងការបណ្តុះបណ្តាលមុខវិជ្ជាស្ទែម នៅតាមសាលាគរុកោសល្យ
- កែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាស្ទែម ដោយផ្តោតលើវិទ្យាសាស្ត្រវិធីរិះរក និងវិធីផ្សេងទៀតសម្រាប់ការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ ដើម្បីឱ្យសិស្សយល់ និងចងចាំ និងការផ្សារភ្ជាប់មេរៀនទៅនឹងជីវភាពប្រចាំថ្ងៃ
- វិនិយោគបន្ថែមលើការបំពាក់សម្ភារឧបទេស និងការធ្វើពិសោធន៍ នៅតាមវិទ្យាល័យ ធនធានសាលារៀនជំនាន់ថ្មី (គម្រោង STEP UP)
- ជំរុញការបង្កើតក្លឹបសិក្សាក្រោយម៉ោងសិក្សា និងពង្រឹងក្រុមប្រឹក្សាយុវជន៖ ដើម្បីជួយបង្រៀនបន្ថែមសម្រាប់សិស្សខ្សោយ
- បង្កើតប្រព័ន្ធអេកូឡូស៊ី៖ ដូចជា ពិព័រណ៍វិទ្យាសាស្ត្រ ការប្រកួត ក្រុមហ៊ុនឯកជន ភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សា

## ៥) ការអប់រំឌីជីថល

- បន្តលើកកម្ពស់ការអប់រំឌីជីថល តាមរយៈកែលម្អវេទិកាឌីជីថលដែលមានស្រាប់បង្កើតមជ្ឈមណ្ឌលអប់រំឌីជីថលនិងពីចម្ងាយ និងធ្វើឱ្យកាន់តែប្រសើរ និងការផលិតវីដេអូបង្រៀនចាំបាច់បន្ថែមទៀត
- ផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះនិងផ្សព្វផ្សាយលើវេទិកាឌីជីថលដែលមានស្រាប់
- បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀន និងរៀន ដោយត្រូវអភិវឌ្ឍសមត្ថភាពគណៈ-គ្រប់គ្រងសាលារៀន គ្រូបង្រៀន និងអនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១ ជាមួយប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ
- បង្កើតកម្មវិធីអប់រំឌីជីថលដូចជា ការរៀនសរសេរកូដភាសា (Coding) បង្កើតកម្មវិធីនានា (Apps) បង្កើតបញ្ញាសិប្បនិម្មិត (Robotics) and ការរចនារូបភាព ឬក្រាហ្វិច (Animation)
- បង្កើតបន្ទប់ឌីជីថលនៅតាមគ្រឹះស្ថានសិក្សា ដោយបង្កើតបន្ទប់មួយសម្រាប់ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក
- បំពាក់ប្រព័ន្ធគ្រប់គ្រងការសិក្សា និងប្រព័ន្ធគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួន នៅតាមគ្រឹះស្ថានសិក្សា
- សហការជាមួយភាគីពាក់ព័ន្ធក្នុងការផលិត និងផ្សព្វផ្សាយកម្មវិធីការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។

## ៦) កំណែទម្រង់សាលាគរុកោសល្យ

- កែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីផ្តល់ឱ្យគរុនិស្សិតប្រតិបត្តិគុណសម្បទាមានបំណិនសតវត្សរ៍ទី២១ មានគុណវុឌ្ឍិអនុលោមតាម «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន»

- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស ដោយផ្តោតលើ ១) ខ្លឹមសារមេរៀន ២) គរុកោសល្យ ជាពិសេសវិធីសាស្ត្របង្រៀនសម្បូរបែបតាមបែបសកម្ម ៣) បច្ចេកវិទ្យា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយបំពាក់បរិក្ខាររៀន និងបង្រៀនស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេស ឯកសាររៀននិងបង្រៀនទំនើបសម្បូណ៌បែប
- អភិវឌ្ឍភាពជាអ្នកដឹកនាំគ្រប់គ្រង ដោយផ្តោតលើម៉ូឌុល ៤ គឺៈ ១) ការគ្រប់គ្រង ការរៀន និងបង្រៀន ២) ការគ្រប់គ្រងរដ្ឋបាល ៣) គ្រប់គ្រងហិរញ្ញវត្ថុ ៤) ការគ្រប់គ្រងបុគ្គលិក និងធនធាន (វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ)
- ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ ដើម្បីពង្រឹងគុណភាពកម្មសិក្សាគរុកោសល្យ
- ធានាគុណភាពនៃការបណ្តុះបណ្តាល ដោយរៀបចំនូវប្រព័ន្ធធានាគុណភាពផ្ទៃក្នុង គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ និងការវាយតម្លៃឯករាជ្យ

## ៧) ការលើកកម្ពស់សុខភាពសិក្សា

- បង្កើតគណៈកម្មការសុខភាពសិក្សា នៅតាមសាលារៀន
- យកចិត្តទុកដាក់លើសុខភាពអ្នកសិក្សា និងគ្រូបង្រៀន ដោយបង្កើតបន្ទប់សុខភាពស្តង់ដា ការពិនិត្យសុខភាព និងសុខភាព ផ្លូវចិត្ត
- លើកកម្ពស់អាហារូបត្ថម្ភ ដោយផ្តោតលើ សុវត្ថិភាពចំណីអាហារ និងការផ្តល់អាហារតាមសាលារៀន
- លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ផ្តោតលើទឹកទទួលទាន កន្លែងលាងសម្អាតដៃ បង្គន់អនាម័យ ការពាក់ម៉ាស និងការរក្សាគម្លាត
- កែលម្អបរិស្ថានសិក្សា ដោយកែលម្អបរិស្ថានឱ្យក្លាយជាសាលាបៃតង និងសាលាស្អាតគ្មានសំរាម
- យកចិត្តទុកដាក់លើសន្តិសុខ និងសណ្តាប់ធ្នាប់ ដោយអនុវត្តវិធានការក្នុងការ កិច្ចការពារកុមារ មានវិន័យ គ្មានគ្រឿងញៀន
- អប់រំអំពីសុខភាពសិក្សា និងគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តតាមខ្លឹមសាររបស់កម្មវិធីសិក្សាមុខវិជ្ជា សុខភាពសិក្សា និងការហាត់ប្រាណ និងលេងកីឡា។

## ៨) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

- អនុវត្តកំណែទម្រង់នៅឧត្តមសិក្សា ផ្តោតលើការពង្រឹងអភិបាលកិច្ច ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យឱ្យមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ការកែលម្អកម្មវិធីសិក្សា និងធនធានសិក្សា ការប្រើប្រាស់បច្ចេកវិទ្យា ការអនុវត្តវិធីសាស្ត្របង្រៀនទំនើប ការស្រាវជ្រាវ ដោយផ្តោតលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា កសិកម្ម និងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ
- បង្កើតសាកលវិទ្យាល័យនិមិត្ត ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព ចែករំលែក និងប្រើប្រាស់ធនធានឌីជីថល និងធនធានសិក្សា រវាងគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ការបង្រៀន និងរៀនតាមប្រព័ន្ធអេឡិចត្រូនិច អនុវត្តការផ្ទេរក្រេឌីតសិក្សា និងផ្សារភ្ជាប់សាកលវិទ្យាល័យសិក្សាពីចម្ងាយនៅកម្ពុជា ជាមួយ ASEAN Cyber University (ACU)

- ផ្សារភ្ជាប់ការបណ្តុះបណ្តាលទៅនឹងទីផ្សារការងារ ដោយឈរលើគោលការណ៍ ការសិក្សាផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្តសិស្សដែលបញ្ចប់ការសិក្សាផ្នែកអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាមានលទ្ធភាពបន្តការសិក្សា បង្កើតអាជីវកម្ម និងបំពេញការងារនៅតាមស្ថាប័នរដ្ឋ ឬ ឯកជន
- បង្កើតមជ្ឈមណ្ឌលឌីជីថល និងបង្កើតបណ្តាញស្រាវជ្រាវជាមួយប្រទេសជាដៃគូ។

អាទិភាពទាំងនេះ ពិតជាបានផ្តល់គុណតម្លៃបន្ថែមលើរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ និងអាទិភាពលេចក៏ដូចជាយុទ្ធសាស្ត្រ និងសកម្មភាពឡើងថ្មីៗដែលមូលដ្ឋានគ្រឹះ សម្រាប់ជួយគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយជាតិ រដ្ឋាភិបាល និងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

ដើម្បីធានាក្នុងការផ្តល់សេវាអប់រំដល់សិស្សឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ក្រសួងបានដាក់ឱ្យដំណើរការសិក្សាជាផ្លូវការឆ្នាំសិក្សា២០២១-២០២២ ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ ខ្លឹមសារសំខាន់ៗនៃដំណើរការសិក្សានេះ ផ្តោតជាសំខាន់លើ ៖ ១) លទ្ធផលសិក្សារបស់សិស្សឆ្លើយតបទៅនឹងស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ២) ការរៀបចំអនាម័យនៅតាមគ្រឹះស្ថានសិក្សា ដោយរក្សាឱ្យបាននូវអភិក្រម «៣ការពារ ៣កុំ» ដើម្បីចូលរួមទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ក្នុងគ្រឹះស្ថានសិក្សា ការអប់រំពីសុវត្ថិភាព សុខភាពសិក្សា ការរក្សាគម្លាត ១,៥ម៉ែត្រ និងសុវត្ថិភាពចំណីអាហារ ៣) ការអនុវត្តទស្សនាទានថ្មី «គន្លងជីវិតថ្មីក្នុងវិស័យអប់រំ» ដោយផ្តល់សេវាបង្រៀននិងរៀនដែលមានភាពទន់ភ្លន់ ផ្អែកតាមទីតាំងភូមិសាស្ត្រនៃហានិភ័យឆ្លងរីករាលដាលកូវីដ-១៩ និងស្ថានភាពអប់រំ និងបន្តជំរុញ «ការអប់រំឌីជីថល» ៤) ការអនុវត្តកម្មវិធីសិក្សាបង្រួញ ដោយកំណត់មុខវិជ្ជាជម្រើសមេរៀនត្រូវសិក្សាក្នុងថ្នាក់និងក្រៅថ្នាក់ ៥) ការធានានូវភាពស័ក្តិសិទ្ធិនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ រួមទាំងការគ្រប់គ្រងសាលារៀន គ្រូបង្រៀន ថវិកា និងការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យអប់រំ និងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈជាប្រចាំ ៦) ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗដែលជាវិធីសាស្ត្រតាមបែបចម្រុះ ៧) ការពង្រឹងសក្តានុពលរបស់គ្រឹះស្ថានសិក្សាទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងសេវាបង្រៀននិងរៀន និងសាលារៀនមានប្រសិទ្ធភាព និង ៨) សហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យសេវាអប់រំប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបនឹងការអភិវឌ្ឍសេដ្ឋកិច្ចពុទ្ធិ និងវិបុលភាព ដើម្បីធានាបាននូវការបន្តការសិក្សារបស់សិស្សានុសិស្សក្នុងពេលដែលសាលារៀនផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈនៅទូទាំងប្រទេស អាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនពីចម្ងាយ តាមប្រព័ន្ធអេឡិចត្រូនិក ឬ រៀនតាមបណ្តុំតូចៗ អាស្រ័យលើស្ថានភាព និងធនធាន ក្រោមការច្នៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូនៅតាមមូលដ្ឋានរបស់ខ្លួន។

## ១. ចក្ខុវិស័យ បេសកកម្ម និងភារកិច្ចចម្បងៗ របស់ក្រសួង

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវចក្ខុវិស័យ គឺកសាងនិងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជននិងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថានៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូល សម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ជាអាទិ៍៖ (i) កំណត់នយោបាយអប់រំ យុវជន និងកីឡាសំដៅការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព (ii) កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (iii) កសាងផែនការ អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើកទិសដៅ និងវិធានការកែលម្អជាបន្តបន្ទាប់តាមមុខជំនាញ (iv) លើកកម្ពស់គុណភាពវិស័យ អប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង និងចំណេះធ្វើ សីលធម៌ និងចេះរួមរស់ជាមួយគ្នា (v) តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា (vi) លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដោយធានាសមធម៌ និងបរិយាបន្ន (vii) អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេសសហគ្រិនភាព និងអប់រំបច្ចេកទេសក្នុងតំបន់ (viii) សិក្សាសំណើបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ (ix) សិក្សាលើសំណើទទួលស្គាល់ការបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាឯកជន (x) លើកកម្ពស់ការស្រាវជ្រាវ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (xi) គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធនឹងការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ (xii) ការអភិវឌ្ឍការងារយុវជន និងការងារអប់រំកាយនិងកីឡា ដោយកំណត់វិធានការគ្រប់គ្រង បណ្ដុះបណ្ដាល និងបំប៉នបច្ចេកទេស (xiii) បង្កើនការយល់ដឹង

វប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ (xiv) គ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (xv) ពិនិត្យនិងផ្តល់យោបល់គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា (xvi) ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនរាជរដ្ឋាភិបាល និង (xvii) ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ការលើកកម្ពស់គុណភាពការអប់រំត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀននិងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្តោតសំខាន់លើគុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើនរូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ ២០២០។ គុណភាពកម្មវិធីសិក្សានៅអប់រំចំណេះទូទៅ និងឧត្តមសិក្សា ឱ្យស្របនឹងគុណភាពស្តង់ដាអាស៊ាន។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានកំណត់វិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលការងារ និងការបែងចែកធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយសមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអន្តរកាលដំណាក់កាលទី៣ ដែលរាជរដ្ឋាភិបាលបានសម្រេចបន្តរយៈពេល២ឆ្នាំទៀត (ឆ្នាំ២០២១ និងឆ្នាំ២០២២) ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំង៣ខាងដើម មុនឈានទៅអនុវត្តខឿនទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ដំណាក់កាលអន្តរកាលឆ្ពោះទៅខឿនទី៤ មានគោលដៅក្នុងការកសាងលក្ខខណ្ឌចាំបាច់នានា ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង " វប្បធម៌សមិទ្ធកម្ម"។

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ បានគាំទ្រដោយផែនការយុទ្ធសាស្ត្រថវិការយៈពេលបីឆ្នាំរំកិល ថវិកាកម្មវិធីប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ នាពេលកន្លងមកលើមូលដ្ឋានជាក់ស្តែង។ ថវិកាដែលត្រូវការសម្រាប់អនុវត្តកម្មវិធីទាំង ៥ សម្រាប់រយៈពេល ៣ឆ្នាំ។ តាមការធ្វើចំណោលលើគម្រោងចំណាយថវិកាកម្មវិធីសម្រាប់ឆ្នាំឆ្នាំ២០២២ ប្រៀបធៀបទៅនឹងថវិកាឆ្នាំ២០២១ មានការកើនឡើង ៣,២ ភាគរយ។ ប្រៀបធៀបថវិកាឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២២ មានការកើនឡើង ១,៧ ភាគរយ ហើយឆ្នាំ២០២៤ ទៅនឹងឆ្នាំ២០២៣ មានការកើនឡើង ៤,៥ ភាគរយ។

## ២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២១ និងវឌ្ឍនភាពគន្លឹះ

អំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការយុទ្ធសាស្ត្រថវិកាកន្លងមកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ចំពោះកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអន្តរកាលដំណាក់កាលទី៣នេះ រាជរដ្ឋាភិបាលបានសម្រេចបន្តរយៈពេល១ឆ្នាំទៀត (ឆ្នាំ២០២២) ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំង៣ខាងដើម មុនឈានទៅអនុវត្តខឿនទី៤ " គណនេយ្យភាពសមិទ្ធកម្ម "ស្របនឹងបរិបទកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាកម្មវិធីកំណែទម្រង់រយៈពេលវែង ដើម្បីធានាដល់ការផ្លាស់ប្តូរជាបណ្តើៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាការផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។

ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចសមិទ្ធផលបានក្នុងឆ្នាំសិក្សា២០២១-២០២២ ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃកំណែទម្រង់សំខាន់ៗ និងវឌ្ឍនភាពតាមអនុវិស័យទាំង៧ ដូចខាងក្រោម ៖

**ការអប់រំកុមារតូច៖** ឆ្នាំសិក្សា២០២១-២០២២ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៨ ៣៣៤ សាលា/កន្លែង កើន ៣២២ ក្នុងនោះសាលាមត្តេយ្យសិក្សារដ្ឋមាន ៤ ៥៦៣ កើន ៧០ (សាលាមត្តេយ្យសិក្សាដាច់ដោយឡែក ២៣៣ កើន ២២) មត្តេយ្យសិក្សាឯកជន ៦៨៨ កើន ១៦៩ និងមត្តេយ្យសិក្សាសហគមន៍ ៣ ០៨៣កន្លែង កើន ១៩កន្លែង ដែលមានទីតាំង ១ ០៥៣ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៤៦ ឃុំ សង្កាត់។

ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាពមាន ១៤ ១៥១ កើន ១១៨។ ថ្នាក់មត្តេយ្យសិក្សារដ្ឋ ៨ ៤៨២ ថយ ៣៤៨ មត្តេយ្យសិក្សាសហគមន៍ ៣ ៣១១ កើន ១១៤ ក្នុងនោះថ្នាក់មត្តេយ្យសិក្សាសហគមន៍ មានលក្ខណៈស្តង់ដា ១ ២៥០ ថ្នាក់ និងមត្តេយ្យសិក្សាឯកជន ២ ៣៥៨ កើន ៣០០។

កុមារទទួលបានសេវាអប់រំមាន ៣៣០ ៨០១នាក់ ស្រី ១៦៤ ៥៤០នាក់ ស្មើ ៥៩,៧៤ភាគរយ។ កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំមាន ៣៧ ៨៣៩នាក់ ស្មើ ១២,០៦ភាគរយ នៃចំនួនប្រជាជនអាយុ ៣ឆ្នាំ ស្រី ១៩ ៧១៨នាក់ ស្មើ ១២,៨៧ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំមាន ៩៤ ១៧៤នាក់ ស្មើ ២៧,៩៩ភាគរយ នៃចំនួនប្រជាជនអាយុ ៤ឆ្នាំ ស្រី ៤៨ ២៧៨នាក់ ស្មើ ២៩,៤១ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១៩៨ ៩១៧នាក់ ស្មើ ៥៩,៥៨ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ (ចំណុចដៅ ESP ៦៣,២ភាគរយ) ស្រី ៩៦ ៥៧០នាក់ ស្មើ ៥៩,២៧ភាគរយ។

អត្រារួមនៃការសិក្សា (មត្តេយ្យសិក្សាសាធារណៈ សហគមន៍ និងឯកជន) ៣៣,៦៣ភាគរយ ប្រុស ៣៣,០២ភាគរយ ស្រី ៣៤,២៦ភាគរយ ។

***មត្តេយ្យសិក្សារដ្ឋ៖*** កុមារទទួលបានកម្មវិធីមត្តេយ្យសិក្សារដ្ឋ ២១៧ ៧៨៧នាក់ ស្រី ១០៩ ០០៥នាក់។ កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ១៥ ០៦១នាក់ ស្មើ ៤,៨០ភាគរយ ស្រី ៧ ៩៩០នាក់ ស្មើ ៥,២២ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ៥៧ ៨៦៧នាក់ ស្មើ ១៧,២០ភាគរយ ស្រី ២៩ ៤៤៥នាក់ ស្មើ ១៧,៩៤ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១៤៤ ៨៥៩នាក់ ស្មើ ៤៣,៣៩ភាគរយ ស្រី ៧១ ៥៧០នាក់ ស្មើ ៤៣,៩២ភាគរយ។

***មត្តេយ្យសិក្សាឯកជន៖*** កុមារទទួលបានកម្មវិធីមត្តេយ្យសិក្សាឯកជន ៤១ ៦១៥នាក់ ស្រី ១៨ ៥៨៨ នាក់។ កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ៦ ៣២០នាក់ ស្មើ ២,០១ភាគរយ ស្រី ៣ ១០៦នាក់ ស្មើ ២,០៣ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ៩ ៧៨១នាក់ ស្មើ ២,៩១ភាគរយ ស្រី ៤ ៩១២ នាក់ ស្មើ ២,៩៩ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ២៥ ៦៤៣នាក់ ស្មើ ៧,៦៨ភាគរយ ស្រី ១០ ៥៩៦នាក់ ស្មើ ៦,៥០ភាគរយ។

***មត្តេយ្យសិក្សាសហគមន៍៖*** កុមារទទួលបានកម្មវិធីមត្តេយ្យសិក្សាសហគមន៍ ៧១ ៣៩៩នាក់ ស្រី ៣៦ ៩៤៧នាក់។ កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ១៦ ៤៥៨នាក់ ស្មើ ៥,២៤ភាគរយ ស្រី ៨ ៦២២ នាក់ ស្មើ ៥,៦៣ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ២៦ ៥២៦នាក់ ស្មើ ៧,៨៨ភាគរយ ស្រី ១៣ ៩២១នាក់ ស្មើ ៨,៤៨ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ២៨ ៤១៥នាក់ ស្មើ ៨,៥១ភាគរយ ស្រី ១៤ ៤០៤នាក់ ស្មើ ៨,៨៤ភាគរយ។

**ការអប់រំបឋមសិក្សា៖** ឆ្នាំសិក្សា២០២១-២០២២ សាលាបឋមសិក្សាសាធារណៈមាន ៧ ៣០៦ កើន ចំនួន ២ ធៀបនឹងឆ្នាំសិក្សា ២០២០-២០២១។ សាលារៀនមិនគ្រប់កម្រិតមាន ៣៣៣ ថយ ៤៩។ សាលាបឋមសិក្សាឯកជនមាន ៦៥៥ នៅគ្រប់រាជធានី ខេត្ត ។ ក្រសួងបានចេញប្រកាសបើកថ្មី ៥ ពេញលក្ខណៈ ១ ប្តូរឈ្មោះ ១ និងទទួលស្គាល់ ៥០៨។ សាលាសាធារណៈមានថ្នាក់រៀន ៦៣ ២៦៣ ថយ ៤០១ និងបន្ទប់រៀន ៤៦ ១៩២ កើន ៣៩០។

សិស្សសាធារណៈមាន ២ ០៣៦ ៥៦៦នាក់ កើន ២៦ ២៨០នាក់ ស្រី ៩៩៨ ៤១៦នាក់ ស្មើ ៤៩,០ភាគរយ កើន ៣៤ ២៦៤នាក់។ សិស្សឯកជនមាន ១៣០ ៥៨៦នាក់ កើន ១២ ១៥០នាក់ ស្រី ៦៤ ៦៤៣នាក់ ស្មើ ៤៩,៥ភាគរយ កើន ៦ ១៦៥នាក់។ អត្រាពិតចូលរៀនថ្មីសរុប ៨៥,៧ភាគរយ[1] ថយ ១,៧ភាគរយ ស្រី ៨៥,៥ភាគរយ ថយ ២,៥ភាគរយ ក្នុងនោះសាធារណៈ ៧៩,៦ភាគរយ ថយ ៣,១ភាគរយ ស្រី ៧៩,៤ភាគរយ ថយ ៣,៩ភាគរយ និងឯកជន ៦,១ភាគរយ កើន ១,៤ភាគរយ ស្រី ៦,១ភាគរយ កើន ១,៤ភាគរយ។ អត្រាពិតនៃការសិក្សាសរុប ៩៣,០ភាគរយ កើន ១,១ភាគរយ ស្រី ៩៤,២ភាគរយ កើន ១,៩ភាគរយ ក្នុងនោះសាធារណៈ ៨៦,៨ភាគ កើន ០,១ភាគរយ ស្រី ៨៧,៩ភាគរយ កើន ០,៩ភាគរយ និងឯកជន ៦,២ភាគរយ កើន ១,០ភាគរយ ស្រី ៦,៣ភាគរយ កើន ១,០ភាគរយ។

***សាលាជំនាន់ថ្មី៖***

ក្រសួងបាន៖

- អនុវត្តនៅសាលាបឋមសិក្សាអនុវត្តន៍ ហ៊ុន សែន ក្រុងកំពង់ចាម ខេត្តកំពង់ចាម សាលាបឋមសិក្សាស្វាយព្រហូត ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាលាបឋមសិក្សាអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម និងសាលាបឋមសិក្សា សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ សាលាបឋមសិក្សាទាំង ៤ មានសិស្ស ២ ៤៥១នាក់ ស្រី ១ ១៩៣នាក់
- បំប៉នសមត្ថភាពស្តីពីការប្រើប្រាស់ហ្គូហ្គលមីត ហ្គូហ្គលហ្វម ស្លែម ស្តង់ដាអំណាន ការសិក្សាតាមបែបស្ថាបនានិយម ការសិក្សាបែបសហការ ការប្រើប្រាស់កម្រិតសំណួរ ការបង្រៀននិងរៀន កម្មវិធីថេបប្លេត ការបង្រៀន ភាសាខ្មែរនិងគណិតវិទ្យា ការប្រើប្រាស់អាយស៊ីធី និងគន្លងអាជីព ដល់នាយកសាលានិងគ្រូបង្រៀន ៥១នាក់ ស្រី ៣២នាក់ នៅខេត្តកំពង់ចាម កំពង់ស្ពឺ និងស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀន និងការប្រើប្រាស់កញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ដំបូង ដល់នាយកសាលានិងគ្រូ ២១នាក់ ស្រី ១៦នាក់ នៅខេត្តកំពង់ស្ពឺ

រៀបចំបន្ទប់កុំព្យូទ័រ ២បន្ទប់ មានកុំព្យូទ័រ ៥០គ្រឿង រៀបចំបណ្ណាល័យ ២បន្ទប់ ផ្តល់ថេបប្លេត ៦០គ្រឿង ផ្តល់សម្ភារឧបទេសសម្រាប់ដំណើរការបង្រៀននិងរៀន ២៧ថ្នាក់ ផ្តល់អិលស៊ីឌី ៨គ្រឿង ផ្តល់ទូរទស្សន៍ ២គ្រឿង សម្រាប់បំពាក់នៅបណ្ណាល័យ បំពាក់កាមេរ៉ាសុវត្ថិភាពតាមអគារសិក្សា បណ្ណាល័យ និងទីចាត់ការ ដល់សាលាបឋមសិក្សាអង្គរបាន និងសាលាបឋមសិក្សាសម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ។

---

*1-ចំនួនប្រជាជនសរុបអាយុ ៦ឆ្នាំ តាមជំរឿនប្រជាជនឆ្នាំ២០១៩។*

**ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស៖** ឆ្នាំសិក្សា ២០២១-២០២២ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨១២ កើន ១២ ក្នុងនោះអនុវិទ្យាល័យ ១ ២៥៣ កើន ៧ និងវិទ្យាល័យ ៥៥៩ កើន ៥ (វិទ្យាល័យធនធាន ៥០ និងវិទ្យាល័យអប់រំពិសេស ៥) វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ៥២៤ កើន ០៤ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣៥ កើន០១។

គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ៣២៣ កើន ៧៤ ក្នុងនោះអនុវិទ្យាល័យ ១១២ កើន ៥០ និងវិទ្យាល័យ ២១១ កើន ២៤។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ២០៦ កើន ២៤ និងកម្រិតថ្នាក់ទី១០ ដល់ ទី១២ មាន ៥ ថេរ។

ឃុំ សង្កាត់ ១១១ លើ ១ ៦៥២ ស្មើ ៦,៧១ភាគរយ មិនទាន់មានអនុវិទ្យាល័យ (ថយ ៣ ឃុំសង្កាត់) ក្នុងនោះរាជធានីភ្នំពេញ ៤៦សង្កាត់ មិនតម្រូវឱ្យបង្កើតអនុវិទ្យាល័យ និងខេត្តរតនគិរី ២៣ឃុំមិនទាន់ទាមទារឱ្យបង្កើតអនុវិទ្យាល័យ។ ដោយឡែកស្រុក ២ លើ ២០៤ ស្មើ ០,៩៨ភាគរយ មិនទាន់មានវិទ្យាល័យ គឺបុរីអូរស្វាយសែនជ័យ ខេត្ត ស្ទឹងត្រែង និងក្រុងកោះរ៉ុង ខេត្តព្រះសីហនុ ដោយសារស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ។

ក្រសួងបាន៖

- កំពុងសាងសង់អគារសិក្សាសម្រាប់វិទ្យាល័យស្ថិតនៅខេត្តកណ្តាល កំពង់ចាម និងរាជធានីភ្នំពេញតាមរយៈគម្រោងជំនួយរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដើម្បីកែលម្អបរិស្ថានសាលារៀន និងការផ្តត់ផ្គង់សម្ភារបរិក្ខារអប់រំនៅកម្ពុជា រួមមានអគារធនធាន ១៧ខ្នង កម្ពស់ ២ជាន់ អគារសិក្សា ២៥ខ្នង ២៩៩បន្ទប់ ក្នុងនោះ ១ខ្នង មាន ៥បន្ទប់ ១៣ខ្នង កម្ពស់ ២ជាន់ មាន ១៤៤បន្ទប់ ៧ខ្នង កម្ពស់ ៣ជាន់ មាន ១៥០បន្ទប់ បង្គន់អនាម័យ ៣០ខ្នង មាន ១២០បន្ទប់ និងអណ្តូងទឹកស្អាត១៩ អគារស្នាក់នៅគ្រូ ៥ខ្នង (ស្នាក់នៅ ៥៥នាក់) អគារស្នាក់នៅគរុនិសិត្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន តាខ្មៅខេត្តកណ្តាល ១ខ្នង ៣ជាន់ តារាងបាល់បោះ១៥ បាល់ទាត់៨ របងសាលាប្រវែង ៦១០ម៉ែត្រ ផ្លូវ និងប្រព័ន្ធលូរំដោះទឹក ៧៥០ម៉ែត្រ
- រៀបចំឯកសារ និងត្រៀមសាងសង់អគារសិក្សាឆ្នាំ២០២២ ដល់២០២៤ សម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ មានអគារសិក្សា ៤៤០ខ្នង សាងសង់អគារថ្មី ៣០ខ្នង ១៥០បន្ទប់ និងជួសជុល ៤១០ខ្នង មាន ២០៥០បន្ទប់
- ជួសជុលអគារសិក្សា និងអគារធនធាននៃវិទ្យាល័យធនធាន តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ រួមមាន ជួសជុលបន្ទប់សិក្សានៃវិទ្យាល័យធនធានទៅជាបន្ទប់ពហុបំណង ២៥បន្ទប់, ជួសជុលអគារធនធាន ៣៦ទីតាំង បន្ទប់ពិសោធន៍២ បណ្ណាល័យ១ បន្ទប់កុំព្យូទ័រ ២បន្ទប់ ជួសជុលអគារសិក្សានៃវិទ្យាល័យធនធាន ៥០ទីតាំង ស្មើ ១០០បន្ទប់ សម្រាប់ធ្វើបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ, ជួសជុលអគារសិក្សានៃសាលាបណ្តាញ ៨៧ទីតាំង ១ទីតាំងមាន ២បន្ទប់ (បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ១ និងបន្ទប់បណ្ណាល័យ១) បណ្ណាល័យ ៨៧បន្ទប់ និងបន្ទប់ពិសោធន៍ ៨៧ បន្ទប់ ស្មើ ១៧៤បន្ទប់ ជួសជុលបន្ទប់ទឹក និងកន្លែងលាងដៃ នៅក្នុងអគារធនធាន ១៨ទីតាំង និងដំឡើងថាមពលដើរដោយពន្លឺព្រះអាទិត្យ ៥០ទីតាំង (វិទ្យាល័យធនធាន ២០ទីតាំង និងសាលាបណ្តាញ ៣០ទីតាំង)

- សាងសង់អគារសិក្សាសម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យ តាមរយៈគម្រោងសាងសង់ និងជួសជុលអគារសិក្សានៅមធ្យមសិក្សា រួមមានអគារសិក្សា ៥ខ្នង ១ជាន់ ៣៩បន្ទប់, សង់អគារសិក្សា ៤ខ្នង ២ជាន់ ៤៤បន្ទប់សង់អគារសិក្សា ១ខ្នង ៣ជាន់ ១៨បន្ទប់ សង់ការិយាល័យអប់រំនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ១ខ្នង មានបន្ទប់ទឹក និងបំពាក់សម្ភារ ជួសជុលអគារ ស្នាក់នៅសិស្ស និងគ្រូ ៣ខ្នង ៥៤បន្ទប់ បង្គន់អនាម័យ ៧ខ្នង ៣៥បន្ទប់ និងអណ្តូងទឹកស្អាត១១
- កាត់បន្ថយភាគរយសាលាមធ្យមសិក្សាបឋមភូមិមានស្តង់ដាអប្បបរមាទឹកស្អាតនិងអនាម័យ «កម្រិតសូន្យ» ពី ២៤,១ភាគរយ (៣០០សាលា ក្នុងចំណោម ១ ២៤៦សាលា) នៅឆ្នាំសិក្សា ២០២០-២០២១ មកនៅត្រឹម ១៨,៦ភាគរយ (២៣៣សាលា ក្នុងចំណោម ១ ២៥៣សាលា) នៅឆ្នាំសិក្សា ២០២១-២០២២
- កាត់បន្ថយភាគរយសាលាមធ្យមសិក្សាទុតិយភូមិមានស្តង់ដាអប្បបរមាទឹកស្អាតនិងអនាម័យ «កម្រិតសូន្យ» ពី ១៨,៤ភាគរយ (១០២សាលា ក្នុងចំណោម ៥៥៤សាលា) នៅឆ្នាំសិក្សា ២០២០-២០២១ មកនៅត្រឹម ១៤,១ភាគរយ (៧៩សាលា ក្នុងចំណោម ៥៥៩សាលា) នៅឆ្នាំសិក្សា ២០២១-២០២២។

អនុវិទ្យាល័យ និងវិទ្យាល័យមានបង្គន់អនាម័យ ១០០ភាគរយ។ អនុវិទ្យាល័យ ១១,៦ភាគរយ និងវិទ្យាល័យ៨,៨ ភាគរយ មិនទាន់មានទឹកស្អាត។ អនុវិទ្យាល័យ ១៩,២ភាគរយ និងវិទ្យាល័យ ១៤,៦ ភាគរយ មិនទាន់មានកន្លែងសម្អាតដៃ។ អនុវិទ្យាល័យ ៥៤,៧ភាគរយ និងវិទ្យាល័យ ៣១,៩ភាគរយ មិនទាន់មានប្រអប់សង្គ្រោះបឋម។

ក្រសួងបាន៖

- បន្តអនុវត្តគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី
- ដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មី ៧ រួមមាន៖
  - វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ខេត្តកំពង់ចាម
  - វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ
  - វិទ្យាល័យ ព្រែកលៀប រាជធានីភ្នំពេញ
  - វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ ខេត្តកណ្តាល
  - វិទ្យាល័យ គោកព្រីង ខេត្តស្វាយរៀង
  - វិទ្យាល័យ ហ៊ុន សែន ៣មជីកង ខេត្តកំពង់ចាម
  - វិទ្យាល័យ ព្រះយុគន្ធរ (អ៊ីធូស្នេម) រាជធានីភ្នំពេញ

### *វឌ្ឍនភាពសាលារៀនជំនាន់ថ្មី*

ក្រសួងបាន៖

- បង្កើនវិសាលភាពកម្មវិធីសាលារៀនជំនាន់ថ្មីសិស្សកើនដល់ ៥ ០៤១នាក់ ស្រី ២ ៦៩១នាក់
- វាយតម្លៃទទួលស្គាល់គុណភាព ៨៧ភាគរយ ដែលបានវាយតម្លៃទទួលស្គាល់គុណភាព

- រៀបចំផែនការសកម្មភាពដើម្បីធានានិរន្តរភាពដោយកៀរគរថវិកាគាំទ្រសម្រាប់ដំណើរការសាលារៀន ពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សបាន ៦សាលា ក្នុងចំណោម៧សាលារៀនដើម្បីកាត់បន្ថយបន្ទុករដ្ឋាភិបាល
- បង្កើតការគ្រប់គ្រងតាមបែបចម្រុះដោយមានការចូលរួមពីដៃគូពាក់ព័ន្ធ គណៈគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលសាលារៀន
- អនុវត្តកម្មវិធីសិក្សាតាមបែបទន់ភ្លន់ ដើម្បីបង្រៀនសិស្សឱ្យមានចំណេះដឹង ជំនាញបច្ចេកទេស បំណិនជីវិត ជំនាញទន់ និងមានអាកប្បកិរិយាល្អ
- បណ្តុះបណ្តាលគ្រូស្តីពីវិធីសាស្ត្របង្រៀនតាមបែបស្ថាបនានិយម វិធីរិះរក វិធីវិទ្យាសាស្ត្រ ៥E PBL IBL Blended-Learning និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀនសិស្សដោយអ្នកជំនាញក្នុងកម្មវិធី NGS ដល់ឆ្នាំ២០២១
- រៀបចំសេចក្តីព្រាងឯកសារ ១៩ សម្រាប់បណ្តុះបណ្តាលគ្រូក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី
- អនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះ បែបស្ថាបនានិយម និងរៀនបែបសហការ
- រៀបចំការប្រជុំបច្ចេកទេសគ្រូនៅតាមសាលារៀនជំនាន់ថ្មី ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបន្ថែម PLC ជារៀងរាល់ សប្តាហ៍ ខែ និងឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ Reflection
- រៀបចំបន្ទប់ពិសោធន៍វិទ្យាសាស្ត្រតាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សរ៍ទី២១។ អនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា (Subject Classroom)
- ពង្រឹងការបង្រៀននិងរៀន ការអប់រំបំណិនជីវិត ការអប់រំស្វែម ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន បន្ទប់សង្គ្រោះបឋម និងក្លឹបសិក្សា (Club and Project Work) លើមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន និងប្រវត្តិវិទ្យា
- បង្កើនការអប់រំតាមបែបឌីជីថល (ការផលិតវីដេអូ)
- ពង្រឹងការបង្រៀននិងរៀនរបស់សិស្សគ្រូតាមប្រព័ន្ធអនឡាញដោយគ្រូថតវីដេអូផ្ទាល់នៅគ្រប់កម្រិតថ្នាក់ក្នុងបរិបទកូវីដ-១៩ និងបន្តការរៀន បង្រៀនរបស់សិស្សតាមប្រព័ន្ធអនឡាញបន្ថែមទៀតឱ្យស្របនឹងសម័យកាលឌីជីថលដោយមិនគិតតែបរិបទកូវីដ-១៩
- បង្កើតតេស្តវាយតម្លៃសិស្សសម្រាប់ការរៀន និងបង្រៀនទៅតាមប្រធានបទមេរៀនតាមកម្រិតថ្នាក់ និងចងក្រងបង្កើតជាធនាគារសំណួរសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី
- លើកកម្ពស់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំ បរិស្ថានក្នុងថ្នាក់ និងក្រៅថ្នាក់។

**ការអប់រំឧត្តមសិក្សា៖** គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១៣០ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៤៨ និងឯកជន ៨២ មានទីតាំងស្ថិតនៅ ២០ ខេត្ត និងរាជធានីភ្នំពេញ។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៦។

គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ៨២ ក្នុងនោះគ្រឹះស្ថានសាធារណៈ ១៣ និងឯកជន ៦៩។ គ្រឹះស្ថានឧត្តមសិក្សា ៤៥ ផ្តល់សេវាអប់រំថ្នាក់បរិញ្ញាបត្រ

ជាន់ខ្ពស់ ក្នុងនោះ គ្រឹះស្ថានសាធារណៈ ១០ និងឯកជន ៣៥។ គ្រឹះស្ថានឧត្តមសិក្សាផ្តល់សេវាអប់រំថ្នាក់បណ្ឌិតមាន២១ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៦ និងឯកជន ១៥។

និស្សិតកំពុងសិក្សាឆ្នាំសិក្សា២០២០-២០២១ មាន ១៩៨ ៣៦៣នាក់ ស្រី ៩៨ ៥៣៥នាក់ ស្មើ ៤៩,៦៧ភាគរយ ក្នុងនោះនិស្សិតបរទេស ១៥៩នាក់ ស្រី ៧៤នាក់ ស្មើ ៤៦,៥៤ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ និស្សិតថយ ៣ ៥៣៧នាក់ ស្មើ ១,៧៥ភាគរយ។

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង ១៨ ៦៧៤នាក់ ស្រី ៩ ៥៤៣នាក់ ស្មើ ៥១,១០ភាគរយក្នុងនោះ និស្សិត អាហារូបករណ៍ ២ ០២៥នាក់ ស្រី ៩៤៩នាក់ ស្មើ ៤៦,៨៦ភាគរយ និងនិស្សិតបង់ថ្លៃសិក្សា ១៦ ៦៤៩នាក់ ស្រី ៨ ៥៩៤នាក់ ស្មើ ៥១,៦១ភាគរយ។ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ និស្សិតថ្នាក់បរិញ្ញាបត្ររងថយ ១ ១០៨នាក់ ស្មើ ៥,៩៣ ភាគរយ ស្រីថយ ៦៩៦នាក់ ស្មើ ៧,២៩ភាគរយ។

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ១៧០ ២៤៦នាក់ ស្រី ៨៦ ១៥៨នាក់ ស្មើ ៥០,៦០ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ ថយ ៩៣៧នាក់ ស្មើ ០,៥៥ភាគរយ ស្រីថយ ៦ ០៧៩នាក់ ស្មើ ៧,០៥ភាគរយ។ និស្សិតអាហារូបករណ៍ ២៦ ០៤៣នាក់ ស្រី ១៣ ៦២៥នាក់ ស្មើ ៥២,៣១ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ ថយ ១ ៣៤៨នាក់ ស្មើ ៥,១៧ភាគរយ ស្រីថយ ១ ៤៣២នាក់ ស្មើ ១០,៥១ភាគរយ។ និស្សិតចូលរៀនថ្នាក់ឆ្នាំទី១ ចំនួន ៥៦ ១០១នាក់ ស្រី ២៦ ៧៣២នាក់ ស្មើ ៤៧,៦៤ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ ថយ ២ ៦៦៦នាក់ ស្មើ ៤,៧៥ភាគរយ ស្រីថយ ៥ ៥២៣នាក់ ស្មើ ២០,៦៦ភាគរយ។

និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ៩ ៤៤៣នាក់ ថយ ១៣,៧២ភាគរយ ស្រី ២ ៨៣៤នាក់ ស្មើ ៣០,០១ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៨ ៤៦៥នាក់ ស្រី ២ ៧១៨នាក់ ស្មើ ៣២,១១ ភាគរយ និងថ្នាក់បណ្ឌិត ៩៧៨នាក់ ស្រី ១១៦នាក់ ស្មើ ១១,៨៦ភាគរយ បើធៀបឆ្នាំសិក្សា២០១៩-២០២០ និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ថយ ១៥,២១ភាគរយ និស្សិតថ្នាក់បណ្ឌិតកើន ១,៧៧ ភាគរយ។

និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ៧ ៩៨៥នាក់ ស្រី ៣ ៩៦៧នាក់ ស្មើ ៤៩,៦៨ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ ៨៩៣នាក់ ស្រី ៤០៦នាក់ ស្មើ ៤៥,៤៦ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃសិក្សា ៧ ០៩២នាក់ ស្រី ៣ ៥៦១នាក់ ស្មើ ៥០,២១ភាគរយ។ បើធៀបនឹងឆ្នាំសិក្សា២០១៩-២០២០ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងថយ ១៩៩នាក់ ស្មើ ២,៤៩ភាគរយ ស្រីថយ ៣៩៣នាក់ ស្មើ ៩,៩០ ភាគរយ។ និស្សិតអាហារូបករណ៍ថយ ៣១នាក់ ស្មើ ៣,៤៧ភាគរយ ស្រីថយ ៦៩នាក់ ស្មើ ១,៦៩ភាគរយ។

និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ៣១ ០៥៦នាក់ ស្រី ១៥ ១២៧នាក់ ស្មើ ៤៨,៧០ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ ៥ ២១៤នាក់ ស្រី ២ ៥២៨នាក់ ស្មើ ៤៨,៤៨ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃសិក្សា ២៥ ៨៤២នាក់ ស្រី ១២ ៥៩៩នាក់ ស្មើ ៤៨,៧៥ភាគរយ។ ធៀបទៅនឹងឆ្នាំសិក្សា ២០១៩-២០២០ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រថយ ១ ៥៨៤នាក់ ស្មើ ៥,១០ភាគរយ ស្រីថយ ១ ៣៥៥នាក់ ស្មើ ៨,៩៥ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ថយ ៣៧៣នាក់ ស្មើ ៧,១៥ភាគរយ ស្រីថយ ៤១០នាក់ ស្មើ ១៦,២១ភាគរយ។

និស្សិតបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ៤ ២១៤នាក់ កើន ២១,០៥ភាគរយ ស្រី ៣១,៤៩ ភាគរយ កើន៤១,៩៣ភាគរយ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ ៤ ១៥៩នាក់ កើន ២៦,១៨ភាគរយ ស្រី

៣១,៧៩ភាគរយ កើន ៤១,៨៥ភាគរយ។ និស្សិតសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ៣៧១នាក់ថយ ២០,២២ភាគរយ ស្រី ៣៩,៨៩ភាគរយ កើន ០,៦៨ ភាគរយ ក្នុងនោះគ្រឹះស្ថានសាធារណៈ ៣៤១នាក់ ថយ ៩,៧៩ភាគរយ ស្រី ៣៩,៨៨ភាគរយ និងគ្រឹះស្ថានឯកជន ៣០ នាក់ ថយ ៦៥,៥២ភាគរយ ស្រី ៤០ភាគរយ ថយ ៥២ភាគរយ និងថ្នាក់បណ្ឌិត ៥៥នាក់ កើន ៧៧,៤២ភាគរយ ស្រី ៩,០៩ភាគរយ កើន ៦៦,៦៧ភាគរយ។

និស្សិតថ្នាក់បរិញ្ញាបត្រមាន ៦៩ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ក្នុងនោះ ៤២ភាគរយ សិក្សាជំនាញធុរកិច្ច ៦ភាគរយសិក្សាជំនាញច្បាប់ ៩ភាគរយសិក្សាជំនាញភាសាបរទេស ៣ភាគរយសិក្សាជំនាញទេសចរណ៍ និង៩ភាគរយសិក្សាជំនាញវិទ្យាសាស្ត្រសង្គមនិងសិល្បៈផ្សេងៗទៀត។ ចំណែកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មាន ៣១ភាគរយ ក្នុងនោះ ៥ភាគរយសិក្សាជំនាញវិទ្យាសាស្ត្រមូលដ្ឋាន ១០ភាគរយសិក្សាជំនាញបច្ចេកវិទ្យាព័ត៌មាន ៨ភាគរយសិក្សាជំនាញសិក្សាវិស្វកម្ម ៣ភាគរយសិក្សាជំនាញកសិកម្ម និង ៥ភាគរយសិក្សាជំនាញសុខាភិបាល។ ជារួមក្នុងរយៈពេល ៥ឆ្នាំ ការសិក្សាជំនាញ STEM បានកើនពី ២៦,៨៣ភាគរយ នៅឆ្នាំសិក្សា ២០១៦-២០១៧ ដល់ ៣០,៦៩ភាគរយ នៅឆ្នាំសិក្សា២០២០-២០២១។

និស្សិតថ្នាក់បណ្ឌិតមាន ៨៨ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ៥ភាគរយសិក្សាផ្នែកមនុស្សសាស្ត្រ ១ភាគរយសិក្សាវិទ្យាសាស្ត្រធម្មជាតិ ១ភាគរយសិក្សាវិទ្យាសាស្ត្រកសិកម្ម និង៥ភាគរយ សិក្សាផ្នែកវិស្វកម្ម និងបច្ចេកវិទ្យា។ គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន មិនទាន់ផ្តោតការវិនិយោគខ្លាំងលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅឡើយ។ ដូច្នេះ ទាមទារឱ្យមានការជំរុញការវិនិយោគបន្ថែម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការស្រាវជ្រាវ។

និស្សិតដែលបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រប្រមាណ ៦៧ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ក្នុងនោះ ៣៧ភាគរយសិក្សាជំនាញធុរកិច្ច ៨ភាគរយសិក្សាជំនាញច្បាប់ ១០ភាគរយសិក្សាជំនាញភាសាបរទេស ៣ភាគរយ សិក្សាជំនាញទេសចរណ៍ និង ១១ភាគរយសិក្សាជំនាញវិទ្យាសាស្ត្រសង្គម និងសិល្បៈផ្សេងៗទៀត។ ចំណែកជំនាញ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មាន ៣៣ភាគរយ ក្នុងនោះវិទ្យាសាស្ត្រមូលដ្ឋាន ៦ភាគរយ បច្ចេកវិទ្យាព័ត៌មាន ១១ភាគរយ វិស្វកម្ម ៧ភាគរយ កសិកម្ម ៤ភាគរយ និងសុខាភិបាល ៥ភាគរយ។

និស្សិតបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ១ភាគរយប៉ុណ្ណោះសិក្សាផ្នែកវិស្វកម្ម និងបច្ចេកវិទ្យា ៦ភាគរយ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ ២ភាគរយផ្នែកវិទ្យាសាស្ត្រកសិកម្ម ៨ភាគរយផ្នែកមនុស្សសាស្ត្រ និង ៨៣ភាគរយផ្នែកវិទ្យាសាស្ត្រសង្គម។ ដូច្នេះ កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមខាងគម្លាត ជំនាញក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលទាមទារឱ្យវិនិយោគបន្ថែមទៀត ។

និស្សិតបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ២ភាគរយសិក្សាផ្នែកវិស្វកម្មនិងបច្ចេកវិទ្យា ២ភាគរយសិក្សាផ្នែកកសិកម្ម ៥ភាគរយសិក្សាផ្នែកមនុស្សសាស្ត្រ និង ៩១ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម។ ដូច្នេះ កម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈមខាងគម្លាតជំនាញកម្រិតបណ្ឌិត ដែលទាមទារឱ្យវិនិយោគបន្ថែមទៀត ក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។

**ការអប់រំក្រៅប្រព័ន្ធ៖** រាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ២៥ កម្មវិធីក្រោយអក្ខរកម្មមាន ១៦ កម្មវិធីចូលរៀនឡើងវិញមាន ៦ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ២៤ កម្មវិធីសមមូលបឋមសិក្សាមាន ២៤ កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិមាន ៣ និងកម្មវិធីបំពេញវិជ្ជាមាន ២១។

## រាជធានី ខេត្តដែលបានអនុវត្តកម្មវិធី

| កម្មវិធី | រាជធានី ខេត្ត | |
|---|---|---|
| | ២០១៩-២០២០ | ២០២០-២០២១ |
| អក្ខរកម្មវិជ្ជាជីវៈ | ២៥ | ២៥ |
| ក្រោយអក្ខរកម្ម | ១៧ | ១៦ |
| ចូលរៀនឡើងវិញ | ៣ | ៦ |
| បង្កើនប្រាក់ចំណូល | ២២ | ២៤ |
| សមមូលបឋមសិក្សា | ២៣ | ២៤ |
| សមមូលមធ្យមសិក្សាបឋមភូមិ | ៥ | ៣ |
| បំពេញវិជ្ជា | ២០ | ២១ |

ថ្នាក់អក្ខរកម្មមាន ៩០៩ថ្នាក់ គ្របដណ្តប់ ៨៤០ភូមិ ៥៥៣ឃុំ សង្កាត់ ១៨៦ក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេស។ ក្រសួងអប់រំ យុវជន និងកីឡាគ្រប់គ្រងថ្នាក់អក្ខរកម្ម ៨៧០ ថយ ៨ ស្មើ ០,៩១ភាគរយ និងដៃគូអភិវឌ្ឍគ្រប់គ្រងថ្នាក់អក្ខរកម្ម ៣៩ កើន ២៣ ស្មើ ១៤៣,៧៥ភាគរយ។ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយអង្គការយូណេស្កូ អង្គការស៊ីប៉ា អង្គការអោយឡូ និងរោងចក្រ បានអនុវត្តកម្មវិធីអក្ខរកម្មនៅតាមរោងចក្រ ១៧ថ្នាក់ ដោយដំណើរការនៅខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កោះកុង សៀមរាប ស្វាយរៀង និងរាជធានីភ្នំពេញ និងសហការជាមួយក្រសួងមហាផ្ទៃ បានអនុវត្តកម្មវិធីអក្ខរកម្មនៅតាមពន្ធនាគារមាន ៣៣ថ្នាក់ ដូចជាខេត្តត្បូងឃ្មុំ ឧត្តរមានជ័យ តាកែវ ស្វាយរៀង រតនគិរី ពោធិ៍សាត់ ព្រៃវែង ព្រះវិហារ ក្រចេះ កោះកុង កណ្តាល កំពត កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ និងរាជធានីភ្នំពេញ និងនៅមណ្ឌលអប់រំកែប្រែមាន ៧ថ្នាក់ នៅខេត្តត្បូងឃ្មុំ និងរាជធានីភ្នំពេញ។

គ្រូអក្ខរកម្មមាន ៩២៨នាក់ ស្រី ៤៤,១៨ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ៨៧០នាក់ ស្រី ៤៤,០២ភាគរយ និងគ្រប់គ្រងដោយដៃគូអភិវឌ្ឍ ៥៨នាក់ ស្រី ៤៦,៥៥ភាគរយ។ គ្រូអក្ខរកម្មបានទទួលការបំប៉ន ៥៩៧នាក់ ស្រី ៤៣,៨៨ភាគរយ ក្នុងនោះបំប៉នដោយក្រសួងអប់រំ យុវជន និងកីឡា ៥៤០នាក់ ស្រី ៤៣,៧០ភាគរយ រួមទាំងគ្រូអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្របានបំប៉ន ១៥នាក់ ស្រី ៧៣,៣៣ភាគរយ ពន្ធនាគារបានបំប៉ន ២៤នាក់ ស្រី ២៩,១៧ភាគរយ និងមណ្ឌលអប់រំកែប្រែបានបំប៉ន ៧នាក់ ស្រី ១៤,២៩ភាគរយ។ គ្រូអក្ខរកម្មបំប៉នដោយដៃគូអភិវឌ្ឍ ៥៧នាក់ ស្រី ៤៥,៦១ភាគរយ។

អ្នកសិក្សាមាន ១៧ ៥៤៤នាក់ ស្រី ៦៤,៥២ភាគរយ ក្នុងនោះអ្នកសិក្សានៅតាមរោងចក្រមាន ៣៣៥នាក់ ស្រី ១០០ភាគរយ នៅពន្ធនាគារ ៦៧៣នាក់ ស្រី ៩,៨១ភាគរយ នៅមណ្ឌលអប់រំកែប្រែ ១៧៤នាក់ ស្រី ១៣,៧៩ភាគរយ។ អ្នកសិក្សាបានបញ្ចប់វគ្គ ១៤ ៤០៤នាក់ ស្រី ៦៥,១៤ភាគរយក្នុងនោះ

ឆ្លងកាត់តេស្តស្តង់ដាបញ្ចប់ជាប់ ១៣ ២១៦នាក់ ស្មើ ៩១,៧៥ភាគរយ ស្រី ៦៥,៩០ភាគរយ ដោយមានបំណិនផ្នែកអក្សរ ១១ ៣៥៤នាក់ ស្មើ ៧៨,៨៣ភាគរយ ស្រី ៦៦,៦៤ភាគរយ និងបំណិនផ្នែកលេខ១០ ២១២នាក់ ស្មើ ៧០,៩០ភាគរយ ស្រី ៦៦,៤២ ភាគរយ។

អនក្ខរជនអាយុ ១៥ឆ្នាំឡើងមាន ៦៤៦ ២៦៧នាក់ ស្រី ៥១,៤១ភាគរយ (ស្ថិតិពីមន្ទីរ អ.យ.ក. រាជធានី ខេត្តឆ្នាំ២០២១) ក្នុងឆ្នាំនេះ កម្មវិធីអក្ខរកម្មបានរំដោះអនក្ខរជន ១៣ ២១៦នាក់ ស្មើ ២,០៤ភាគរយ ស្រី ៦៥,៩០ភាគរយ។

### ការអភិវឌ្ឍយុវជន៖ *កម្មវិធីកូនល្អ សិស្សល្អ មិត្តល្អ*

ក្រសួងបានបូកសរុបចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" នៅថ្នាក់ជាតិ មានអ្នកចូលរួម ១៧៥នាក់ ស្រី ៥១ភាគរយ ដើម្បីអភិវឌ្ឍបំណិនយុវជន និងកុមារឱ្យក្លាយជាពលរដ្ឋល្អ។

***ការងារក្រុមប្រឹក្សាកុមារកម្ពុជា៖*** ក្រុមប្រឹក្សាកុមារកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិ គិតពីថ្នាក់ទី៤ ដល់ថ្នាក់ទី៩។ក្រសួងបានធ្វើបច្ចុប្បន្នកម្មស្ថិតិក្រុមប្រឹក្សាកុមារកម្ពុជា មានដូចតារាងខាងក្រោម៖

### ស្ថិតិក្រុមប្រឹក្សាកុមារកម្ពុជាឆ្នាំសិក្សា២០១៩-២០២០ និង២០២០-២០២១

| បរិយាយ | ២០១៩-២០២០ | ២០២០-២០២១ | កើន/ថយ (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាកុមារកម្ពុជា | ៨ ៥៨៥ | ៨ ៦៩០ | +១០៥ |
| ចំនួនសាខា | ៣៧ ៣៤៧ | ៤៤ ១៧០ | +៦ ៨២៣ |
| ចំនួនអនុសាខា | ២៤០ ៣៣៦ | ២៥៤ ៥០០ | +១៤ ១៦៤ |
| ចំនួនសមាជិក | ១ ៣៤៧ ៦៥៤<br>(ស្រី ៧៣៦ ១១០) | ១ ៥៨៣ ៦០២<br>(ស្រី ៧៩៤ ៧៥០) | +២៣៥ ៩៤៨<br>(ស្រី +៥៨ ៦៤០) |

ក្រុមប្រឹក្សាកុមារកម្ពុជា រួមមានសមាជិក សាខា និងអនុសាខា កើនឡើងដោយសារមានការពិនិត្យតាមដានច្បាស់លាស់ និងការពង្រឹងយន្តការប្រមូលស្ថិតិ តាមរយៈកំណើនគ្រឹះស្ថានសិក្សាដែលបានរៀបចំក្រុមប្រឹក្សាកុមារកម្ពុជា ការអនុវត្តកម្មវិធីបំណិនជីវិត និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។

***ការងារក្រុមប្រឹក្សាយុវជនកម្ពុជា៖*** ក្រុមប្រឹក្សាយុវជនកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។ ក្រសួងបានធ្វើបច្ចុប្បន្នកម្ម ស្ថិតិក្រុមប្រឹក្សាយុវជនកម្ពុជា ដូចខាងក្រោម៖

### ស្ថិតិក្រុមប្រឹក្សាយុវជនកម្ពុជាឆ្នាំសិក្សា២០១៩-២០២០ រហូតដល់ឆ្នាំសិក្សា២០២០-២០២១

| បរិយាយ | ២០១៩-២០២០ | ២០២០-២០២១ | កើន/ថយ (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាយុវជនកម្ពុជា | ៥៤៣ | ៥៩១ | +៤៨ |
| ចំនួនសាខា | ៧ ៤០៣ | ៨ ១៧៥ | +៧៧២ |

| | | | |
|---|---|---|---|
| ចំនួនអនុសាខា | ៤៤ ៤១៨ | ៤៨ ៦៧៣ | +៤ ២៥៥ |
| ចំនួនសមាជិក | ២៩៦ ៥៩៧<br>(ស្រី ១៨៣ ៣៤៣) | ៣៥៧ ៧៨៦<br>(ស្រី ១៩៤ ៧១៤) | +៦១ ១៨៩<br>(ស្រី +១១ ៣៧១) |

ក្រុមប្រឹក្សាយុវជនកម្ពុជា មានសាខា និងអនុសាខា កើនឡើង ដោយមានកម្មវិធីស្ម័គ្រចិត្ត កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន តាមរយៈកំណើនគ្រឹះស្ថានសិក្សាដែលបានរៀបចំក្រុមប្រឹក្សាយុវជនកម្ពុជា និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។

ក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមប្រឹក្សាកុមារកម្ពុជា បានជួយដល់ការងារស្វ័យគ្រប់គ្រងសាលារៀន គាំទ្រសកម្មភាពក្លឹប ការងារស្ម័គ្រចិត្ត និងជួយសិស្សប្រឡងថ្នាក់ទី១២។

***ការងារកាយរឹទ្ធិកម្ម៖*** ក្រសួងបានធ្វើបច្ចុប្បន្នកម្មស្ថិតិសមាជិកកាយរឹទ្ធិជាតិកម្ពុជា ដូចខាងក្រោម៖

## ស្ថិតិសមាជិកភាពឆ្នាំសិក្សា២០១៩-២០២០ ធៀបនឹងឆ្នាំសិក្សា២០២០-២០២១

| បរិយាយ | ២០១៩-២០២០ | ២០២០-២០២១ | ស្ថានភាព(+/-) |
|---|---|---|---|
| ចំនួនកាយរឹទ្ធិប្អូន(៩-១១ឆ្នាំ) | ១២ ៩២៣ | ១៥ ២២៣ | +២ ៣០០ |
| ចំនួនកាយរឹទ្ធិ (១២-១៧ឆ្នាំ) | ១១៦ ៦៤២ | ១១៩ ៣៤២ | +២ ៧០០ |
| ចំនួនកាយរឹទ្ធិរៀមច្បង (១៨-២៥ឆ្នាំ) | ២១ ២៤៤ | ២១ ២៤៤ | ០ |
| ចំនួនមេដឹកនាំកាយរឹទ្ធិ (២៦ឆ្នាំឡើង) | ១២ ៩៨៩ | ១២ ៩៨៩ | ០ |
| ចំនួនសមាជិកកិត្តិយស | ២ ៣៣៧ | ២ ៣៣៧ | ០ |
| **ចំនួនសរុប** | **១៦៦ ១៣៥** | **១៧១ ១៣៥** | **+៥ ០០០** |

តារាងខាងលើបង្ហាញថា សមាជិកកាយរឹទ្ធិកើនឡើងដោយសារប្រសិទ្ធភាពការគ្រប់គ្រងប្រព័ន្ធកងល្បាតនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ គ្រឹះស្ថានសិក្សាឯកជន និងសហគមន៍។ ក្នុងឆ្នាំសិក្សា ២០២០-២០២១ សមាជិកកាយរឹទ្ធិជាតិកម្ពុជាមាន ១៧១ ១៣៥នាក់ ស្រី ៤៩ភាគរយ។

ក្រសួងបាន៖

- ផ្តល់គ្រឿងឥស្សរិយយស ៥ ០០០គ្រឿង ជូនកាយរឹទ្ធិជាតិកម្ពុជារាជធានី ខេត្ត ដើម្បីរៀបចំបញ្ចូលសមាជិកភាពនិងបំពាក់កន្សែងដល់នវកាយរឹទ្ធិប្អូន និងនវកាយរឹទ្ធិ
- ព្រាងប្រកាសស្តីពីការរៀបចំក្រុមប្រឹក្សាកាយរឹទ្ធិរៀមច្បង។

### *ការងារលើកកម្ពស់ការស្ម័គ្រចិត្ត និងការចូលរួមរបស់យុវជន*

ក្រសួងបាន៖

- បណ្តុះបណ្តាលកម្មវិធីស្តីពី "ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ឆ្នាំ២០២១" សម្រាប់យុវជនគ្រប់រាជធានី ខេត្ត មានអ្នកចូលរួម ៤៦៨នាក់ ស្រី ៤៧ភាគរយ តាមប្រព័ន្ធអនឡាញ

- រៀបចំសិក្ខាសាលាបណ្ដាញអ្នកនាំសារសន្តិភាពកាយរឹទ្ធិជាតិកម្ពុជា មានមន្ត្រីទទួលបន្ទុកការងារយុវជនចូលរួម ៥០នាក់ ស្រី ១៦ភាគរយ តាមប្រព័ន្ធអនឡាញ
- ចុះផ្សព្វផ្សាយអប់រំពីវិធីសាស្ត្រការពារជំងឺកូវីដ-១៩ ដល់សហគមន៍នៅរាជធានីភ្នំពេញ ខេត្តបន្ទាយ-មានជ័យ សៀមរាប ព្រះវិហារ ប៉ៃលិន កំពង់ស្ពឺ និងកំពង់ធំ មានយុវជនកាយរឹទ្ធិចូលរួម ១០០នាក់ ស្រី ៥០ភាគរយ
- ចុះសម្របសម្រួលយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកអប់រំនៅរាជធានីភ្នំពេញ មានមន្ត្រីទទួលបន្ទុកការងារកាយរឹទ្ធិចូលរួម ២១នាក់ ស្រី៤២,៨៥ភាគរយ។

***ការអប់រំសហគ្រិនភាព និងភាពជាអ្នកដឹកនាំ***

ក្រសួងបាន៖

- រៀបចំកម្មវិធី "យុវជន២១" ក្រោមប្រធានបទ "សហគ្រិនឌីជីថល" ក្រោមគំនិតផ្តួចផ្តើមរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានយុវជនចូលរួម ១១៩នាក់ ស្រី ៤៣ភាគរយ តាមប្រព័ន្ធអនឡាញ
- រៀបចំកម្មវិធីធុរកិច្ចជាតិសម្រាប់យុវជន មានគ្រូបង្គោល និងយុវជនចូលរួម ៤ ៦៤៧នាក់ ស្រី ៥០ភាគរយ។ ដំណើរការកម្មវិធីបែងចែកជា ៦ដំណាក់កាល ដូចជា៖ ១- វគ្គបំប៉នសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ ២- វគ្គបំប៉នសមត្ថភាពគ្រូបង្គោលថ្នាក់រាជធានី ខេត្ត ៣- ការបណ្តុះបណ្តាលយុវជនស្តីពីសហគ្រិនភាព និងការរៀបចំផែនការអាជីវកម្ម ៤-វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ៥-ជម្រុះយក ៥ក្រុមឆ្នើម ៦-ការប្រារព្ធទិវាសហគ្រិនភាពកម្ពុជា ការប្រកួតវគ្គផ្តាច់ព្រ័ត្រ និងទស្សនកិច្ចសិក្សា តាមប្រព័ន្ធអនឡាញ
- បណ្តុះបណ្តាលស្តីពីជំនាញទន់សម្រាប់យុវជន មានអ្នកចូលរួម ១០៨នាក់ ស្រី ៥១ភាគរយតាមប្រព័ន្ធអនឡាញ។

***ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញឌីជីថល និងជំនាញបច្ចេកទេសរយៈពេលខ្លី***

ក្រសួងបាន៖

- ដំណើរការ "កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត" មានសិស្សចុះឈ្មោះចូលរៀន ១១៦ នាក់ ស្រី ៣៩,៣៩ភាគរយ
- បណ្តុះបណ្តាលជំនាញខ្លីៗនៅមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា និងមជ្ឈមណ្ឌលយុវជនរាជធានី ខេត្តលើជំនាញខ្លីៗ ដូចជា៖ឧបករណ៍ភ្លេងព្យ៉ាណូ សិល្បៈរបាំបុរាណនិងប្រពៃណី ភ្លេងបុរាណ អក្សរភ្លេង ភ្លេងព្យុហយាត្រា តន្ត្រីសម័យ សម្អាងកាយ ភាសាអង់គ្លេស ភាសាកូរ៉េ តម្រង់ទិសមគ្គុទ្ទេសក៍ទេសចរណ៍ និងចំណេះដឹងមូលដ្ឋានងាយៗពីបុរាណវិទ្យា មូលដ្ឋានគ្រឹះគុនល្បុក្កតោ របៀបប្រើប្រាស់អ៊ីនធឺណិតនិងបណ្តាញទំនាក់ទំនងសង្គម កុំព្យូទ័ររដ្ឋបាល ការរចនានិងផលិត វីដេអូបង្រៀនពីចម្ងាយ សញ្ញាណដំបូងនៃស្ថាបត្យកម្ម AutoCad ការថែរក្សា និងដំឡើងកុំព្យូទ័រ មានយុវជន ចូលរួម ១ ០០៨នាក់ ស្រី ៥៨,២៣ភាគរយ។

### ការលើកកម្ពស់សុខភាព និងសុខុមាលភាពយុវជន

ក្រសួងបានផ្សព្វផ្សាយស្តីពី ការអប់រំសុខភាពផ្លូវចិត្តយុវជនក្នុងបរិបទជំងឺកូវីដ-១៩ តាមទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលទស្សនា ៥០៨ ០០០នាក់។

### ការប្រកួតប្រជែងសមត្ថភាពយុវជន

ក្រសួងបានរៀបចំ៖

- កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ មានយុវជនចូលរួម ៩៦នាក់ ស្រី ៦១ភាគរយ តាមប្រព័ន្ធអនឡាញ
- កម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ ក្រោមប្រធានបទ "ការអភិវឌ្ឍវិស័យអប់រំតាមបែបស្ទែម" មានយុវជនចូលរួម ១៩៣នាក់ ស្រី ៥២ភាគរយ និងគ្រូដឹកនាំ ២៤នាក់ ស្រី ៤០ភាគរយ តាមប្រព័ន្ធអនឡាញ
- កម្មវិធីប្រកួតប្រជែងផែនការអាជីវកម្មតាមទម្រង់ឌីជីថល មានឈ្មោះថា "អាជីវកម្មខ្ញុំ" មានយុវជនចូលរួម ១២០នាក់ ស្រី ៦១,៦៦ភាគរយ តាមប្រព័ន្ធអនឡាញ។

### ការបោះជំរំ និងទស្សនកិច្ចសិក្សា

ក្រសួងបានរៀបចំ៖

- បោះជំរំយុវជនជាសកលលើកទី៧ តាមទម្រង់ឌីជីថល ក្រោមប្រធានបទ "យុវជនក្នុងបរិបទឌីជីថល" មានយុវជន និងអ្នកស្ម័គ្រចិត្តចូលរួម ១៥៣នាក់ ស្រី ៥១ភាគរយ តាមប្រព័ន្ធអនឡាញ
- បោះជំរំកាយរឹទ្ធិ ក្រោមប្រធានបទ "ចុងភៅឯក" មានយុវជនចូលរួម ៨៤នាក់ ស្រី ៤៦ភាគរយ តាមប្រព័ន្ធអនឡាញ
- បោះជំរំតាមប្រព័ន្ធរលកធាតុអាកាសលើកទី៦៤ និងតាមអ៊ីនធឺណិតលើកទី២៥ (JOTA-JOTI) ក្រោមប្រធានបទ "តោះ..! វិលត្រឡប់មកចលនាកាយរឹទ្ធិវិញ" មានយុវជនចូលរួម ៧០នាក់ ស្រី ៥៨ភាគរយ តាមប្រព័ន្ធអនឡាញ
- បោះជំរំកាយរឹទ្ធិថ្នាក់ជាតិលើកទី៤ ក្រោមប្រធានបទ "កាយរឹទ្ធិនិងសុវត្ថិភាពចំណីអាហារ" មានយុវជនចូលរួម ៤០០នាក់ ស្រី ២៨ភាគរយ តាមប្រព័ន្ធអនឡាញ។

### ការផ្សព្វផ្សាយសកម្មភាពកិច្ចការយុវជន

ក្រសួងបានផលិតវីដេអូសកម្មភាព និងផ្សាយបន្តផ្ទាល់កម្មវិធីប្រកួតប្រជែងរបស់យុវជន តាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចជា "ការជជែកដេញដោលយុវជនថ្នាក់ជាតិ" "យុវជន២១" "ការប្រកួតប្រជែងផែនការអាជីវកម្ម" និង "ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ" មានអ្នកចូលទស្សនាប្រមាណជាង ៤៥០ ០០០នាក់។

### ការពង្រឹងសមាគមនិស្សិត

គ្រប់សាកលវិទ្យាល័យសាធារណៈ បានពង្រឹងកិច្ចសហប្រតិបត្តិការ ទំនាក់ទំនង រៀបចំបង្កើតកែលម្អរចនាសម្ព័ន្ធ និងពង្រឹងតួនាទីសមាគមនិស្សិត សម្រាប់បម្រើសកម្មភាពមនុស្សធម៌ សណ្តាប់ធ្នាប់ និងការសិក្សាស្រាវជ្រាវរបស់និស្សិត។ ដោយឡែកឆ្នាំសិក្សា២០២០-២០២១ កន្លងមកនេះ សាកល-

វិទ្យាល័យជាតិមានជ័យ សាកលវិទ្យាល័យជាតិបាត់ដំបង និងសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ក៏បានរៀបចំដំណើរការសកម្មភាពនេះផងដែរ។

### *ការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ*

ក្រសួងបាន៖

- រៀបចំអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាងឌីពើរតួននៃប្រទេសព្រុយណេដារូសាឡឹម ស្តីពីកិច្ចសហប្រតិបត្តិការយុវជន
- រៀបចំអនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសមភាពយេនឌ័រ និងគ្រួសារនៃសាធារណរដ្ឋកូរ៉េ ស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងវិស័យយុវជន
- ព្រាងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃរបស់អនុវិស័យការអភិវឌ្ឍយុវជន សហការជាមួយអង្គការ EWMI និងនាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ
- បណ្តុះបណ្តាលគ្រូសម្របសម្រួលកម្មវិធីធុរកិច្ចជាតិសម្រាប់យុវជន សហការជាមួយអង្គការអន្តរជាតិការងារ
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍដូចជា UNESCO, UNFPA, UNV, VSO, DVV International, IYF, World Vision, KE, ILO, YEAC, KOICA & BOOKBRIDGE Foundation។

### *ការផ្លាស់ប្តូរទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ*

ក្រសួងបាន៖

- បញ្ជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូយុវជន ១៥៦នាក់ ស្រី ៤៣ភាគរយ ដើម្បីចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនលើកទី១១ និងកិច្ចប្រជុំឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនអាស៊ានបូក៣លើកទី១០ ពិធីសម្ពោធរបាយការណ៍សន្ទស្សន៍ការអភិវឌ្ឍយុវជនអាស៊ានដំណាក់កាលទី២៖ ការស្វែងយល់ពីរបៀបដែលយុវជនមើលឃើញអាស៊ាន ការយល់ដឹង តម្លៃ និងអត្តសញ្ញាណ កិច្ចប្រជុំនិមិត្តអនុម័តផែនការសកម្មភាពយុវជនអាស៊ាន ឆ្នាំ២០២១-២០២៥ កម្មវិធីដាំដើមឈើសាមគ្គីយុវជនអាស៊ីអឺរ៉ុបនៃកម្មវិធី ASEFYLS4 របស់ ASEM កិច្ចប្រជុំប្រមូលទិន្នន័យដើម្បីអភិវឌ្ឍការសិក្សារួមគ្នាស្តីពីនគរូបនីយកម្ម ការកៀរគរមនុស្ស និងការអភិវឌ្ឍប្រកបដោយបរិយាបន្នទាំងក្នុងតំបន់ជនបទ-ទីក្រុងរបស់អាស៊ាន វេទិកាយុវជនអាស៊ានលើកទី១១ កម្មវិធីអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអំពីទិន្នន័យអាស៊ាន កម្មវិធីបោះជំរំស្ពានរជូវក្តៅ សន្និសីទសហព័ន្ធក្រុមប្រឹក្សានិស្សិតសាកលវិទ្យាល័យអាស៊ានលើកទី៥ កម្មវិធីអ្នកដឹកនាំយុវជនអាស៊ី កម្មវិធីបោះជំរំរដូវក្តៅ កម្មវិធីផ្លាស់ប្តូរអ្នកការទូតវ័យក្មេងអាស៊ានលើកទី២ កម្មវិធីពានរង្វាន់យើងរួមគ្នា កម្មវិធីភាពជាអ្នកដឹកនាំវ័យក្មេង កម្មវិធីការផ្លាស់ប្តូរទំនាក់ទំនងយុវជនអាស៊ីបូព៌ា និងជប៉ុន កិច្ចប្រជុំនិមិត្តនៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍និងជប៉ុនលើកទី៤៧ ឆ្នាំ២០២១ កម្មវិធីការផ្លាស់ប្តូរទំនាក់ទំនងយុវជនកូរ៉េ-កម្ពុជា២០២១ កម្មវិធីវេទិកាសន្តិសុខនយោបាយយុវជនអាស៊ាន-កូរ៉េ សន្និសីទអ្នកវិទ្យាសាស្ត្រវ័យក្មេងអាស៊ានតាមប្រព័ន្ធអនឡាញឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ

- បញ្ជូនមេដឹកនាំកាយរឹទ្ធិ និងកាយរឹទ្ធិរៀមច្បង ៣៦នាក់ ស្រី ១៩ភាគរយ ចូលរួមកិច្ចប្រជុំមេដឹកនាំកាយរឹទ្ធិថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក សន្និសីទកាយរឹទ្ធិពិភពលោកលើកទី៤២ និងវេទិកាយុវជនកាយរឹទ្ធិពិភពលោកលើកទី១៤ តាមប្រព័ន្ធអនឡាញ។

**ការអប់រំកាយ និងកីឡា ៖**

*ការប្រកួតកីឡាសហព័ន្ធ*

ក្រសួងបានសហការជាមួយសហព័ន្ធកីឡាជាតិរៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ជាតិឆ្នាំ ២០២១ នៅ ៖

- រាជធានីភ្នំពេញ៖ កីឡាវាយកូនគោល កីឡាករ ១៦នាក់ ស្រីគ្មាន កីឡារាំ កីឡាករ ៣៨នាក់ ស្រី ២០នាក់ កីឡាតេក្វាន់ដូដាប់ប៊ែលយូធី កីឡាករ ៩៦នាក់ ស្រី ៤២នាក់ កីឡាអុកចត្រង្គ កីឡាករ ៦៦នាក់ ស្រីគ្មាន កីឡា សូហ្វតិន្និស កីឡាករ ៥៧នាក់ ស្រី ២៣នាក់ កីឡាប្រដាល់សកល កីឡាករ ៨៥នាក់ ស្រី ៤នាក់ កីឡាស៊ូវីនហ្វិកាំប៉ូ កីឡាករ ៣៤នាក់ ស្រី ១២នាក់ កីឡាវ៉ូវីណាម កីឡាករ ៥៨នាក់ ស្រី ២៣នាក់ កីឡា តេក្វាន់ដូអាយធីអេហ្វ កីឡាករ ១៣២នាក់ ស្រី ៤៦នាក់ កីឡាចំបាប់ កីឡាករ ៣៥នាក់ ស្រី ១០នាក់ ការប្រកួតកីឡាបាល់ទាត់លីគស្ត្រីហ្វូមអឺវ៉េ កីឡាការិនី ២០០នាក់ ជើងឯកប្រដាល់គុនខ្មែរ កីឡាករ១២៨នាក់ ស្រី ១១នាក់ កីឡាបាញ់កាំភ្លើងកីឡាករ ៣២នាក់ ស្រី ៩នាក់ កីឡាគុនដាវ កីឡាករ ៤៨នាក់ ស្រី ៦នាក់ កីឡាបាល់បោះ កីឡាករ ១២០នាក់ ស្រី ៣៥នាក់ កីឡាការ៉ាតេ កីឡាករ ១០៥នាក់ ស្រី ៤៨នាក់ និងកីឡាវាយកូនបាល់ កីឡាករ ៥៧នាក់ ស្រី ៦នាក់
- ខេត្តកែប៖ កីឡាទ្រីយ៉ាត្លុង កីឡាករ ៥៨នាក់ ស្រី ១៥នាក់
- ខេត្តកណ្ដាល៖ កីឡាស៊ីដក់ និងឈិនឡូន កីឡាករ ៦៦នាក់ ស្រី ១៨នាក់ កីឡាទាញព្រ័ត្រ កីឡាករ ៨១នាក់ ស្រី ៣៥នាក់
- ខេត្តកំពង់ឆ្នាំង៖ កីឡាកាយសម្ព័ន្ធ កីឡាករ ៦៤នាក់ ស្រី ៣០នាក់
- ខេត្តកំពង់ធំ៖ កីឡាបេស្បល កីឡាករ ៦៨នាក់ ស្រី ៥នាក់
- ខេត្តកំពត៖ កីឡាទូកកានូ និងរ៉ូអ៊ីង កីឡាករ ២៣២នាក់ ស្រី ៤៨នាក់
- ខេត្តបាត់ដំបង៖ កីឡាហែលទឹក កីឡាករ ១១២នាក់ ស្រី ៣៨នាក់
- ខេត្តសៀមរាប៖ កីឡាទោចក្រយាន កីឡាករ ២៥២នាក់ ស្រី ១៩នាក់ កីឡាយូដូ កីឡាករ ៦០នាក់ ស្រី ២១នាក់ កីឡាឡើងភ្នំ កីឡាករ ៨២នាក់ ស្រី ២០នាក់
- ខេត្តព្រះសីហនុ៖ កីឡាទូកក្ដោង កីឡាករ ២៦នាក់ ស្រី ១នាក់
- ខេត្តកំពង់ស្ពឺ៖ កីឡាជិះសេះរត់រយៈចម្ងាយឆ្ងាយ កីឡាករ ៦នាក់ ស្រី ២នាក់។

## *ការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេស*

ក្រសួងបាន៖

- ត្រៀមលក្ខណៈទាំងការងាររដ្ឋបាល បច្ចេកទេស និងគម្រោងថវិការួចរាល់ សម្រាប់រៀបចំការប្រកួតជើងឯកអាស៊ីអាគ្នេយ៍លើ ៤ប្រភេទកីឡា រួមមានកីឡាប្រដាល់គុនខ្មែរ ល្បុក្កតោ ការ៉ាតេ និងកីឡាបាល់បោះ ប៉ុន្តែដោយសារវិបត្តិកូវីដ-១៩ ការប្រកួតខាងលើត្រូវបានផ្អាក
- រៀបចំការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ឆ្នាំ២០២១ កីឡាទូកក្តោងនៅខេត្តព្រះសីហនុ មានប្រតិភូ និងកីឡាករ កីឡាការិនី ២៩នាក់ ស្រី ៣នាក់ មកពីប្រទេសសឹង្ហបុរី ម៉ាឡេស៊ី និងកម្ពុជា។ ការប្រកួតនេះកម្ពុជាទទួលបានមេដាយ ៨គ្រឿង ក្នុងនោះមេដាយមាស ១គ្រឿង មេដាយប្រាក់ ៤គ្រឿង និងមេដាយសំរឹទ្ធិ ៣គ្រឿង។

## *ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្រៅប្រទេស*

ក្រសួងបានបញ្ជូនប្រតិភូ គ្រូបង្វឹក និងកីឡាករ៖

- កីឡាតេក្វាន់ដូដាប់ប៊ែលយូធី ៤នាក់ ស្រី ១នាក់ ចូលរួមប្រកួតជម្រុះអូឡាំពិកនៅស៊ូដង់
- កីឡាតេក្វាន់ដូដាប់ប៊ែលយូធី ៥នាក់ ស្រី ៣នាក់ ចូលរួមប្រកួតជើងឯកបើកទូលាយតាមប្រព័ន្ធអនឡាញ វើលតេក្វាន់ដូអាស៊ីនៅកូរ៉េ
- កីឡាហែលទឹក និងអត្តពលកម្ម ១០នាក់ ស្រី ៣នាក់ ចូលរួមប្រកួតអូឡាំពិករដូវក្តៅលើកទី៣២ នៅជប៉ុន
- កីឡាម៉ូតូទឹក ៨នាក់ ស្រីគ្មាន ចូលរួមប្រកួតជើងឯកពិភពលោក នៅអ៊ីតាលី
- កីឡាប៉េតង់ ១២នាក់ ស្រី ៤នាក់ ចូលរួមប្រកួតជើងឯកពិភពលោកយុវជននិងស្ត្រី នៅអេស្ប៉ាញ
- កីឡាអាស៊ីប៉ារ៉ាហ្គេមយុវជនលើកទី៤ ចំនួន ២នាក់ ស្រីគ្មាន ចូលរួមប្រកួត នៅបារ៉ែន
- កីឡាទូករ៉ូអ៊ីង ១០នាក់ ស្រី ២នាក់ ប្រកួតជ្រើសរើសជើងឯកអាស៊ី ២០២១ នៅថៃ
- កីឡាហែលទឹក (ទីខ្លីអាងហែលទឹក ២៥ម៉ែត្រ) ៥នាក់ ស្រី ២នាក់ ប្រកួតជ្រើសរើសជើងឯកពិភពលោក នៅអារ៉ាប់រួម
- កីឡាការ៉ាតេ ២៦នាក់ ស្រី ៩នាក់ ប្រកួតជើងឯកអាស៊ី នៅកាហ្សាក់ស្ថាន
- កីឡាវាយកូនគោល ២នាក់ ស្រីគ្មាន ប្រកួតជើងឯកអាស៊ីប៉ាស៊ីហ្វិច នៅអារ៉ាប់រួម។

## *ការគាំទ្រថវិការបស់ក្រសួងដល់សហព័ន្ធកីឡាជាតិ*

ក្រសួងបានផ្តល់ថវិកាគាំទ្រដល់សហព័ន្ធកីឡាជាតិ៤០ ដើម្បីពន្លឿនការអភិវឌ្ឍឆ្ពោះទៅឆ្នាំ២០២៣ រួមមានសហព័ន្ធខ្មែរអត្តពលកម្មស្ម័គ្រចិត្ត តេក្វាន់ដូដាប់ប៊ែលយូធី បាល់ទាត់ បាល់បោះ បាល់ទះ ការ៉ាតេប៊ូល និងប៉េតង់ វូស៊ូ ហែលទឹក វាយកូនបាល់ កាយសម្ព័ន្ធ វាយកូនគោល ចំបាប់ ប្រដាល់សកល ទូកកានូនិងរ៉ូអ៊ីង តេក្វាន់ដូអាយធីអែហ្វ យូដូ បាញ់កាំភ្លើង វាយកូនឃ្លីលើតុ គុនដាវ វាយសី សីដក់ អុកចត្រង្គ វ៉ូវីណាម ប្រដាល់គុនខ្មែរ ល្បុក្កតោ សូហ្វតិន្នីសទ្រើយ៉ាត្លុង ម៉ូតូទឹក ឡើងភ្នំ ទូកក្តោង បាល់ឱប ស្វីនហ្វ៊ិកកាំប៉ូ ទាញព្រ័ត្រ គុងហ្វីលម៉ូដូ បេស្បល បង្ហាត់ជិះសេះ ទោចក្រយាន គណៈកម្មាធិការប៉ារ៉ាឡាំពិកកម្ពុជា និងសហព័ន្ធកីឡាសិស្ស-និស្សិតកម្ពុជា។

### *ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា*

ក្រសួងបាន៖

- ផ្តល់ទីតាំងពហុកីឡដ្ឋានជាតិជូនគណៈកម្មការប្រយុទ្ធជំងឺកូវីដ-១៩ ប្រើប្រាស់ព្យាបាលអ្នកកើតជំងឺកូវីដ-១៩ និងសហការសម្របសម្រួលលើប្រព័ន្ធទឹក អគ្គិសនី
- ថែទាំអាងហែលទឹក សួនស្មៅ និងផ្កា ក្នុងពហុកីឡដ្ឋានជាតិ
- ស្តារប្រព័ន្ធលូ នៅក្នុងពហុកីឡដ្ឋានជាតិ សហការជាមួយសាលារាជធានីភ្នំពេញ
- បញ្ចប់ការសាងសង់ផ្លូវរត់អត្តពលកម្ម ៨ខ្សែបន្ទាត់ ជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ប្រជាជនជប៉ុន ក្នុងគម្រោងគូសាណូណិ តាមរយៈអង្គការបេះដូងមាស
- បញ្ចប់ការសាងសង់អគារធ្វើលំហាត់ប្រាណដោយមានបំពាក់សម្ភារបរិក្ខារ និងបរិវេណជុំវិញអាងហែលទឹក ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន ប្រជាជនជប៉ុន តាមរយៈអង្គការបេះដូងមាស
- បញ្ចប់ការជួសជុលកែលម្អទីលានលោតចម្ងាយឡើងវិញ
- ជួសជុលកែលម្អអគារមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- ជួសជុលក្លោងទ្វារចូលច្រកខាងកើតនៃវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា
- ជួសជុល និងថែទាំទីលានកីឡាបាល់ទាត់ ៨ សាលាតម្រង់ទិសវិទ្យាល័យ ១ ទីលានកីឡាបាល់ទាត់ ១ នៅខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ចាម តាកែវ ព្រៃវែង កណ្តាល និងរាជធានីភ្នំពេញ
- តបណ្តាញខ្សែកាបអុបទិកក្រោមដី នៅក្នុងពហុកីឡដ្ឋានជាតិ សហការជាមួយអគ្គិសនីកម្ពុជា
- តបណ្តាញទឹកនៅក្នុងពហុកីឡដ្ឋានជាតិ សហការជាមួយរដ្ឋាករទឹកស្វយ័តកម្ពុជា
- តបណ្តាញទឹក អគ្គិសនី និងម៉ាស៊ីនបោកគក់នៅអគារស្នាក់នៅរបស់អត្តពលិកក្នុងពហុកីឡដ្ឋានជាតិមរតកតេជោ
- តបណ្តាញអគ្គិសនី និងកែលម្អបន្ទប់អនាម័យឡើងវិញអគាររដ្ឋបាល នាយកដ្ឋានរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា
- បំពាក់សម្ភារ និងបរិក្ខារការិយាល័យនៅនាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា មជ្ឈមណ្ឌល-ជាតិព័ត៌មានវិទ្យានិងស្ថិតិកីឡា ជាជំនួយឧបត្ថម្ភរបស់ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការទទួលបន្ទុក។

វឌ្ឍនភាពរយៈពេលមួយឆ្នាំកន្លងមកនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ មានដូចខាងក្រោម៖ គឺ (១) **ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន** (២) **ការពិនិត្យឡើងពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន** (៣)**ការដាក់ឱ្យអនុវត្តអធិការកិច្ច** (៤) **ការពង្រឹងវង្វាយតម្លៃការសិក្សា** និង (៥) **ការកែទម្រង់ឧត្តមសិក្សា។**

## *សសរស្តម្ភទី១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន*

### *កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន*

- ការអនុម័តនិងដាក់ឱ្យប្រើប្រាស់សាកល្បងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ១២+២ តាមប្រព័ន្ធក្រេឌីត

- ការបញ្ចូលកញ្ចប់អំណានដំបូងនិងគណិតវិទ្យាថ្នាក់ដំបូងក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា
- ការអនុម័តក្របខណ្ឌកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញាបត្រ+២
- ការអនុវត្តការរៀន និងបង្រៀននៅតាមគ្រឹះស្ថានសិក្សាតាមប្រព័ន្ធអនឡាញ ការបណ្ដុះបណ្ដាលនាយកសាលាតាមប្រព័ន្ធអនឡាញ និងការសរសេរនិក្ខេបបទស្រាវជ្រាវ ដើម្បីឆ្លុះបញ្ចាំងពីសមត្ថភាពការប្រើប្រាស់បច្ចេកវិទ្យា និងការសិក្សាក្នុងបរិបទកូវីដ-១៩
- ការអនុម័តលើសៀវភៅណែនាំស្ដីពី ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។

## ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងគុណភាពគ្រូឧទ្ទេស

- ការអនុម័តលើគោលការណ៍អនុញ្ញាតយន្តការនៃការអនុវត្តកម្មវិធីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ ថ្នាក់ជាតិ អន្តរជាតិ ដើម្បីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
- ការលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ទទួលបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន
- ការលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ទទួលបរិញ្ញាបត្រជាន់ខ្ពស់អប់រំនៅប្រទេសអូស្ត្រាលី
- ការចុះកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ស្ដីពីគម្រោងលើកកម្ពស់សមត្ថភាពការអប់រំបច្ចេកវិទ្យាព័ត៌មាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្ត និងសាលាមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា
- ការលើកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រង
- ការលើកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាមត្តេយ្យមជ្ឈិមទទួលបរិញ្ញាបត្រជាន់ខ្ពស់អប់រំ កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ការអនុវត្តការលើកកម្ពស់សមត្ថភាពគណៈគ្រប់គ្រង និងគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សហការជាមួយអង្គការយូនីសេហ្វ
- ក្របខណ្ឌគោលនយោបាយគន្លងអាជីពបានកែសម្រួល និងបានអនុម័តដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ និងកំពុងអនុវត្តសាកល្បងទៅលើនាយក សាលារៀន ២១ រូប និង គ្រូបង្រៀន ៨០ រូប ដែលបានជ្រើសរើសជានាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ដោយបានទទួលស្គាល់ទៅក្នុងគន្លងអាជីពចាប់តាំងពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២
- ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានអនុម័ត ដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។ ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានឯកសារគាំទ្រអនុវត្ត រួមមាន៖ គោលនយោបាយ, ផែនការសកម្មភាព, ឯកសារប្រតិបត្តិ, ប្រព័ន្ធ

ផ្តល់ក្រេឌីត។ ប្រព័ន្ធទិន្នន័យកត់ត្រាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្សារភ្ជាប់នឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សបានរៀបចំ និងអនុវត្តសាកល្បងនៅខែតុលា ឆ្នាំ២០២១ និងបានដាក់ឱ្យអនុវត្តជាផ្លូវការជាមួយនឹងប្រព័ន្ធទូរស័ព្ទដៃនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២ ដែលអាចចូលបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់គ្រងដោយ «ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ» នៃនាយកដ្ឋានបុគ្គលិក

- ការផ្សព្វផ្សាយការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងសៀវភៅណែនាំការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងធនធានមនុស្សជូនសាលាបឋមសិក្សា

## ការកែលម្អធនធានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធ

- ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
- ការបំពាក់សម្ភារបច្ចេកវិទ្យាព័ត៌មានសម្រាប់ការរៀន និងបង្រៀន នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- ការផ្តល់កុំព្យូទ័របន្ទះស៊ីមកាត និងផ្តល់ទិន្នន័យ សម្រាប់គាំទ្រការរៀន និងបង្រៀនតាមសាលាគរុកោសល្យ និងវិក្រឹតការខេត្ត
- ការផ្តល់អាហារូបករណ៍ដល់គរុសិស្ស ៣០នាក់ ក្នុង ១សាលា ១០នាក់ នៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តស្វាយរៀង កំពង់ធំ និងព្រៃវែង(២៥ ដុល្លាអាមេរិក)
- ការផ្តល់អាហារូបករណ៍ដល់គរុសិស្សមានដើមកំណើតជាជនជាតិដើមភាគតិច កំពុងបណ្តុះបណ្តាលនៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តក្រចេះ ព្រះវិហារ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ៥១នាក់ ស្រី ២៧នាក់។

## ភាពជាអ្នកដឹកនាំ

- ការចងក្រងសៀវភៅបទពិសោធន៍នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន
- ការផ្តល់ឱកាសជូននាយកសាលាបំពេញការងារល្អបានអភិវឌ្ឍសមត្ថភាព តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## ការផ្សារភ្ជាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសាលាអនុវត្តន៍

- ការអនុម័តសេចក្តីណែនាំស្តីពី កម្មសិក្សាគរុកោសល្យសម្រាប់ការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តមបរិញ្ញាបត្រ+២
- ការរៀបចំឧបករណ៍សម្រាប់វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្សារភ្ជាប់គ្នារវាងគ្រូបង្រៀនល្អ នាយកល្អ និងសាលារៀនល្អ
- ការរៀបចំគោលការណ៍ នីតិវិធី និងវិធីសាស្ត្រវាយតម្លៃគរុសិស្ស គរុនិស្សិត ដោយផ្តោតលើលទ្ធផលសិក្សា
- ការជំរុញការអនុវត្តកម្មសិក្សាគរុកោសល្យបែបចម្រុះ (ផ្ទាល់ និងតាមប្រព័ន្ធអនឡាញ) សម្រាប់គរុសិស្ស គរុនិស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូឆ្លើយតបទៅនឹងបរិបទកូវីដ-១៩។

### ការធានាគុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ការអនុម័តលើគោលការណ៍អនុញ្ញាតផ្តល់ឋានៈជាគ្រូឧទ្ទេស និងគ្រូឧទ្ទេសរង ជូនបុគ្គលិកអប់រំ ៤០នាក់ ស្រី១៤នាក់ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
- ការអនុម័តស្តង់ដាគ្រូឧទ្ទេសសម្រាប់វិទ្យាស្ថានគរុកោសល្យ។

### *សសរស្តម្ភទី២ ៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា*

### *ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល*

### ការពិនិត្យឡើងវិញកម្មវិធីសិក្សា

- ការពិនិត្យឡើងវិញកម្មវិធីសិក្សាបង្រួញផ្នែកភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម
- ការបង្កើត និងកែសម្រួលកម្មវិធីសិក្សាដែលមានស្រាប់ឱ្យឆ្លើយតបទៅនឹងបរិបទអប់រំ រួមមាន ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស (២០១៨) កម្មវិធីអប់រំស្វែម ការអភិវឌ្ឍកម្មវិធីសិក្សាជំនាញ Media Design and App Design
- ការបង្កើតកម្មវិធី (App) STEM Network Training Center វិធីសាស្ត្របង្រៀនតាមប្រព័ន្ធអនឡាញ (ឯកសារ មគ្គុទេសក៍បង្រៀនតាមវិធីសាស្ត្រថ្មី) ផ្តោតលើវិធីសាស្ត្របង្រៀនតាមបែបបញ្ញត្តិស្ថាបនានិយម
- ការកែលម្អកម្មវិធីសិក្សាលម្អិតមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ ភាសាខ្មែរ និងសិក្សាសង្គម
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីនាយកដ្ឋានស្តីពី ការអភិវឌ្ឍកម្មវិធីសិក្សាបែបបញ្ញត្តិ និងការអភិវឌ្ឍឯកសារកម្រិតសមត្ថភាពសិស្សថ្នាក់ទី៩
- ការអភិវឌ្ឍឯកសារកម្រិតសមត្ថភាពរបស់សិស្សថ្នាក់ទី៩ មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីបរិស្ថានវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា និងគេហសេដ្ឋកិច្ចវិទ្យា។

### ការរៀបចំឯកសារ និងសៀវភៅសិក្សាគោល

- ការអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាសិល្បៈថ្នាក់ទី១ ទី២ ទី៣ សម្រេចបាន ១០០ភាគរយ និង អភិវឌ្ឍសេចក្តីព្រាងលើកទី១ ថ្នាក់ទី៤ ទី៥ និងទី៦ សម្រេចបាន ១០០ភាគរយ
- ការអភិវឌ្ឍឯកសារគំរូដំណើរការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន
- ការអភិវឌ្ឍសៀវភៅ «បរិស្ថាន និងអប់រំការប្រែប្រួលអាកាសធាតុ» សម្រាប់គ្រូ និងសិស្សកម្រិតបឋមសិក្សាថ្នាក់ ទី៤ ទី៥ និងថ្នាក់ទី៦
- ការកែលម្អសៀវភៅសិក្សាគោលមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គមព្រមទាំងអភិវឌ្ឍ សៀវភៅអំណានបន្ថែម សៀវភៅហ្វឹកហាត់ និងសម្ភារឧបទេសមួយចំនួន
- ការពង្រឹងការចុះឈ្មោះសាលារៀនក្នុងប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោល
- ការពង្រឹងយន្តការរៀបចំបញ្ជីតម្រូវការ បញ្ជីបែងចែកសៀវភៅសិក្សាគោលឱ្យត្រូវតាមការស្នើសុំរបស់សាលារៀននិងការផ្គត់ផ្គង់ឱ្យទាន់ពេលវេលា
- ការបោះពុម្ពឯកសារទេសចរណ៍ថ្នាក់ទី១១ ចំនួន ៣០ ០០០ ក្បាល
- ការបោះពុម្ពសៀវភៅ ១៧៧ចំណងជើង ត្រូវជា ៣ ១២១ ៤២០ច្បាប់ ស្មើ ៦៨១ ៦២០ ៦៨០ទំព័រ

- ការអភិវឌ្ឍ និងអនុវត្តសាកល្បង «ប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោល» សហការជាមួយ អង្គការ អប់រំពិភពលោក
- ការផ្គត់ផ្គង់សៀវភៅសិក្សាគោល ៥ ០៧៦ ៨៣០ ច្បាប់ ក្នុងនោះបឋមសិក្សា ៣ ៣៨០ ៥៤៤ ច្បាប់ មធ្យមសិក្សាបឋមភូមិ ៩២២ ២២៤ច្បាប់ និងមធ្យមសិក្សាទុតិយភូមិ ៧៧៤ ០៦២ច្បាប់
- ការបញ្ចូលទិន្នន័យសៀវភៅក្នុងតារាងបែងចែកសៀវភៅសិក្សាគោលសម្រាប់ឆ្នាំសិក្សា២០២១-២០២២ ចំនួន ៩ ០៨៥ /៩ ០៨៥ សាលា ស្មើ ១០០ភាគរយ
- ការបញ្ចប់ការដឹកជញ្ជូនសៀវភៅសិក្សាគោល PB-២០២១ ជូនរាជធានី ខេត្ត វគ្គ១ និងវគ្គ២ បាន គ្រប់រាជធានី ខេត្ត ស្មើ ១ ២១៥ ០០០ច្បាប់ សម្រេចបាន ១០០ ភាគរយ។

## ការរៀបចំសេចក្តីណែនាំ និងវិធីសាស្ត្របង្រៀន

- ការរៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន និងបោះពុម្ព បែងចែក។

## *ការកែលម្អបរិស្ថានសិក្សា*

## គម្រោងថវិកាជាតិរដ្ឋាភិបាល

- ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
- ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- ការជួសជុលកែលម្អអគារសិក្សាវិទ្យាល័យអនុវត្តន៍ ២ជាន់ ស្មើ ៨បន្ទប់ ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ
- ក្នុងឆ្នាំ២០២១ គម្រោងសាងសង់ដោយសហគមន៍បានរៀបចំឡើង ដោយមានឯកសារប្រតិបត្តិ សំណង់សហគមន៍បានអនុម័តនៅខែកក្កដា ឆ្នាំ២០២១។ គណៈកម្មការវាយតម្លៃសំណង់សិក្សា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានកំណត់អាទិភាពនៅខែមីនា ឆ្នាំ២០២០ ស្រប ទៅនឹងលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ជ្រើសរើសការសាងសង់ និងជួសជុលផ្អែកលើទិន្នន័យ ពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។ អាទិភាពបានកំណត់ផ្តោតលើសាលារៀនមានសិស្សច្រើនលើសលប់, សាលារៀនមិនគ្រប់កម្រិតថ្នាក់ សាលារៀននៅដាច់ស្រយាល សាលារៀនមានបញ្ហាទឹក និងអនាម័យ។ គណៈកម្មការបានអនុម័តអាទិភាពនៃការសាងសង់អគារសិក្សា ៥០ខ្នង មានទឹកប្រាក់ ១៥ ៦៤០ លានរៀល នៅខែមីនា ឆ្នាំ២០២១ និង ១០០ខ្នងផ្សេងទៀត មានទឹកប្រាក់ ៣៣ ៧៥១,២ លានរៀល នៅខែវិច្ឆិកា ឆ្នាំ២០២១
- ការសាងសង់អគារសិក្សាសាលាបឋមសិក្សា ១៩ខ្នង ស្មើ ១២៧បន្ទប់ ទីចាត់ការ ៥ខ្នង ស្មើ ២៥ បន្ទប់ អគារសិក្សាអនុវិទ្យាល័យ ៦ខ្នង ស្មើ ៤៩បន្ទប់ និងបណ្ណាល័យ ១ខ្នង និងអគារសិក្សា វិទ្យាល័យ ២ខ្នង ស្មើ ១៥បន្ទប់ នៅខេត្តកណ្តាល កំពង់ចាម កំពត រតនគិរី ព្រៃវែង ស្វាយរៀង និងរាជធានីភ្នំពេញ
- ចំនួនសាលារៀនគ្រប់កម្រិតសិក្សាមានស្តង់ដាអប្បបរមាទឹកស្អាត និងអនាម័យចំណាត់ថ្នាក់ «កម្រិត សូន្យ» បានថយចុះពី ២ ៥០៩សាលា (២៧ភាគរយ) នៅឆ្នាំសិក្សា ២០១៩-២០២០ មកត្រឹម ២ ០៦៨សាលា (២២,២ភាគរយ) នៅឆ្នាំសិក្សា២០២០-២០២១ និង ១ ៦៥៥សាលា (១៧,៧ ភាគរយ) នៅឆ្នាំសិក្សា ២០២១-២០២២។

## គម្រោងថវិកាក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ

- ការសង់បណ្ណាល័យថ្មី **សម្តេចព្រះសង្ឃរាជ ជួន ណាត** (USESDP-II)
- ការជួសជុលអគារសិក្សាវិទ្យាល័យធនធាន ៥០ទីតាំង ស្មើ ១០០បន្ទប់ សម្រាប់ធ្វើបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ(USESDP-II)
- ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានជាតិអប់រំ រួមមានៈ អគារសិក្សា ១ខ្នង ៣ជាន់ ស្មើ ១៥បន្ទប់អគារ E ១ជាន់ ស្មើ ៣បន្ទប់ អគារសិក្សា ៩ខ្នង ស្មើ ៤៤បន្ទប់ បង្គន់អនាម័យ ២ខ្នង ស្មើ ១៦បន្ទប់ សាងសង់ខ្លោងទ្វារ១ រចនាប្លង់គោល រៀបចំប្រព័ន្ធលូទឹក ផ្លូវបេតុង សួនច្បារ របងវិទ្យាស្ថាន (USESDP-II)
- ការជួសជុលអគារធនធាន ៣៦ទីតាំង បន្ទប់ពិសោធន៍ ២បន្ទប់ បណ្ណាល័យ ១បន្ទប់ បន្ទប់កុំព្យូទ័រ ២បន្ទប់ សម្រេចបាន ១០,១៥ភាគរយ (USESDP-II)
- ការជួសជុលបន្ទប់ពហុបំណង ២៥បន្ទប់ សម្រេចបាន ៨៧ភាគរយ (USESDP-II)
- ការជួសជុលបន្ទប់ទឹក និងកន្លែងលាងដៃអគារធនធាន ១៨ទីតាំង (USESDP-II)
- ការដំឡើងថាមពលដើរដោយពន្លឺព្រះអាទិត្យ ៥០ទីតាំង (វិទ្យាល័យធនធាន ២០ទីតាំង និងវិទ្យាល័យបណ្តាញ ៣០ទីតាំង) (USESDP-II)
- ការជួសជុលអគារសិក្សានៃវិទ្យាល័យបណ្តាញ ៨៧ទីតាំង បណ្ណាល័យ ៨៧បន្ទប់ និងបន្ទប់ពិសោធន៍ ៨៧បន្ទប់
- ការជួសជុលអគារសិក្សាសាលាបឋមសិក្សា ២ខ្នង ៨បន្ទប់ និងជួសជុលអន្តេវាសិកដ្ឋានក្នុងវិទ្យាល័យ ៣ខ្នង ៥៤បន្ទប់ នៅខេត្តកណ្តាល (USESDP-II)
- ការកែលម្អបណ្ណាល័យឱ្យស្របតាមស្តង់ដាបណ្ណាល័យសតវត្សរ៍ទី២១
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ១១ រួមមានខេត្តកំពត កំពង់ធំ បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង ក្រចេះ ស្ទឹងត្រែង ព្រះវិហារ ស្វាយរៀង កំពង់ស្ពឺ និងព្រះសីហនុ (GPE3/STEPCam)
- ការសាងសង់អគារសិក្សាថ្មី ៤ខ្នង ស្មើ ២០បន្ទប់ នៅខេត្តកណ្តាល, ១ខ្នង ស្មើ ៥បន្ទប់ នៅខេត្តមណ្ឌលគិរី ២ខ្នង ស្មើ ១០បន្ទប់ នៅខេត្តរតនគិរី ៥ខ្នង ស្មើ ២៥បន្ទប់ នៅខេត្តត្បូងឃ្មុំ ៣ខ្នង ស្មើ ១៥បន្ទប់ នៅខេត្តស្វាយរៀង ១ខ្នង ស្មើ ៥បន្ទប់ នៅខេត្តព្រះវិហារ ១ខ្នង ស្មើ ៥បន្ទប់ និងអគារផ្ទះសំណាក់គ្រូ នៅខេត្តកំពង់ឆ្នាំង
- ការសាងសង់អគារមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ១ខ្នង អន្តេវាសិកដ្ឋាន ១ខ្នង ជួសជុលបន្ទប់ពិសោធន៍ និងកំពុងសាងសង់អគាររោងជាងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (HEIP)
- ការសាងសង់អន្តេវាសិកដ្ឋាន ១ខ្នង អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលពន្លកអាជីវកម្ម ជួសជុលបន្ទប់ពិសោធន៍ អគារ A និងអគារវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងសាងសង់រោងបន្លែ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (HEIP)

- ការសាងសង់អន្តេវាសិកដ្ឋាន ២ខ្នងសម្រាប់សិស្សស្រីនិងសិស្សប្រុស អគារពហុបំណង អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលពន្លកអាជីវកម្ម និងជួសជុលបន្ទប់ពិសោធន៍ ៤ រោងបន្លែ ១ខ្នង នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- ការសាងសង់អន្តេវាសិកដ្ឋាន ១ខ្នង អគារវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ១ខ្នង ជួសជុលបន្ទប់ពិសោធន៍ ៣បន្ទប់ ក្រាលការ៉ូឡាជុំវិញមាត់ស្រះ និងសាង់សង់រោងសន្តិសុខ ១ខ្នង នៅសាកលវិទ្យាល័យបាត់ដំបង (HEIP)
- ការសាងសង់អគារសិក្សាថ្មី ១ខ្នង អគាររោងជាង ១ខ្នង អគារភ្ញាស់វិជ្ជា ១ខ្នង សាងសង់របងរោងបន្លែ ទ្រុងជ្រូក ចាក់ដីនៅសាកលវិទ្យាល័យស្វាយរៀង និងសាងសង់អគារសិក្សា ១ខ្នង ២ជាន់ស្មើ ៨បន្ទប់ នៅស្ថានីយ៍កសិកម្មថ្មី (HEIP)
- ការសាងសង់អគារសិក្សា ២៣ខ្នង ស្មើ ២៩៩បន្ទប់ អគារធនធាន ១៧ខ្នង ស្មើ ២៥៥បន្ទប់ ផ្ទះសំណាក់គ្រូ ៥ខ្នង ស្មើ ១៥បន្ទប់ ផ្ទះសំណាក់សិស្ស ១ខ្នង ស្មើ ៤៨បន្ទប់ បង្គន់អនាម័យ ៣២ខ្នង ស្មើ ១៦០បន្ទប់ អណ្តូងទឹក ២៣ របងសាលារៀនប្រវែង ៦១០ម៉ែត្រ ផ្លូវបេតុងប្រវែង ៧៥០ម៉ែត តារាងបាល់បោះ ១៥កន្លែង និងតារាងបាល់ទាត់ ៨កន្លែង នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ចាម (China Aid)។

គិតមកត្រឹមថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ សំណង់អគារសិក្សា ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** មាន ៤ ៤៨៧ ខ្នង ស្មើនឹង ២៨ ៨១០ បន្ទប់។

### *សសរស្តម្ភទី៣ ៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធអធិការកិច្ច*

- ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំដែលមានដំណើរការល្អនៅសាលារៀន មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ។

### អធិការកិច្ចតាមប្រធានបទ

- ការផ្សព្វផ្សាយលទ្ធផលរបាយការណ៍អធិការកិច្ចតាមប្រធានបទ បានផ្តល់ព័ត៌មានត្រឡប់ដល់គ្រប់អ្នកពាក់ព័ន្ធបានទាន់ពេលដើម្បីចូលរួមកែលម្អដូចជាការគ្រប់គ្រង និងផ្គត់ផ្គង់សៀវភៅសិក្សាគោលនៅតាមសាលារៀន ការកែលម្អវិធីសាស្ត្របង្រៀនសំណេរ ការផ្តល់គ្រូបង្រៀនដល់សាលារៀនដែលមានតម្រូវការ
- ការធ្វើអធិការកិច្ចតាមប្រធានបទ ពីរប្រធានបទក្នុងមួយឆ្នាំសិក្សា ផ្នែកបឋមសិក្សាមួយប្រធានបទ និងផ្នែកមធ្យមសិក្សាមួយប្រធានបទ។ ប្រធានបទនីមួយៗផ្អែកលើរបាយការណ៍វង្វាយតម្លៃតេស្តថ្នាក់ជាតិ ថ្នាក់តំបន់ និងរបាយការណ៍អធិការកិច្ចតាមកាលកំណត់។

### អធិការកិច្ចតាមកាលកំណត់

- ការធ្វើអធិការកិច្ចតាមកាលកំណត់ ឆ្លើយតបទៅនឹងវដ្តនៃការធ្វើអធិការកិច្ចពី៣ ទៅ៥ ឆ្នាំឱ្យបានគ្រប់សាលារៀន

- ការធ្វើអធិការកិច្ចសាលារៀនតាមកាលកំណត់ ត្រូវបានផ្តល់លទ្ធផលរបាយការណ៍ដល់សាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ វិញក្រោយពេលធ្វើអធិការកិច្ចយ៉ាងយូរ ៣សប្តាហ៍ ដើម្បីមានវិធានការ និងកែលម្អទាន់ពេលវេលាចំពោះសាលារៀនដែលមានតម្រូវការ
- ក្រុមបំប៉ន និងពិនិត្យតាមដាននៃការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមត្ថភាពចុះពិនិត្យតាម និងវាយតម្លៃវឌ្ឍនភាពសាលារៀនផ្អែកលើអនុសាសន៍អធិការកិច្ចតាមកាលកំណត់ ប្រកប ដោយគុណភាព
- នាយកសាលារៀនមានសមត្ថភាពពេញលេញ ក្នុងការធ្វើស្វ័យវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក
- ការធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំអធិការកិច្ចតាមកាលកំណត់ និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការ
- ការធ្វើសុខដុមនីយកម្ម និងបច្ចុប្បន្នកម្មឧបករណ៍អធិការកិច្ចដែលមាននៅគ្រប់កម្រិត (សូចនាករសរុប ២៥)
- ការអនុម័តដាក់ឱ្យប្រើប្រាស់ផ្លូវការសៀវភៅជំនួយស្មារតីអធិការកិច្ចសាលារៀន
- ការពិនិត្យ និងកែលម្អឧបករណ៍ពិនិត្យតាមដានសាលារៀនក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩
- ការពិនិត្យឡើងវិញខ្លឹមសារសៀវភៅណែនាំការអនុវត្តប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត
- ការផ្សព្វផ្សាយសៀវភៅណែនាំការអនុវត្តប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត
- ការផ្សព្វផ្សាយប្រព័ន្ធអធិការកិច្ចសាលារៀនផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្នុងដល់គ្រប់អ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សកម្មភាពគាំទ្រផ្នែកអធិការកិច្ច

- ការបណ្តុះបណ្តាលមន្ត្រីអធិការអប់រំ ៥ជំនាន់ មាន ២៤៧នាក់
- ការបំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ចស្តីពីការវិភាគ និងការសរសេររបាយការណ៍អធិការកិច្ចប្រកដោយគុណភាព តាមរយៈការធ្វើអធិការកិច្ចជាក់ស្តែងនៅតាមសាលារៀន
- ការបំប៉នសមត្ថភាពអធិការអប់រំទាំង ២៥ ខេត្ត រាជធានី ស្តីពីការធ្វើតេស្តវង្វាយតម្លៃលទ្ធផលការសិក្សា
- ការបំប៉នសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិស្តីពី ការវិភាគនិងការសរសេររបាយការណ៍អធិការកិច្ចសាលា-រៀន ដើម្បីរៀបចំខ្លឹមសារ និងសម្ភារសម្រាប់បំប៉នបន្តដល់មន្ត្រីការិយាល័យអធិការកិច្ចតាមគន្លងទី២
- ការបំប៉នសមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌស្តីពី ការវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យសាលារៀន
- ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចក្នុងការជួយពង្រឹងការធ្វើតេស្តស្តង់ដាកម្រិតថ្នាក់រៀន និងពិនិត្យឧបករណ៍ពិនិត្យតាមដានតាម Google Form
- ការណែនាំ និងហ្វឹកហាត់ពីវិធីបញ្ចូលទិន្នន័យលទ្ធផលរបាយការណ៍អធិការកិច្ចតាមកាលកំណត់ និងរបាយការណ៍អធិការកិច្ចតាមអនឡាញក្នុងបរិបទកូវីដ-១៩ ដល់មន្ត្រីអធិការកិច្ចគ្រប់រាជធានី ខេត្ត

- ការពិនិត្យតាមដានការសិក្សារបស់សិស្សងាយរងគ្រោះក្នុងបរិបទជំងឺកូវីដ-១៩ តាមប្រព័ន្ធអនឡាញ ៤០៧សាលា ក្នុងនោះសាលាបឋមសិក្សា ២២៣ និងសាលាមធ្យមសិក្សា ១៨៤ សាលា និងចុះពិនិត្យសាលារៀនផ្ទាល់បាន ២០ សាលា ក្នុង ១០ ខេត្ត រាជធានី
- ក្រសួងមុខងារសាធារណៈគាំទ្រ បន្តការបណ្តុះបណ្តាលអធិការអប់រំ តាមលិខិតលេខ ៧៩១មស.ក្រខ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដើម្បីឆ្លើយតបតាមត្រូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

***សសរស្តម្ភទី៤ ៖ ការពង្រឹងវង្វាយតម្លៃសិក្សាមានរូបភាពផ្សេងៗដូចជា ការប្រឡង ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ***

**កិច្ចការប្រឡង**

- ការពង្រឹងការវាយតម្លៃការសិក្សារបស់សិស្សប្រចាំខែ និងប្រចាំឆមាស តាមរយៈការប្រឡងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ
- ការកសាងសមត្ថភាព និងធ្វើវិសហមជ្ឈការលើការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- ការកែលម្អគោលការណ៍ណែនាំ និងប្រព័ន្ធការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រឡងឱ្យកាន់តែមានប្រសិទ្ធភាព និងទំនើប
- ការរៀបចំសេចក្តីណែនាំស្តីពីស្តង់ដាវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- ការស្រង់ បូក និងប្រកាសលទ្ធផលប្រឡងតាមប្រព័ន្ធបច្ចេកវិទ្យាកាន់តែមានប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន។

**តេស្តវង្វាយតម្លៃថ្នាក់ជាតិ (NLA)**

- ការពិនិត្យឡើងវិញលើខ្លឹមសារសំណួរតេស្តថ្នាក់ជាតិថ្នាក់ទី៦ និងការបន្ស៊ីគ្នាជាមួយនឹងក្របខណ្ឌកម្រិត
  សមត្ថភាពសាកល (GPF)
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៦ បានធ្វើនៅខែវិច្ឆិកា ឆ្នាំ២០២១ ទៅលើសិស្សជាង៦ ០០០នាក់ (ស្រី ៥៣ភាគរយ, ប្រុស ៤៧ភាគរយ) នៅតាមសាលាបឋមសិក្សារដ្ឋ និងឯកជនសំណាកគំរូ ២៣០សាលា នៅទូទាំងប្រទេសលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាក្នុងស្ថានភាពកូវីដ-១៩បានធូរស្រាល។

លទ្ធផលតេស្តបឋមត្រូវបានផ្សព្វផ្សាយនិងពិគ្រោះយោបល់ ដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធនៅថ្ងៃទី៣១ខែមករា ឆ្នាំ២០២២ មានអ្នកចូលរួម ៥០នាក់ ស្រី ៩នាក់។ លទ្ធផលត្រូវបានពិនិត្យនិងអនុម័តដោយគណៈកម្មការវាយតម្លៃការសិក្សាដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី។ ការផ្សព្វផ្សាយលទ្ធផលជាផ្លូវការ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ មានអ្នកចូលរួមផ្ទាល់ពីថ្នាក់ដឹកនាំ នាយកដ្ឋានពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ៦៣នាក់ ស្រី ៤នាក់ និងមន្ត្រីរាជធានី ខេត្ត សាលាគរុកោសល្យនិងវិក្រឹតការ ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនគោលដៅចូលរួមតាមអនឡាញ។ អ្នកចូលរួមសរុប ៧១០នាក់។

**តេស្តវង្វាយតម្លៃថ្នាក់តំបន់ (SEA-PLM)**

- ការផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃថ្នាក់តំបន់ SEA-PLM ជូនបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ មានអ្នកចូលរួម ១៥០នាក់ ស្រី ២៣នាក់។

### តេស្តវាយតម្លៃអន្តរជាតិ (PISA)

- ការរៀបចំតេស្ត កម្រងសំណួរ ជាភាសាខ្មែរសម្រាប់ការអនុវត្តតេស្តសាកល្បងនៃកម្មវិធី PISA-២០២២
- ការជ្រើសរើសសាលារៀនសំណាក ៣៥ សម្រាប់ការអនុវត្តតេស្តសាកល្បងនៃកម្មវិធី PISA-២០២២
- ការរៀបចំឯកសារជំនួយស្មារតីស្តីពី ការណែនាំការបង្រៀនឆ្លើយតបនឹងកម្មវិធី PISA-២០២២ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG4) ដើម្បីជួយដល់គ្រូបង្រៀនក្នុងការបង្រៀនសិស្សឱ្យសម្រេចបាននូវចំណេះដឹង និងបំណិនមូលដ្ឋានសកល

### តេស្តវាយតម្លៃកម្រិតថ្នាក់ដំបូង (EGRA & EGMA)

- ការបំប៉នសមត្ថភាពស្តីពី បច្ចេកទេសចុះវាយតម្លៃដើមគ្រាលើការសិក្សាថ្នាក់ដំបូង (EGRA-EGMA) ដោយប្រើ Tablet ដល់អនុរក្សតេស្ត ៦៦នាក់ ស្រី ១២នាក់
- ការប្រមូលព័ត៌មានសាលារៀន និងរៀបចំបញ្ជីឈ្មោះសិស្សសម្រាប់វាយតម្លៃដើមគ្រាលើការសិក្សាថ្នាក់ដំបូង (EGRA-EGMA) តាមសាលាបឋមសិក្សា ៣៤០សាលា
- ការបញ្ចប់ការរៀបចំរបាយការណ៍ដើមគ្រានៃតេស្តវាយតម្លៃអំណាននិងគណិតវិទ្យាថ្នាក់ដំបូង (EGRA&EGMA)

### ផលជះនៃការអនុវត្តកំណែទម្រង់តេស្តវាយតម្លៃ

- គ្រូបង្រៀនគ្រប់ភូមិសិក្សាមានសមត្ថភាពកសាងតេស្តវាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- ការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត រាជធានី មានសមត្ថភាពកសាងតេស្តវាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- គរុសិស្ស គរុនិស្សិតមានសមត្ថភាពកសាងតេស្តវាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- ការបង្វឹកបច្ចេកទេសជូនការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ២៥ រាជធានី ខេត្ត ឱ្យមានសមត្ថភាពអនុវត្តតេស្តស្តង់ដាកម្រិតរាជធានី ខេត្ត នៅក្នុងដំណើរការអធិការកិច្ចតាមកាលកំណត់
- ការបង្វឹកបច្ចេកទេសជូនគ្រូបង្រៀនមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា ឱ្យមានសមត្ថភាពអនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដែលមានលក្ខណៈស្តង់ដាច្បាស់លាស់នៅកម្រិតសាលារៀន
- ការពង្រឹងប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្រិតសាលារៀន និងឆ្លើយតបទៅនឹងក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សា
- ការបង្វឹកការវិភាគ និងប្រើប្រាស់លទ្ធផលតេស្តស្តង់ដានៅកម្រិតសាលារៀន ដើម្បីកែលម្អការបង្រៀននិងរៀន ដែលអាចជាវិធីសាស្ត្រល្អបំផុត រួមទាំងជួយដឹកនាំ និងសម្របសម្រួលបច្ចេកទេសក្នុងការរៀបចំ ១) សន្លឹកកិច្ចការស្វ័យសិក្សាផ្អែកលើខ្លឹមសារមេរៀន ២) សន្លឹកកិច្ចការស្វ័យសិក្សាផ្អែកលើបញ្ញត្តិមេរៀន ៣) សន្លឹកកិច្ចការស្វ័យហ្វឹកហាត់ និង៤) សន្លឹកកិច្ចការស្វ័យវាយតម្លៃ ដើម្បីជំរុញឱ្យគ្រូបង្រៀនធ្វើការសិក្សាស្រាវជ្រាវមេរៀនបន្ថែម និងសិស្សអាចធ្វើស្វ័យសិក្សាវាយតម្លៃប្រកបដោយប្រសិទ្ធភាពពិតប្រាកដ

- កិច្ចអន្តរាគមន៍រយៈពេលវែង តាមរយៈការពិគ្រោះយោបល់ស្តីពី កម្មវិធីសិក្សានៃមុខវិជ្ជាវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់កម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន សេចក្តីព្រាងស្តីពីឯកសារជំនួយស្មារតីអភិវឌ្ឍវិញ្ញាសាស្តង់ដាសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ (គ្រូកម្រិតមូលដ្ឋាន ១២+២) និងសម្រាប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## *សសរស្តម្ភទី៥ ៖ ការកែទម្រង់ឧត្តមសិក្សា*

### ការបណ្តុះបណ្តាល និងប្រព័ន្ធក្រេឌីត

- ការធ្វើឱ្យមានឧត្តមមានុវត្តនៅកម្រិតគ្រឹះស្ថានឧត្តមសិក្សា ដូចជាការបង្កើតកម្មវិធីឌីជីថល ការចែករំលែកបទពិសោធរៀនតាមប្រព័ន្ធអនឡាញ ការអនុវត្តការរៀននិងបង្រៀន ការបង្កើតបន្ទប់រៀនតាមប្រព័ន្ធអនឡាញជាប្រចាំ Cyber Online/Program ការចុះឈ្មោះចូលរៀន និងការបង់ថ្លៃសិក្សា
- ការតាមដានការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា និងការរៀបចំរបាយការណ៍លទ្ធផលដែលរៀបចំដោយគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ៥
- ការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៦ គឺផ្តល់នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងព័ត៌មានបច្ចេកវិទ្យា

### ការស្រាវជ្រាវ និងនវានុវត្តន៍

- ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព សម្រាប់ការស្រាវជ្រាវស្ថានប្រព័ន្ធជលសាស្ត្រ នៅវិទ្យាស្ថានបច្ចេក-វិទ្យាកម្ពុជា មជ្ឈមណ្ឌលឧត្តមភាពលើកម្មវិធីសិក្សាការងាររៀន និងបង្រៀន និងការវាយតម្លៃនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង មជ្ឈមណ្ឌលឧត្តមភាព ដើម្បីស្រាវជ្រាវ និងនវានុវត្តន៍នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង
- ការសាងសង់ និងបំពាក់សម្ភារក្នុងកន្លែងពិសោធន៍ ៨ សម្រាប់បម្រើឱ្យការស្រាវជ្រាវផ្នែកស្នែម និងកសិកម្ម នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈគោលដៅ ៥
- ការអនុវត្តគម្រោងស្រាវជ្រាវផ្នែកស្នែម និងកសិកម្ម ៥៣គម្រោង ក្នុងនោះ ៤៤គម្រោងផ្សារភ្ជាប់និងឧស្សាហកម្មមានដូចជា៖ បច្ចេកវិទ្យាថាមពលនិងការគ្រប់គ្រង មេកាត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន កសិកម្មនិងជីវចម្រុះនិងបរិស្ថាន ទឹកនិងបរិស្ថាន វិទ្យាសាស្ត្ររូបធាតុនិងគ្រឿងបង្គុំ បច្ចេកវិទ្យាថាមពលនិងការគ្រប់គ្រង និងបច្ចេកវិទ្យាអាហារ និងអាហារូបត្ថម្ភ
- ការរៀបចំវេទិកាស្រាវជ្រាវថ្នាក់ជាតិលើកទី៣ ស្តីពីការពង្រឹងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សា។

### ប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាផ្ទៃក្នុង និងខាងក្រៅ

- ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សា ដោយបានរៀបចំរបាយការណ៍ស្វ័យវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ១៤
- ការផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ១០។

### ការទំនាក់ទំនងអន្តរជាតិ

- ការអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សា១២ បានសហការគ្នាក្នុងការអនុវត្តកម្មវិធីសិក្សារួមគ្នាក្នុងកម្រិតជាតិ និងអន្តរជាតិមាន ៤០ កម្មវិធីសិក្សា ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៥ និងឯកជន ៧
- ការកែលម្អកម្មវិធីសិក្សាឱ្យមានគុណភាព និងឆ្លើយតបតម្រូវការទីផ្សារការងារ ដោយមានកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយសាកលវិទ្យាល័យអន្តរជាតិ។

## ៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមទាំងនោះមានដូចជា៖

### ការអប់រំកុមារតូច៖

- រចនាសម្ព័ន្ធកម្មវិធីអប់រំកុមារតូចមិនទាន់មានសង្គតិភាពទៅនឹងតម្រូវការសេវា
- ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាមិនទាន់បានពេញលេញ និងគ្របដណ្តប់គ្រប់ជ្រុងជ្រោយ
- ធនធានគាំទ្រកិច្ចដំណើរការនិងបច្ចេកទេសមិនទាន់ឆ្លើយតបទៅនឹងតម្រូវការពង្រីក និងលើកកម្ពស់គុណភាពកម្មវិធីអប់រំកុមារតូច
- សមត្ថភាពបុគ្គលិកអប់រំផ្នែកអប់រំកុមារតូច នៅមិនទាន់ឆ្លើយតបតាមក្របខណ្ឌគុណភាពការអប់រំកុមារតូច
- សកម្មភាពមាតាបិតាក្នុងការចូលរួមគាំទ្រកុមារតូច ក្នុងបរិបទគន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំនៅមានកម្រិត។

### ការអប់រំបឋមសិក្សា៖

- កង្វះគ្រូនៅតាមសាលារៀនដាច់ស្រយាលនិងជួបការលំបាក និងបញ្ហាគ្រូលើសនៅតាមសាលារៀនតំបន់ទីប្រជុំជន
- ការបណ្តុះបណ្តាល ការបង្រៀននិងរៀនតាមប្រព័ន្ធអនឡាញ និងការសិក្សាពីចម្ងាយមានប្រសិទ្ធភាពតិចតួច និងគម្លាតសមត្ថភាពរបស់សិស្ស គរុសិស្ស-និស្សិត កាន់តែធំ
- គ្រូបង្រៀនកម្រិតថ្នាក់ដំបូងប្រមាណ ៦៥ភាគរយ មិនទាន់បានទទួលការបំប៉នស្តីពីការអនុវត្តកញ្ចប់សម្ភារអំណានថ្នាក់ដំបូង និងប្រមាណ ៨០ភាគរយ មិនទាន់បានទទួលការបំប៉នស្តីពីការអនុវត្តកញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ដំបូង
- ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមានទំហំតូចធៀបនឹងសាលាបឋមសិក្សាទូទាំងប្រទេស
- គ្រូបង្រៀនបឋមសិក្សាមិនទាន់មានសមត្ថភាពសមស្របលើកម្រិតលើចំណេះដឹងវិធីសាស្ត្របង្រៀន បទពិសោធ ការគ្រប់គ្រងថ្នាក់រៀន
- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ចម្អិនបានតិចតួច ធ្វើឱ្យការអនុវត្តថវិកា សម្រេចបាន ៤៧ភាគរយ នៃថវិកាសរុប
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការបង្រៀននិងរៀន ការបង្រៀនតាមប្រព័ន្ធអនឡាញ និងឧបករណ៍អេឡិចត្រូនិក

- កង្វះខាតទឹកស្អាត បង្គន់អនាម័យ ការប្រើប្រាស់និងថែទាំបង្គន់អនាម័យ សម្ភារអនាម័យ ជាពិសេស សម្ភារបម្រើឱ្យការលាងសម្អាតដៃ សម្ភារម្ទាប់មេរោគ និងឯកសារអប់រំសុខភាពនៅតាមសាលារៀន។

**ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស៖**

- គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍ពិសោធន៍ គរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មី
- ការចុះកម្មសិក្សា និងទស្សនកិច្ចសិក្សាតាមសហគ្រាស កសិដ្ឋាន និងផ្នែកឯកជនពុំទាន់បានពេញលេញ
- ការផ្សព្វផ្សាយស្តីពីកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីៗ បែបស្ថាបនានិយមផ្អែកលើបញ្ញត្តិ គោលវិធីស្ទែម និងវិធីសាស្ត្រល្អៗផ្សេងទៀត រួមទាំងវិធីសាស្ត្រតាក់តែងវិញ្ញាសា មិនទាន់បាន ទូលំទូលាយដល់គ្រូបង្រៀន
- កង្វះគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បន្ទប់ពិសោធន៍ និងសម្ភារពិសោធន៍ ម៉ោងសិក្សា និងបន្ទប់ កុំព្យូទ័រ ធ្វើឱ្យដំណើរការបង្រៀនមុខវិជ្ជាស្ទែម នៅតែជាបញ្ហាតាមសាលា
- សកម្មភាពការធ្វើអធិការកិច្ចតាមប្រធានបទ ការពិនិត្យតាមដានការធ្វើអធិការកិច្ចសាលារៀនតាម កាលកំណត់ និងសកម្មភាពសាកល្បងតេស្តថ្នាក់ជាតិ និងអន្តរជាតិត្រូវបានពន្យារពេលដោយ ការរីករាលដាលនៃជំងឺកូវីដ-១៩
- កង្វះមន្ត្រីជំនាញផ្នែកវិទ្យាសាស្ត្រសុខាភិបាល និងសុខភាពសាធារណៈដើម្បីបំពេញការងារ
- កង្វះមន្ត្រីជំនាញបច្ចេកទេសផ្នែក ICT ដើម្បីធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានបុគ្គលិក និងគរុសិស្ស គរុនិស្សិត នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- កង្វះធនធានមនុស្សដែលមានជំនាញ ភាសាអង់គ្លេស ព័ត៌មានវិទ្យា និងស្ថាបត្យករ។

**ការអប់រំឧត្តមសិក្សា៖**

- ធនធានមនុស្សជំនាញស្រាវជ្រាវ ព័ត៌មានវិទ្យា គ្រប់គ្រងទិន្នន័យ និងហិរញ្ញវត្ថុនៅមានកម្រិត
- ផែនការសកម្មភាពមួយចំនួនត្រូវបានផ្អាក លុបចោល និងលើកពេលអនុវត្តន៍
- ការជ្រើសរើសនិស្សិតឱ្យចូលសិក្សាមិនទាន់ស្របទៅតាមផែនការដែលបានគ្រោងទុករបស់ គ្រឹះស្ថានសិក្សានីមួយៗ
- ប្រព័ន្ធអ៊ីនធឺណិតនៅមានកម្រិត និងដំណើរការមិនល្អនៅតាមបណ្តាខេត្ត ឬតំបន់មួយចំនួន
- បុគ្គលិក និងនិស្សិតមួយចំនួនមិនមានឧបករណ៍គ្រប់គ្រាន់សម្រាប់ការរៀននិងបង្រៀន។

**ការអប់រំក្រៅប្រព័ន្ធ៖**

- ដំណើរការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតនៅ ពុំទាន់បានដំណើរការពេញលេញ
- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលពុំទាន់បានអនុវត្តនៅទូទាំងប្រទេស
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធពុំទាន់បានអនុវត្តនៅកម្រិតក្រុង ស្រុក ខណ្ឌ
- ការអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ អប់រំក្រៅប្រព័ន្ធ និងកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្រ មិនទាន់បានទូលំទូលាយ
- ការអនុវត្តកម្មវិធីក្រោយអក្ខរកម្មដំណើរការមិនបានពេញលេញ។

**ការអភិវឌ្ឍយុវជននូវជំនាញបច្ចេកទេស និងជំនាញទន់៖**

- កម្មវិធីយុវជនមួយចំនួនខកខានមិនបានអនុវត្ត ដោយសារបញ្ហាការរាតត្បាតនៃជំងឺកូវីដ-១៩
- កង្វះលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំសម្រាប់កម្មវិធីអភិវឌ្ឍយុវជន និងកុមារ
- កង្វះសម្ភារគាំទ្រកម្មវិធីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលយុវជន
- កង្វះគ្រឿងឥស្សរិយយសកាយរឹទ្ធិក្នុងការពង្រីកសមាជិកភាព
- កង្វះធនធានមនុស្សដែលមានសមត្ថភាពជំនាញកិច្ចការយុវជន និងចំណេះដឹងផ្នែកឌីជីថល។

**កំណែទម្រង់ការអប់រំកាយនិងកីឡា៖**

- ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាអប់រំកាយនៅតាមគ្រឹះស្ថានសិក្សាមួយចំនួនមិនទាន់បានអនុវត្តពេញលេញពីរម៉ោងក្នុងមួយសប្តាហ៍
- មន្ត្រីបច្ចេកទេសជំនាញតាមប្រភេទកីឡាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលកម្រិតអន្តរជាតិមិនទាន់គ្រប់គ្រាន់
- ប្រជាជនចូលរួមហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពនៅមានកម្រិត
- មន្ត្រីវេជ្ជសាស្ត្រកីឡាមានចំនួនមិនគ្រប់គ្រាន់ក្នុងការថែទាំសុខភាព ព្យាបាល រៀបចំរបបអាហារ និងការប្រយុទ្ធប្រឆាំងសារធាតុដូប៉ាក្នុងវិស័យកីឡា
- សមត្ថភាពមន្ត្រីបច្ចេកទេសកីឡាសម្រាប់សិក្សាស្រាវជ្រាវ តាមដាន និងវិភាគគុណផលនៃការហាត់ហ្វឹកហ្វឺននៅមានកម្រិត
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បង្រៀន និងបង្ហាត់មិនទាន់ឆ្លើយតបតម្រូវការ
- ធនធានមនុស្សក្នុងអង្គភាពមិនទាន់ឆ្លើយតបទៅនឹងតម្រូវការក្នុងការបំពេញការងារតាមជំនាញ។

## ៤. ទិសដៅគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល

ជារួម ដើម្បីចូលរួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ២០២៣-២០២៥ ឱ្យមានគុណភាព ត្រូវជានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦នៃរដ្ឋសភា ស្របតាមគោលការណ៍ណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម ខ្ពស់ ព្រមទាំងសុខមាលភាព ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ។

ក្នុងពេលស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៣នេះ ដោយមានការគិតគូរក្នុងគោលដៅបង្កើនគុណភាព នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ ជាពិសេស ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំង

ឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង កម្មវិធី សូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ជាពិសេសការរៀបចំផែនការនេះក៏ត្រូវផ្តោតលើសកម្មភាពអាទិភាពដើម្បីគាំទ្រដល់ដំណើរការងារបង្រៀន និងរៀនពីចម្ងាយ តាមអនឡាញ និងតាមប្រព័ន្ធវីដេអូ តាមរយៈវិធីសាស្ត្របង្រៀនថ្មីៗ ក្នុងបរិបទការគ្រប់គ្រងតាមសាលារៀនសំដៅឈានសម្រេចគោលនយោបាយអប់រំរបស់ក្រសួង។

លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដើម្បីចូលរួមចំណែកសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ក្នុងនោះការអភិវឌ្ឍធនធានមនុស្សក្នុងនីតិកាលទី៦ បានបន្តផ្តោតលើ ១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្តុះ បណ្តាលជំនាញបច្ចេកទេស តាមរយៈទស្សនាទាន "យុវជនមានជំនាញមួយយ៉ាងតិចប្រចាំជីវិត" ។

ក្នុងដំណាក់កាលនេះ ក្រសួងអប់រំ យុវជន និងកីឡាបានបន្តផ្តោតលើអាទិភាពកំណែទម្រង់វិស័យអប់រំ ក្នុងនោះរួមមាន៖ (១) កំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិ (២) កំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ និង (៣) កំណែទម្រង់កម្រិតសាលារៀន

ជាងនេះទៅទៀត ក្រសួងក៏កំពុងបន្តអនុវត្តកំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិដែលក្នុងនោះរួមមាន៖ (១) ការអនុវត្តកំណែទម្រង់តាមសសរស្តម្ភទាំង៥ (២) ការអនុវត្តកម្មវិធីសិក្សាថ្មីនិងសៀវភៅសិក្សាគោល ដោយផ្តោតលើវិធីសាស្ត្របង្រៀនថ្មី (៣) កំណែទម្រង់ការគ្រប់គ្រងអប់រំ និង(៤) កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ (៥)កំណែទម្រង់ការអប់រំគ្រូនៅតាមសាលាគរុកោសល្យ (៦) កំណែទម្រង់កម្រិតសាលារៀន (៧) កំណែទម្រង់កម្រិតឧត្តមសិក្សា (៨) កំណែទម្រង់ការអភិវឌ្ឍន៍យុវជន និង (៩) កំណែទម្រង់ការអប់រំកាយ និងកីឡា ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា ទើបតែបានកែសម្រួលគោលនយោបាយអប់រំទាំងពីរក្នុងគោលបំណងសំដៅ "***ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យ កីឡា" និងពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់***" ដើម្បីធានាឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះមានលក្ខណៈអនុវិស័យ ក្នុងការរួមចំណែកសម្រេចគោលនយោបាយរាជរដ្ឋាភិបាលផងដែរ។

គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាព ជាអាទិភាពរបស់ក្រសួងត្រូវបានសម្រួចដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធអប់រំមួយ ដែលធានាគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីសំណាក់ដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានសរុប ដើម្បីឈានទៅអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

## II. គោលបំណងគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡាបានកែសម្រួលខ្លឹមសារដែលមានលក្ខណៈគ្រប់ដណ្តប់ជាអនុវិស័យលើគោលនយោបាយអប់រំ (១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់

វិស័យកីឡា និង (២) ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ជាពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងគោលនយោបាយ ដូចខាងក្រោម៖

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលដៅយុទ្ធសាស្ត្រ និង វិធានការគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ | ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា។ | ការអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ចំណេះដឹង ជំនាញ វិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពល្អ និងកាយសម្បទារឹងមាំ តួនាទីស្ត្រី និងកិច្ចគាំពារសង្គម។ ការអភិវឌ្ឍធនធានមនុស្សបន្តផ្តោតលើ៖ ១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២)ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ | ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស |
| ទី២ ៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។ | | |

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីចំនួន៥ ដូចខាងក្រោម៖

**១. កម្មវិធីទី១៖** ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការ

**គោលបំណងនៃកម្មវិធី៖** ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី ០ឆ្នាំ ទៅក្រោម៦ឆ្នាំ បង្កើនការចូលរៀននិងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្រ្ត នៅកម្រិតអប់រំចំណេះទូទៅ បង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យ ផ្តល់ការអប់រំពហុភាសាដល់កុមារជនជាតិដើមភាគតិច ផ្តល់ការអប់រំពិសេសដល់កុមារពិការ និងការអប់រំបំណិនជីវិតនៅតាមសាលាមធ្យមសិក្សា។

**២. កម្មវិធីទី២៖** ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ

**គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។

**៣. កម្មវិធីទី៣៖** ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

**គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍធនធានមនុស្សលើវិស័យអប់រំកាយ និងកីឡាប្រកប ដោយគុណភាព ប្រសិទ្ធភាព និងលើកកម្ពស់ការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលខ្ពស់។

**៤. កម្មវិធីទី៤៖** ការអភិវឌ្ឍយុវជន

**គោលបំណងនៃកម្មវិធី៖** អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្រ្តស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា និងឆ្លើយតបតាមតម្រូវការចំបាច់របស់យុវជន។

**៥. កម្មវិធីទី៥៖** ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

**គោលបំណងនៃកម្មវិធី៖** ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ការងារវិមជ្ឈការនិងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| គោលបំណងគោលនយោបាយ | ឈ្មោះកម្មវិធី និងអនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| ទី១៖ ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា | **កម្មវិធី ទី ១** | **អគ្គនាយក** | **អគ្គនាយកដ្ឋានអប់រំ** | (១) | (២) | (៣) |
| | អនុកម្មវិធី ១.១ | ប្រធាននាយកដ្ឋាន | នា. អប់រំកុមារតូច | | ✓ | |
| | អនុកម្មវិធី ១.២ | ប្រធាននាយកដ្ឋាន | នា. បឋមសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៣ | ប្រធាននាយកដ្ឋាន | នា. មធ្យមសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៤ | ប្រធាននាយកដ្ឋាន | នា. អប់រំក្រៅប្រព័ន្ធ | | ✓ | |
| | អនុកម្មវិធី ១.៥ | ប្រធាននាយកដ្ឋាន | នា. សុខភាពសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៦ | ប្រធាននាយកដ្ឋាន | នា. តម្រង់ទិសវិជ្ជាជីវៈ | | ✓ | |
| | អនុកម្មវិធី ១.៧ | ប្រធាននាយកដ្ឋាន | នា. បណ្ដុះបណ្ដាល និងរំក្រឹតការ | | ✓ | |
| | អនុកម្មវិធី ១.៨ | ប្រធាននាយកដ្ឋាន | នា. អភិវឌ្ឍកម្មវិធីសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៩ | ប្រធាននាយកដ្ឋាន | នា.អប់រំពិសេស | | ✓ | |
| ទី២៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ | **កម្មវិធីទី ២** | **អគ្គនាយក** | **អគ្គនាយកដ្ឋានឧត្តមសិក្សា** | | | |
| | អនុកម្មវិធី ២.១ | ប្រធាននាយកដ្ឋាន | នា. ឧត្តមសិក្សា | | ✓ | |
| | អនុកម្មវិធី ២.២ | ប្រធាននាយកដ្ឋាន | នា. ស្រាវជ្រាវវិទ្យាសាស្ត្រ | | ✓ | |
| | អនុកម្មវិធី ២.៣ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ✓ | | |
| | អនុកម្មវិធី ២.៤ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យត្បូងឃ្មុំ | | | ✓ |
| | អនុកម្មវិធី ២.៥ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិ ជាស៊ីម កំចាយមារ | ✓ | | |
| | អនុកម្មវិធី ២.៦ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ✓ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ២.៧ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំ | ✓ | | |
| | អនុកម្មវិធី ២.៨ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យស្វាយរៀង | ✓ | | |
| | អនុកម្មវិធី ២.៩ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិមានជ័យ | ✓ | | |
| | អនុកម្មវិធី ២.១០ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិបាត់ដំបង | ✓ | | |
| | អនុកម្មវិធី ២.១១ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | ✓ | | |
| | អនុកម្មវិធី ២.១២ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ✓ | | |
| | អនុកម្មវិធី ២.១៣ | អគ្គលេខាធិការ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ✓ | | |
| | អនុកម្មវិធី ២.១៤ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | | ✓ | |
| | អនុកម្មវិធី ២.១៥ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យក្រចេះ | | | ✓ |
| | អនុកម្មវិធី ២.១៦ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | | ✓ | |
| | អនុកម្មវិធី ២.១៧ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | | ✓ | |
| | អនុកម្មវិធី ២.១៨ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | | ✓ | |
| | **កម្មវិធីទី ៣** | **អគ្គនាយក** | **អគ្គនាយកដ្ឋានកីឡា** | | ✓ | |
| | អនុកម្មវិធី ៣.១ | ប្រធាននាយកដ្ឋាន | នា. អប់រំកាយ និងកីឡា | | | ✓ |
| | អនុកម្មវិធី ៣.២ | ប្រធាននាយកដ្ឋាន | នា. អប់រំកាយ និងកីឡាសិស្ស និស្សិត | | | ✓ |
| | អនុកម្មវិធី ៣.៣ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | | | ✓ |
| | អនុកម្មវិធី ៣.៤ | ប្រធានមជ្ឈមណ្ឌល | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | | | ✓ |
| | អនុកម្មវិធី ៣.៥ | ប្រធាននាយកដ្ឋាន | នា.រៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា | | | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ៣.៦ | ប្រធានមជ្ឈមណ្ឌល | មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា | | | ✓ |
| | **កម្មវិធីទី ៤** | **អគ្គនាយក** | **អគ្គនាយកដ្ឋានយុវជន** | | ✓ | |
| | អនុកម្មវិធី ៤.១ | ប្រធាននាយកដ្ឋាន | នា. យុវជន | | | ✓ |
| | អនុកម្មវិធី ៤.២ | ប្រធាននាយកដ្ឋាន | នា. គ្រប់គ្រងមជ្ឈមណ្ឌលយុវជន | | | ✓ |
| | អនុកម្មវិធី ៤.៣ | ប្រធាននាយកដ្ឋាន | នា.សហប្រតិបត្តិការកាយរឹទ្ធិ | | | ✓ |
| | **កម្មវិធីទី ៥** | **អគ្គនាយក** | **អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** | | | |
| | អនុកម្មវិធី ៥.១ | ប្រធាននាយកដ្ឋាន | នា. ផែនការ | | | ✓ |
| | អនុកម្មវិធី ៥.២ | ប្រធាននាយកដ្ឋាន | នា. បុគ្គលិក | | ✓ | |
| | អនុកម្មវិធី ៥.៣ | ប្រធាននាយកដ្ឋាន | នា. ហិរញ្ញវត្ថុ | | ✓ | |
| | អនុកម្មវិធី ៥.៤ | ប្រធាននាយកដ្ឋាន | នា. សវនកម្មផ្ទៃក្នុង | | ✓ | |
| | អនុកម្មវិធី ៥.៥ | ប្រធាននាយកដ្ឋាន | នា. ជានាគុណភាពអប់រំ | | ✓ | |
| | អនុកម្មវិធី ៥.៦ | ប្រធាននាយកដ្ឋាន | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | | ✓ | |
| | អនុកម្មវិធី ៥.៧ | ប្រធាននាយកដ្ឋាន | នា. ព័ត៌មាន និងកិច្ចការអាស៊ាន | | ✓ | |
| | អនុកម្មវិធី ៥.៨ | ប្រធាននាយកដ្ឋាន | នា. នីតិកម្ម | | ✓ | |
| | អនុកម្មវិធី ៥.៩ | ប្រធាននាយកដ្ឋាន | នា. សំណង់ | | ✓ | |
| | អនុកម្មវិធី ៥.១០ | ប្រធាននាយកដ្ឋាន | នា. សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ | | ✓ | |
| | អនុកម្មវិធី ៥.១១ | ប្រធាននាយកដ្ឋាន | នា. រដ្ឋបាល | | ✓ | |
| | អនុកម្មវិធី ៥.១២ | ប្រធាននាយកដ្ឋាន | នា. ទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | | ✓ | |
| | អនុកម្មវិធី ៥.១៣ | ប្រធាននាយកដ្ឋាន | នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | | | ✓ |
| | អនុកម្មវិធី ៥.១៤ | ប្រធាននាយកដ្ឋាន | នា.គោលនយោបាយ | | | ✓ |
| | អនុកម្មវិធី ៥.១៥ | ប្រធាននាយកដ្ឋាន | នា.ពិនិត្យតាមដាន និងវាយតម្លៃ | | | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ៥.១៦ | ប្រធាននាយកដ្ឋាន | នា. បច្ចេកវិទ្យាព័ត៌មាន | | ✓ | |
| | អនុកម្មវិធី ៥.១៧ | ប្រធាននាយកដ្ឋាន | នា. កិច្ចការប្រឡង | | | ✓ |

## IV. ការកំណត់ទសនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

### ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករសមិទ្ធកម្មនិងគោលដៅ ដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោម៖

តារាង ១ "ក"

**ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅនៃកម្មវិធី និងអនុកម្មវិធី**

| សេចក្តីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៣ (លានរៀល) | ឆ្នាំមុន (២០២១) | គោលដៅសូចនាករសមិទ្ធកម្ម | | | | |
|---|---|---|---|---|---|---|---|
| | | | ឆ្នាំបច្ចុប្បន្ន (ឆ្នាំ ២០២២) | ឆ្នាំគ្រោងថវិកា (២០២៣) | | ឆ្នាំគ្រោង ថវិកា (២០២៤) | ឆ្នាំគ្រោង ថវិកា (២០២៥) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២២) | | |
| *គោលបំណងគ.ប.ទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាស ក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា* | | | | | | | |
| *គោលបំណងគ.ប.ទី២៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់* | | | | | | | |
| **១. កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី១.១៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព(មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | | ៦១,១ | ៦២,១ | ៦៣,១ | | ៦៤,០ | ៦៥,០ |
| សូចនាករលទ្ធផលចុងក្រោយទី១.២៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | ៨៧,៤ | ៨៨,១ | ៨៨,៧ | | ៨៩,៤ | ៩០,០ |
| សូចនាករលទ្ធផលចុងក្រោយទី១.៣៖ អត្រាបញ្ចប់ | | ៤៨,១ | ៥០,៦ | ៥៣,១ | | ៥៥,៥ | ៥៨,០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី១.៤៖ អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) | | ៨៧,៨ | ៨៩,២ | ៩០,៧ | | ៩២,១ | ៩៣,៥ |
| **១.១ អនុកម្មវិធីទី១៖ ការពង្រីកការអប់រំកុមារតូច (នាយកដ្ឋានអប់រំកុមារតូច)** | ១២ ២៩៩,៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.ក៖ អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំនៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន | | ៦១,១% | ៥៩,៦% | ៦៣,១% | | ៦៤,០ | ៦៥,០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.ខ៖ អត្រារួមនៃការសិក្សានៅ មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន | | ៣៤,៨% | ៣៣,៦% | ៣៧,៤% | | ៣៨,៧% | ៤០,០% |
| **១.១.១ ចង្កោមសកម្មភាពទី១៖ គាំពារ និងការអភិវឌ្ឍកុមារតូច** | ១១ ៩៧៥,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.១.ក៖ ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា | | ១ ២៥០ | ១ ២៥០ | ១ ៣៧៥ | | ១ ៤៣៨ | ១ ៥០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.១.ខ៖ ចំនួនមត្តេយ្យសិក្សាបើកថ្មីនៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | | | | ៣៧៨ | ថ្មី | ៤៣៧ | ៤៣៧ |
| **១.១.២ ចង្កោមសកម្មភាពទី២៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអនុវិស័យអប់រំកុមារតូច** | ៣២៤,៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.២.ក៖ ចំនួនសាលាមត្តេយ្យសិក្សាធនធាន សម្រេចបានតាមលក្ខណៈស្តង់ដា | | | | ៤ | ថ្មី | ១០ | ១៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.២.ខ៖ ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ បានអនុវត្តការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សា | | ៤៣ | ៨៦ | ១២៨ | | ១៧១ | ២១៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **១.២ អនុកម្មវិធីទី២៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានបឋមសិក្សា)** | ៧ ២៨៦,៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.២.ក៖ អត្រាពិតនៃការសិក្សា | | ៩១,៩ | ៩២,៤ | ៩៣,០ | | ៩៣,៥ | ៩៤,០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.២.ខ៖ អត្រាត្រួតថ្នាក់ | | ៧,០ | ៦,០ | ៥,០ | | ៤,០ | ៣,០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.២.គ៖ អត្រាបោះបង់ការសិក្សា | | ៧,៣ | ៦,៧ | ៦,២ | | ៥,៦ | ៥,០ |
| **១.២.១ ចង្កោមសកម្មភាពទី១៖ ការអភិវឌ្ឍការអប់រំបឋមសិក្សា ដើម្បីធានាឱ្យការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន** | ៦ ៧៤០,៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.២.១.ក៖ ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន | | ១០ ០០០ នាក់ | ១០ ០០០ នាក់ | ១០ ០០០ នាក់ | | ១២ ០០០ នាក់ | ១២ ០០០ នាក់ |
| **១.២.២ ចង្កោមសកម្មភាពទី២៖ ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា** | ៥៤៦,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.២.២.ក៖ ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន | | ៥០០ នាក់ | ៥០០ នាក់ | ៥០០ នាក់ | | ២ ០០០នាក់ | ២ ០០០នាក់ |
| **១.៣ អនុកម្មវិធីទី៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា (នា. មធ្យមសិក្សាចំណេះទូទៅ)** | ៦ ៥១៣,៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ក៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ៦០,៧ | ៦៥,៥ | ៧០,៤ | | ៧៥,២ | ៨០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ខ៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | ៣២,២ | ៣៥,៤ | ៣៨,៦ | | ៤១,៨ | ៤៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.គ៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ | | ៨១,៣ | ៨៣,០ | ៨៤,៧ | | ៨៦,៣ | ៨៨ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ឃ៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ៤៨,១ | ៥០,៦ | ៥៣,១ | | ៥៥,៥ | ៥៨ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.ង៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ១៨,២ | ១៦,២ | ១៤,១ | | ១២,១ | ១០ |
| **១.៣.១ ចង្កោមសកម្មភាពទី១៖ បង្កើនការចូលរៀនមធ្យមសិក្សា និងជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់មធ្យមសិក្សា** | ៧៦៣,៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.១.ក៖ ចំនួនភ្នាក់ងារផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកម្មវិធីការគ្រប់គ្រងតាមសាលារៀន | | ១០០ | ១០០ | ៤៥០ | | ៤៥០ | ៤៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.១.ខ៖ ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសាបារាំង-ខ្មែរ | | ១០០ | ១០០ | ១០០ | | ១៥០ | ១៥០ |
| | | បឋមភូមិ ៧៥,៩ | បឋមភូមិ ៧៦,១ | បឋមភូមិ ៧៦,២ | គ្រោងពង្រីកចំនួនភ្នាក់ងារផ្លាស់ប្តូរ | បឋមភូមិ ៧៦,៩ | បឋមភូមិ ៧៧,១ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.១.គ៖ ចំនួនសាលារៀនបានចុះជួយពិនិត្យតាមដាន និងវាយតម្លៃ | | ទុតិយភូមិ ៨០,៣ | ទុតិយភូមិ ៨០,៤ | ទុតិយភូមិ ៨១,១ | | ទុតិយភូមិ ៨១,៣ | ទុតិយភូមិ ៨១,៥ |
| **១.៣.២ ចង្កោមសកម្មភាពទី២៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ** | ៥ ៧៥០ | ៤៧ | ១១៨ | ១៥០ | | ២០០ | ២៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៣.២.ក៖ ចំនួនសាលារៀនជំនាន់ថ្មី | | ៧ | ៧ | ៧ | | ៧ | ៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **១.៤ អនុកម្មវិធីទី៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)** | ១ ៩៥៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ក៖ ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | | ១៤ ៤០៤ នាក់ | ១៣ ៦០០ នាក់ | ១២ ៨០០ នាក់ | | ១២ ០០០ នាក់ | ១១ ២០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ខ៖ ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | | ៧ ៤៤៥ នាក់ | ៧ ៣៨៧ នាក់ | ៧ ៤៨៧ នាក់ | | ៧ ៥៨៧ នាក់ | ៧ ៦៨៧ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.គ៖ ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | | ២ ៦៦៣ នាក់ | ១០ ៣០០ នាក់ | ១០ ៤០០ នាក់ | | ១០ ៥០០ នាក់ | ១០ ៦០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ឃ៖ ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ មុខរបរ សម្រាប់ការសិក្សាពេញមួយជីវិត (ម.ស.ស) | | ៧ ១២៥ នាក់ | ៨ ៦៩០ នាក់ | ៩ ៤៩០ នាក់ | | ១០ ២៩០ នាក់ | ១១ ០៩០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ង៖ ចំនួនមន្ត្រីអកបទទួលការបណ្តុះបណ្តាលសមត្ថភាពការគ្រប់គ្រងលើសេវាអកប | | ១២០ នាក់ | វិចារណកម្មថវិកា | ១៩០ នាក់ | | ២៥០ នាក់ | ៣០០ នាក់ |
| **១.៤.១ ចង្កោមសកម្មភាពទី១៖ ការអភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ** | ១៦៩៩,៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.ក៖ ចំនួនកម្មករ-កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស | | ៣៥០ នាក់ | ៤៥០ នាក់ | ៥០០ នាក់ | | ៥៥០ នាក់ | ៦០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.ខ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមសហគមន៍ ពន្ធនាគារ និងមណ្ឌលកែប្រែ | | ១ ៤០៥៤ នាក់ | ១៣ ១៥០នាក់ | ១២ ៣០០ នាក់ | | ១១ ៤៥០ នាក់ | ១០ ៦០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.គ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា | | ៧ ៣៣៩ នាក់ | ៧ ១០០ នាក់ | ៧ ១៨៧ នាក់ | | ៧ ២៣៧ នាក់ | ៧ ២៨៧ នាក់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.ឃៈ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលមធ្យមសិក្សា | | ១០៦ នាក់ | ២៨៧ នាក់ | ៣០០ នាក់ | | ៣៥០ នាក់ | ៤០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.ងៈ ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណេះទូទៅក្នុងប្រព័ន្ធ | | ២ ៦៦៣ នាក់ | ១០ ៣០០ នាក់ | ១០ ៤០០ នាក់ | | ១០ ៥០០ នាក់ | ១០ ៦០០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.១.ចៈ ចំនួនអ្នកសិក្សាដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ | | ៧ ១២៥ នាក់ | ៨ ៦៩០ នាក់ | ៩ ៤៩០ នាក់ | | ១០ ២៩០ នាក់ | ១១ ០៩០ នាក់ |
| **១.៤.២ ចង្កោមសកម្មភាពទី២ៈ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់** | ២៥៥,១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.២.កៈ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការនិងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | | ១៣០ នាក់ | ៣១២ នាក់ | ១៣០ នាក់ | | ១៣០ នាក់ | ១៣០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.១.២ ខៈ ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | | ០ | ០ | ៣០ ក្រុង ស្រុក | | ៣០ ក្រុង ស្រុក | ៣០ ក្រុង ស្រុក |
| **១.៥ អនុកម្មវិធីទី៥ៈ ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា (នាយកដ្ឋានសុខភាពសិក្សា)** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៥.កៈ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បបរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) | | ៣៧,៩ | ៣៦,១ | ៣៤,០ | | ៣០,០ | ២៥,០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៥.ខៈ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បបរមាទឹកស្អាតនិងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២) | | ៣៦,៩ | ៤១,៤ | ៤៥,០ | | ៤០,០ | ៣៥,០ |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រូបង្រៀនអប់រំពហុភាសា | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ពង្រីក និងពង្រឹងការផ្តល់សេវាអប់រំតាមរយៈកម្មវិធីអប់រំពហុភាសា ដល់កុមារជនជាតិដើមភាគតិច ដោយផ្តោតលើការបណ្តុះបណ្តាល និងបំប៉នសមត្ថភាពគ្រូបង្រៀនស្តីពីវិធីសាស្ត្របង្រៀនថ្នាក់អប់រំពហុភាសា និងបោះពុម្ពសៀវភៅសិក្សា សម្រាប់សិស្ស។ | | | |
| **សេចក្តីពណ៌នា៖** ពង្រីកថ្នាក់អប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចកម្រិតបឋមសិក្សា ពីថ្នាក់ទី១ ដល់ទី៣ តាមរយៈមានសៀវភៅសិក្សាជាភាសាកំណើតស្របនឹងកម្មវិធីសិក្សាជាតិ និងគ្រូជាជនជាតិដើមភាគតិច ហើយវិធីសាស្ត្របង្រៀន ឆ្លើយតបនឹងតម្រូវការសិស្ស ធានាកុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ (បង្កើនការចូលរៀន ការឡើងថ្នាក់ កាត់បន្ថយការត្រួតថ្នាក់ និងការបោះបង់ការសិក្សារបស់កុមារជនជាតិដើមភាគតិច)។ | | | |
| **ការគណនា៖** ចំនួនគ្រូជ្រើសរើសតាមតម្រូវការឆ្នាំនីមួយៗ និងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ | | | |
| **ប្រភពទិន្នន័យ៖** របាយការណ៍វគ្គបំប៉នសមត្ថភាពគ្រូអប់រំពហុភាសា និងរបាយការណ៍សន្និបាត | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ៣០ មេសា ២០២៣ | | | |

| កាលបរិច្ឆេទកែប្រែចុងក្រោយ៖ ៣០ ធ្នូ ២០២៣ |
|---|

| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី១.៩៖** ពង្រីកការអប់រំបរិយាបន្ន គ្រប់ភូមិសិក្សា | **អង្គភាពទទួលបន្ទុក៖** នាយកដ្ឋានអប់រំពិសេស | **កាលបរិច្ឆេទ៖ ១២ សីហា ២០២២** |
|---|---|---|---|
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងផ្តល់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអប់រំបរិយាបន្ន ការអប់រំពិសេស និងការអប់រំពហុភាសា ដោយបណ្តុះឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សា ដល់អ្នកមានតម្រូវការពិសេស អ្នកសិក្សាមានពិការភាព និងកុមារជនជាតិដើមភាគតិច ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 1.09.2 **(សម្រាប់អនុកម្មវិធី)** | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធបានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាព | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ពង្រីក និងពង្រឹងការផ្តល់សេវាអប់រំបរិយាបន្នដល់សិស្សមានពិការភាពតាមរយៈការសិក្ខាសាលាពិគ្រោះយោបល់ និងការបំប៉នសមត្ថភាពគ្រូគ្រប់ភូមិសិក្សាស្តីពីការអប់រំបរិយាបន្ន។ | | | |
| **សេចក្តីពណ៌នា៖** ពង្រីកថ្នាក់អប់រំបរិយាបន្នសម្រាប់កុមារមានពិការភាពគ្រប់ភូមិសិក្សា ដើម្បីធានាថាកុមារមានតម្រូវការពិសេស កុមារមានពិការភាពគ្រប់ប្រភេទ បានចូលរៀនក្នុងថ្នាក់ធម្មតា ប្រកបដោយសមធម៌ និងបរិយាបន្ន ដែលចូលរួមកាត់បន្ថយការត្រួតថ្នាក់ ការបោះបង់។ | | | |
| **ការគណនា៖** ចំនួនគ្រូជ្រើសរើសតាមខេត្តគោលដៅ និងតម្រូវការតាមឆ្នាំនីមួយៗ | | | |
| **ប្រភពទិន្នន័យ៖** ចំនួនគ្រូជ្រើសរើសតាមខេត្តគោលដៅ និងតម្រូវការតាមឆ្នាំនីមួយៗ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ៣០ ខែធ្នូ ឆ្នាំ២០២៣។ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ៣០ ខែធ្នូ ឆ្នាំ ២០២៣ | | | |

| ក្រសួង៖ អប់រំ យុវជន និងកីឡា | **អនុកម្មវិធី១.៩៖** ពង្រីកការអប់រំបរិយាបន្ន គ្រប់ភូមិសិក្សា | **អង្គភាពទទួលបន្ទុក៖** នាយកដ្ឋានអប់រំពិសេស | **កាលបរិច្ឆេទ៖ ១២ សីហា ២០២២** |
|---|---|---|---|
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងផ្តល់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអប់រំបរិយាបន្ន ការអប់រំពិសេស និងការអប់រំពហុភាសា ដោយបណ្តុះឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សា ដល់អ្នកមានតម្រូវការពិសេស អ្នកសិក្សាមានពិការភាព និងកុមារជនជាតិដើមភាគតិច ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 1.09.3 **(សម្រាប់អនុកម្មវិធី)** | |
| **ឈ្មោះសូចនាករវែង៖** ចំនួនសិស្សមានពិការភាព(គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...)ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស | | | |

| |
|---|
| និងថ្នាក់សមាហរណកម្ម |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនសិស្សមានពិការភាពរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ផ្ដល់សេវាអប់រំពិសេសដល់សិស្សមានពិការភាពកម្រិតធ្ងន់ និងតាមប្រភេទពិការនីមួយៗ តាមរយៈ ការបណ្ដុះបណ្ដាល ការបំប៉នសមត្ថភាពគ្រូ ការមានកម្មវិធីសិក្សា សៀវភៅសិក្សាដែលស្របនឹងកម្មវិធីសិក្សាជាតិ ហើយសិស្សត្រូវមានឧបករណ៍ជំនួយ និងសម្ភារៀនគ្រប់គ្រាន់ ជាពិសេសផ្ដល់ទីកន្លែងស្នាក់នៅ និងហូបចុកសម្រាប់អ្នកឆ្ងាយពីលំនៅស្ថាន។ |
| **សេចក្ដីពណ៌នា៖** ពង្រីក និងពង្រឹងថ្នាក់អប់រំពិសេស និងអប់រំសមាហរណកម្ម សម្រាប់កុមារមានពិការភាពកម្រិតធ្ងន់គ្រប់កម្រិតថ្នាក់នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់អប់រំសមាហរណកម្ម ដើម្បីធានាការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន ដែលចូលរួមកាត់បន្ថយការត្រួតថ្នាក់ បោះបង់ និងបង្កើនការឡើងថ្នាក់ ជាពិសេសផ្ដល់ឱកាសដល់អ្នកមានពិការភាពទទួលវគ្គបណ្ដុះបណ្ដាល និងបំប៉នវិជ្ជាជីវៈដើម្បីទទួលបានសមធម៌ និងសមភាពការងារក្នុងសង្គម។ |
| **ការគណនា៖** ចំនួនគ្រូជ្រើសរើសតាមតម្រូវការរបស់វិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ដើម្បីបណ្ដុះបណ្ដាល |
| **ប្រភពទិន្នន័យ៖** របាយការណ៍វគ្គបណ្ដុះបណ្ដាលសមត្ថភាពគ្រូជំនាញអប់រំពិសេស របស់នាយកដ្ឋានអប់រំពិសេស និងរបាយការណ៍សន្និបាត របាយការណ៍ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ៣០ ខែធ្នូ ឆ្នាំ២០២៣ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ៣០ ខែធ្នូ ឆ្នាំ ២០២៣ |

តារាង ២ "ក"

ទម្រង់បែបបទសូចនាករសមិទ្ធកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ទម្រង់ "ក"

ឆ្នាំ ២០២៣

| **ក្រសួងអប់រំ យុវជន និងកីឡា** | **កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ អគ្គនាយកដ្ឋានឧត្តមសិក្សា** | **កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២** |
|---|---|---|---|
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។ | | | |
| **ប្រភេទសូចនាករ៖**<br>☑ **សូចនាករលទ្ធផលចុងក្រោយ**<br>☐ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖**<br>☑ ___ KPI 2.01 (**សម្រាប់កម្មវិធី**)<br>☐ ___ PI 1.XX.X (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២) ក្នុងការទទួលយកសិស្សដែលបានជាប់/ធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមកចូលរៀននៅឧត្តមសិក្សា | | | |
| **ឈ្មោះសូចនាករខ្លី៖** អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២) | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ធានាឱ្យការអប់រំឧត្តមសិក្សាមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាស ក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ | | | |
| **សេចក្ដីពណ៌នា៖** ចំនួននិស្សិតចូលរៀននៅឧត្តមសិក្សាមានការកើនឡើងមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាឆ្លើយតបទៅនឹងកំណែទម្រង់ឧត្តមសិក្សា ផែនការយុទ្ធសាស្ត្រ | | | |

| |
|---|
| វិស័យអប់រំ២០១៩-២០២៣ និង យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ ក្នុងការបង្កើនផលិតភាព និងជំរុញកំណើនសេដ្ឋកិច្ច និងសង្គម។ |
| **ការគណនា៖** ការប្រឡងជ្រើសរើសនិស្សិតឱ្យចូលរៀននៅឧត្តមសិក្សាក្នុងឆ្នាំសិក្សានីមួយៗធ្វើឡើងពីរលើកនៅខែវិច្ឆិកា ឆ្នាំចាស់ និងនៅខែមេសា ឆ្នាំថ្មី និងត្រូវប្រមូលទិន្នន័យនៅក្នុងត្រីមាសទី៣ នៃឆ្នាំ ធៀបនឹងចំនួនប្រជាជនសរុបដែលមានអាយុចន្លោះពី ១៨ដល់២២ឆ្នាំ |
| **ប្រភពទិន្នន័យ៖** ប្រមូលទិន្នន័យនិស្សិតពីគ្រឹះស្ថានឧត្តមសិក្សាចំនួន៩៥ រក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា (HEMIS) និងជំរឿនស្ថិតិប្រជាជនរបស់ក្រសួងផែនការ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** នៅត្រីមាសទី៣នៃឆ្នាំនីមួយៗ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ អគ្គនាយកដ្ឋានឧត្តមសិក្សា** | **កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។ | | | |
| **ប្រភេទសូចនាករ៖**<br>☑ **សូចនាករលទ្ធផលចុងក្រោយ**<br>☐ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖**<br>☑ ___ KPI 2.02 **(សម្រាប់កម្មវិធី)**<br>☐ ___ PI 1.XX.X **(សម្រាប់អនុកម្មវិធី)** | |
| **ឈ្មោះសូចនាករវែង៖** ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅក្នុងគ្រឹះស្ថានឧត្តមសិក្សា | | | |
| **ឈ្មោះសូចនាករខ្លី៖** ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលស្ទែម (STEM) | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ធានាឱ្យការអប់រំលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅឧត្តមសិក្សាមានគុណភាពដើម្បីជំរុញកំណើន លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចឌីជីថល។ | | | |
| **សេចក្តីពណ៌នា៖** ចំនួននិស្សិតចូលរៀននៅឧត្តមសិក្សាមានគុណភាព និងការកើនឡើងលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់ឧត្តមសិក្សា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ និងក្របខណ្ឌសេដ្ឋកិច្ចឌីជីថលក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចឌីជីថល ។ | | | |
| **ការគណនា៖** ការប្រឡងជ្រើសរើសនិស្សិតឱ្យចូលរៀននៅឧត្តមសិក្សាលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ក្នុងឆ្នាំសិក្សានីមួយៗធ្វើឡើងពីរលើកនៅខែវិច្ឆិកា ឆ្នាំចាស់ និងនៅខែមេសា ឆ្នាំថ្មី និងត្រូវប្រមូលទិន្នន័យនៅក្នុងត្រីមាសទី៣នៃឆ្នាំ ធៀបជាមួយនិស្សិតដែលចុះឈ្មោះចូលរៀនសរុបក្នុងឆ្នាំ | | | |
| **ប្រភពទិន្នន័យ៖** ប្រមូលទិន្នន័យនិស្សិតពីគ្រឹះស្ថានឧត្តមសិក្សាចំនួន៩៥ រក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា (HEMIS) | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** នៅត្រីមាសទី៣នៃឆ្នាំនីមួយៗ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ | | | |

# ទម្រង់បែបបទសូចនាករសមិទ្ធកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ទម្រង់ "ក"
# ឆ្នាំ ២០២៣

| | | | |
|---|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.១៖** ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានឧត្តមសិក្សា | កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២ |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា។ | | | |
| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | | **លេខកូដសូចនាករ៖** ☑ ___ PI 2.01.1 (សម្រាប់អនុកម្មវិធី) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវ៖ ១) គុណភាពនៃការស្រាវជ្រាវផ្សារភ្ជាប់នឹងការអភិវឌ្ឍដែលនឹងនាំឱ្យមានកំណើនសេដ្ឋកិច្ច ២) គុណភាពនៃនិស្សិតបញ្ចប់ការសិក្សាឆ្លើយតបនឹងទីផ្សារការងារ និងសមធម៌សង្គម និង ៣) គុណភាពនៃប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងនិរន្តរភាព ដែលជាធាតុចូលដ៏សំខាន់សម្រាប់គ្រឹះស្ថានឧត្តមសិក្សា។ | | | |
| **សេចក្តីពណ៌នា៖** ប្រព័ន្ធនេះមានលក្ខណៈជាក់ស្តែង និងតម្រូវទៅតាមស្ថានភាពប្រទេស និងកម្រិតសមត្ថភាពរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ។ ភាពប្រទាក់ក្រឡាគ្នានៃប្រព័ន្ធធានាគុណភាពអប់រំនេះនឹងចូលរួមចំណែកក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យកម្ពុជាក្នុងការប្រែក្លាយប្រទេសកម្ពុជាជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ តាមរយៈការផ្តល់ជាម៉ែត្រសម្រាប់វាស់វែង និងតម្រង់ទិសដៅអភិវឌ្ឍន៍ការអប់រំឧត្តមសិក្សាស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលផ្តោលលើ "កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព"។ | | | |
| **ការគណនា៖** គឺផ្អែកលើការបូកតួលេខបន្តពីមួយឆ្នាំទៅមួយឆ្នាំ ដោយក្នុងនោះមានការកើនឡើងចំនួន៥គ្រឹះស្ថានក្នុងមួយឆ្នាំៗ | | | |
| **ប្រភពទិន្នន័យ៖** ចំនួនគ្រឹះស្ថានដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងគឺផ្អែកលើរបាយការណ៍ស្វ័យវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗដែលបានអមុម័តពីប្រធានក្រុមប្រឹក្សាភិបាល ហើយផ្តល់ជូនអគ្គនាយកដ្ឋានឧត្តមសិក្សារៀងរាល់ចុងឆ្នាំ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ទិន្នន័យកំណត់នៅរៀងរាល់ចុងឆ្នាំ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ | | | |

| | | | |
|---|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.១៖** ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការ | អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានឧត្តមសិក្សា | កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២ |

| | | | |
|---|---|---|---|
| | **អប់រំឧត្តមសិក្សា** | | |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា។ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 2.01.2 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំ និងអនុវត្តការតាំរបស់និស្សិត | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានអនុវត្តការតាំ | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ជួយគ្រឹះស្ថានឧត្តមសិក្សាគោលដៅសម្រេចបាននូវសូចនាករទី១៦ នៃប្រព័ន្ធធានាគុណភាពឧត្តមសិក្សារបស់ខ្លួន ពោលគឺជួយលើកកម្ពស់គុណភាពនៃការផ្តល់សេវាឱ្យកាន់តែមានភាពល្អប្រសើរ។ | | | |
| **សេចក្តីពណ៌នា៖** គ្រឹះស្ថានឧត្តមសិក្សានីមួយៗនឹងផ្តល់សិទ្ធិតាំជូននិស្សិតលើ សេវាកម្មសិក្សា សេវាកម្មគាំទ្រ និងសេវាកម្មផ្សេងៗ និងមានប្រព័ន្ធដោះស្រាយការតាំរបស់និស្សិតបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ | | | |
| **ការគណនា៖** គឺគណនាជាលេខសង់បន្តពីឆ្នាំចាស់ ដោយយបូកបញ្ចូលគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តការតាំ | | | |
| **ប្រភពទិន្នន័យ៖** ប្រមូលទិន្នន័យពីគ្រឹះស្ថានឧត្តមសិក្សាគោលដៅ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** រៀងរាល់សប្តាហ៍ទី១នៃខែ ក្រោយបញ្ចប់ឆមាសលើកទី១ និងលើកទី២ មិនឱ្យហួសពីសប្តាហ៍ទី២នៃខែក្រោយបញ្ចប់ឆមាសលើកទី២ នៃឆ្នាំនីមួយៗ។ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ | | | |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.១៖** **ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការ អប់រំឧត្តមសិក្សា** | **អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានឧត្តមសិក្សា** | **កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 2.01.3 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំ និងអនុវត្តប្រព័ន្ធសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាមានការងារធ្វើ | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានអនុវត្ត Tracer Study។ | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ជួយគ្រឹះស្ថានឧត្តមសិក្សាគោលដៅសម្រេចបានស្តង់ដាទី២ នៃសូចនាករទី៤ របស់ប្រព័ន្ធធានាគុណ-ភាពឧត្តមសិក្សារបស់ខ្លួន ពោលគឺជួយលើកកម្ពស់គុណភាពបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា | | | |

| |
|---|
| ឱ្យកាន់តែមានភាពប្រសើរឡើង។ |
| **សេចក្ដីពណ៌នា៖** គ្រឹះស្ថានឧត្តមសិក្សានីមួយៗនឹងមានប្រព័ន្ធនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយរកឃើញលទ្ធផលនៃការទទួលបានប្រាក់បៀវត្សរបស់និស្សិតក្រោយបញ្ចប់ការសិក្សា ផលិតភាពការងារ និងតម្រូវការជំនាញក្នុងការបំពេញការងារ ពោលគឺជួយឱ្យគ្រឹះស្ថានឧត្តមសិក្សាកែលម្អកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងសង្គមសេដ្ឋកិច្ចឌីជីថល។ |
| **ការគណនា៖** គឺគណនាជាលេខសង់បន្តពីឆ្នាំចាស់ ដោយយបូកបញ្ចូលគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្ត Tracer Study។ |
| **ប្រភពទិន្នន័យ៖** ប្រមូលទិន្នន័យពីគ្រឹះស្ថានឧត្តមសិក្សាគោលដៅ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** រៀងរាល់សប្តាហ៍ទី២ ខែធ្នូ នៃឆ្នាំនីមួយៗ។ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ |

| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.១៖ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា** | **អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានឧត្តមសិក្សា** | **កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២** |
|---|---|---|---|
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | | | |
| **ប្រភេទសូចនាករ៖**<br>☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖**<br>☑ ___ PI 2.01.4 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ(HEMIS) | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ការរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងបណ្ដុះបណ្ដាល និងការស្រាវជ្រាវឧត្តមសិក្សានេះមានគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យបណ្ដុះបណ្ដាល និងស្រាវជ្រាវនៅឧត្តមសិក្សា តាមបែបឌីជីថលនិងលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ និងគ្រឹះស្ថានឧត្តមសិក្សាក្នុងការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ បណ្ដុះបណ្ដាល និងស្រាវជ្រាវនៅឧត្តមសិក្សា។ | | | |
| **សេចក្ដីពណ៌នា៖** ប្រព័ន្ធព័ត៌មានគ្រប់គ្រងការបណ្ដុះបណ្ដាល និងស្រាវជ្រាវនៅឧត្តមសិក្សានេះ រៀបចំឡើងសម្រាប់គ្រប់គ្រងទិន្នន័យបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវក្នុងអនុវិស័យឧត្តមសិក្សា ក្នុងទម្រង់ឌីជីថល។ ប្រព័ន្ធនេះនឹងជួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្នុងការរៀបចំ គ្រប់គ្រង និងប្រើប្រាស់ទិន្នន័យជាមូលដ្ឋានសម្រាប់កែលម្អគុណភាពបណ្ដុះបណ្ដាល និងស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្រព័ន្ធនេះនឹងរៀបចំឡើងជាលក្ខណៈអនឡាញ ដែលអគ្គនាយកដ្ឋានឧត្តមសិក្សា (នាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ) ជាអ្នកគ្រប់គ្រង និងសម្របសម្រួលដោយផ្ទាល់។ | | | |
| **ការគណនា៖** គឺផ្អែកលើការបូកតួលេខបន្តពីមួយឆ្នាំទៅមួយឆ្នាំ នៃចំនួនគ្រឹះស្ថានឧត្តមសិក្សាក្រោមក្រសួងអប់រំ យុវជន និងកីឡាដែលបានបញ្ចូលទិន្នន័យគ្រប់គ្រាន់ក្នុងប្រព័ន្ធ(HEMIS)។ | | | |
| **ប្រភពទិន្នន័យ៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាក្រោមក្រសួងអប់រំ យុវជន និងកីឡាដែលបានបញ្ចូលទិន្នន័យគ្រប់គ្រាន់ក្នុងប្រព័ន្ធ | | | |

| |
|---|
| (HEMIS) ហើយផ្តល់ជូនអគ្គនាយកដ្ឋានឧត្តមសិក្សារៀងរាល់ចុងឆ្នាំ។ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួនពីរដងក្នុងមួយឆ្នាំសិក្សា លើកទី១នៅខែតុលា និងលើកទី២ នៅខែមេសា។ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.១៖** **ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា** | **អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានឧត្តមសិក្សា** | **កាលបរិច្ឆេទ៖ ១៥ កក្កដា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | | | |
| **ប្រភេទសូចនាករ៖**<br>☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖**<br>☑ ___ PI 2.01.5 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ជួយគ្រឹះស្ថានឧត្តម សិក្សាគោលដៅទាំង៦ ឱ្យអនុវត្តការងារបណ្ដាញសាកលវិទ្យាល័យសាយប័រនេះ ឱ្យមានគុណភាព និងប្រសិទ្ធភាព ដែលអាចសម្រេចបាននូវសូចនាករទាំង៣ ដែលបានកំណត់ក្នុងកម្មវិធីវិនិយោគបណ្ដាញសាកលវិទ្យាល័យសាយប័រ។ | | | |
| **សេចក្តីពណ៌នា៖** គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំង៦ នឹងអនុវត្តការងារបណ្ដាញសាកលវិទ្យាល័យសាយប័រនេះ ឱ្យមានគុណភាព និងប្រសិទ្ធភាព ដោយនឹងរៀបចំឱ្យមានមុខវិជ្ជាដាក់ប្រើប្រាស់ក្នុងកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ និងដំណើរការហេដ្ឋារចនាសម្ព័ន្ធសាកលវិទ្យាល័យសាយប័រ។ | | | |
| **ការគណនា៖** ផ្ដោតលើចំនួនគ្រឹះស្ថានឧត្តមសិក្សាដែល បានរៀបចំមុខវិជ្ជាដែលបានដាក់ប្រើប្រាស់ក្នុងកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ។ | | | |
| **ប្រភពទិន្នន័យ៖** ផ្អែកលើគ្រឹះស្ថានឧត្តមសិក្សាដែល បានរៀបចំមុខវិជ្ជាដែលបានដាក់ប្រើប្រាស់ក្នុងកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ។ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ទិន្នន័យកំណត់នៅរៀងរាល់ចុងឆ្នាំ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ១០ កញ្ញា ២០២៣ | | | |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.២៖** **ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា** | **អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងជំរុញការសិក្សាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ និងផ្សារភ្ជាប់ជាមួយផ្នែកឧស្សាហកម្ម។ | | | |
| **ប្រភេទសូចនាករ៖** | | **លេខកូដសូចនាករ៖** | |

<table>
<tr><td>☑ សូចនាករលទ្ធផលក្នុងឆ្នាំ</td><td>☑ ___ PI 2.02.1 (សម្រាប់អនុកម្មវិធី)</td></tr>
<tr><td colspan="2">ឈ្មោះសូចនាករវែង៖ ភាគរយនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយការសរសេររបាយការណ៍ស្រាវជ្រាវ ឬសរសេរនិក្ខេបបទធៀបនឹងនិស្សិតបញ្ចប់ក្នុងឆ្នាំ។</td></tr>
<tr><td colspan="2">ឈ្មោះសូចនាករខ្លី៖ ភាគរយនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្របញ្ចប់ការសិក្សាដោយការសរសេររបាយការណ៍ស្រាវជ្រាវ ឬសរសេរនិក្ខេបបទ។</td></tr>
<tr><td colspan="2">គោលបំណង/សារៈសំខាន់នៃសូចនាករ៖ លើកកម្ពស់សមត្ថភាពនិស្សិតបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលបានសរសេររបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទមានការកើនឡើងជាបន្តបន្ទាប់។</td></tr>
<tr><td colspan="2">សេចក្ដីពណ៌នា៖ សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើកំណើននិស្សិតបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលមានសមត្ថភាពអាចសរសេររបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទពីមួយឆ្នាំទៅមួយឆ្នាំសម្រាប់គាំទ្រ និងអភិវឌ្ឍដល់ការស្រាវជ្រាវនៅឧត្តមសិក្សាស្របនឹងគោលនយោបាយទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា។</td></tr>
<tr><td colspan="2">ការគណនា៖ ជាផលធៀបរវាងចំនួននិស្សិតបញ្ចប់ដោយសរសេរនិក្ខេបបទ និងចំនួននិស្សិតបញ្ចប់ការសិក្សាសរុបប្រចាំឆ្នាំគុណនឹង ១០០</td></tr>
<tr><td colspan="2">ប្រភពទិន្នន័យ៖ គ្រឹះស្ថានឧត្តមសិក្សាដែលបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រ (របាយការណ៍សមិទ្ធិកម្ម និងរបាយការណ៍សន្និបាតអប់រំ)។</td></tr>
<tr><td colspan="2">ថ្ងៃកំណត់នៃទិន្នន័យ៖ ០១ វិច្ឆិកា ២០២៣</td></tr>
<tr><td colspan="2">កាលបរិច្ឆេទកែប្រែចុងក្រោយ៖ ៣១ ធ្នូ ២០២៣</td></tr>
</table>

<table>
<tr><td>ក្រសួងអប់រំ យុវជន និងកីឡា</td><td>អនុកម្មវិធី២.២៖<br>ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា</td><td>អង្គភាពទទួលបន្ទុក៖<br>នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ</td><td>កាលបរិច្ឆេទ៖ ១១ សីហា ២០២២</td></tr>
<tr><td colspan="4">គោលបំណងកម្មវិធី/អនុកម្មវិធី៖ លើកកម្ពស់ការបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រ និងជំរុញការសិក្សាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ និងផ្សារភ្ជាប់ជាមួយផ្នែកឧស្សាហកម្ម។</td></tr>
<tr><td colspan="2">ប្រភេទសូចនាករ៖<br>☑ សូចនាករលទ្ធផលក្នុងឆ្នាំ</td><td colspan="2">លេខកូដសូចនាករ៖<br>☑ ___ PI 2.02.2 (សម្រាប់អនុកម្មវិធី)</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករវែង៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្ដុះ-បណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រ។</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករខ្លី៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រង។</td></tr>
<tr><td colspan="4">គោលបំណង/សារៈសំខាន់នៃសូចនាករ៖ គ្រឹះស្ថានឧត្តមសិក្សាមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រច្បាស់លាស់ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវ។</td></tr>
<tr><td colspan="4">សេចក្ដីពណ៌នា៖ សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើការគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រច្បាស់លាស់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយ ដើម្បីពង្រឹងគុណភាពប្រសិទ្ធភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវស្របនឹងគោលនយោបាយទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា។</td></tr>
<tr><td colspan="4">ការគណនា៖ រាប់ចំនួនគ្រឹះស្ថានដែលបានរៀបចំ និងនិងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រង។</td></tr>
<tr><td colspan="4">ប្រភពទិន្នន័យ៖ របាយការណ៍សមិទ្ធិកម្ម និងរបាយការណ៍សន្និបាតអប់រំ។</td></tr>
</table>

| |
|---|
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ២៥ កក្កដា ២០២៣ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ៣១ ធ្នូ ២០២៣ |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា** | **អង្គភាពទទួលបន្ទុក៖ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងជំរុញការសិក្សាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ និងផ្សារភ្ជាប់ជាមួយផ្នែកឧស្សាហកម្ម។ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 2.02.3 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនបុគ្គលិកបង្រៀន មន្រ្តីជំនាញ និងនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រដែលចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍។ | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនបុគ្គលិកអប់រំ អ្នកស្រាវជ្រាវ និងនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រដែលបានអភិវឌ្ឍសមត្ថភាព។ | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** កំណើនបុគ្គលិកអប់រំ អ្នកស្រាវជ្រាវនិងនិស្សិតដែលបានអភិវឌ្ឍសមត្ថភាព ដើម្បីបំពេញការងារនៅតាមគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាព។ | | | |
| **សេចក្តីពណ៌នា៖** សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើកំណើនបុគ្គលិកអប់រំ អ្នកស្រាវជ្រាវ និងនិស្សិត(ថ្នាក់ក្រោយបរិញ្ញាបត្រ)ដែលបានអភិវឌ្ឍសមត្ថភាព ដើម្បីបំពេញការងារនៅតាមគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាពស្របនឹងគោលនយោបាយទី២របស់ក្រសួងអប់រំ យុវជន និងកីឡា។ | | | |
| **ការគណនា៖** រាប់ចំនួនបុគ្គលិកអប់រំ អ្នកស្រាវជ្រាវ និងនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រដែលបានចូលរួមបំប៉នសមត្ថភាព។ | | | |
| **ប្រភពទិន្នន័យ៖** បញ្ជីវត្តមានបុគ្គលិកអប់រំ អ្នកស្រាវជ្រាវ និងនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រដែលបានចូលរួមបំប៉នសមត្ថភាព ឬរបាយការណ៍សមិទ្ធិកម្ម និងរបាយការណ៍សន្និបាតអប់រំ ។ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ០១ មិថុនា ២០២៣ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ៣១ ធ្នូ ២០២៣ | | | |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.៣៖ ការពង្រឹងគុណភាព និងភាពឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយ ប្រសិទ្ធភាព** | **អង្គភាពទទួលបន្ទុក៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** | **កាលបរិច្ឆេទ៖ ១២ សីហា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសមួយសម្រាប់ប្រទេសជាតិ ដោយផ្សារភ្ជាប់ការងារស្រាវជ្រាវវិទ្យាសាស្ត្រមូលដ្ឋានទៅនឹងការងារផលិតកម្ម និងជីវភាពសង្គម ។ | | | |
| **ប្រភេទសូចនាករ៖** | | **លេខកូដសូចនាករ៖** | |

| | |
|---|---|
| ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | ☑ ___ PI 2.03.1 (**សម្រាប់អនុកម្មវិធី**) |
| **ឈ្មោះសូចនាករវែង៖** ភាគរយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំទី៤ថ្នាក់អាហារូបករណ៍ និងថ្នាក់បង់ថ្លៃ ប្រឡងជាប់បរិញ្ញបត្រ។ | |
| **ឈ្មោះសូចនាករខ្លី៖** ភាគរយនិស្សិតស.ភ.ភ.ព. ឆ្នាំទី៤ប្រឡងជាប់បរិញ្ញាបត្រ។ | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ផលិតធនធានមនុស្សមានសមត្ថភាព និងជំនាញ ឆ្លើយតបនឹងទីផ្សារការងារបច្ចុប្បន្ន។ | |
| **សេចក្ដីពណ៌នា៖** ដើម្បីសម្រេចនូវគោលបំណងនៃសូចនាករនេះសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវពង្រឹងសមត្ថភាពស្ថាប័ន ពង្រឹងគុណភាព ផ្ទៃក្នុង កែលម្អកម្មវិធីសិក្សា បំប៉នសមត្ថភាពបុគ្គលិកអប់រំជាពិសេសលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យបង្រៀនផ្ដល់នូវការស្រាវជ្រាវនិងនវានុវត្តន៍ដល់និស្សិត ប្រកបដោយគុណភាពផ្សារភ្ជាប់ក្នុងសកម្មភាពឧស្សាហកម្ម កសិកម្មនិងសង្គម ដែលមានការគាំទ្រដំណើរការអង្គភាពទាំងផ្នែកសម្ភារនិងបរិក្ខារ ព្រមទាំងសេវាកម្មផ្សេងៗទៀត ដើម្បីគាំទ្រដល់ការរៀន និងបង្រៀនតាមបែបសម័យបច្ចេកវិទ្យាឌីជីថល។ | |
| **ការគណនា៖** យកលទ្ធផលបេក្ខជនប្រឡងជាប់បរិញ្ញាបត្រធៀបនឹងចំនួននិស្សិតស.ភ.ភ.ព.ឆ្នាំទី៤ទាំងអស់ដែលបានដាក់ពាក្យប្រឡង។ | |
| **ប្រភពទិន្នន័យ៖** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ពេលចេញលទ្ធផលប្រឡងបញ្ចប់ថ្នាក់បរិញ្ញាប័ត្រឆ្នាំទី៤។ | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ៣១ ធ្នូ ២០២៣ | |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.៤៖** **ការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល និងការស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ** | **កាលបរិច្ឆេទ៖ ២៦ សីហា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** បណ្ដុះបណ្ដាលសិស្ស និងនិស្សិតលើជំនាញបច្ចេកទេសវិជ្ជាជីវៈ និងកម្រិតឧត្តមសិក្សា ដើម្បីឱ្យក្លាយជាអ្នកដែលមានសមត្ថភាពពេញលេញលើចំណេះដឹង ជំនាញ អត្តចរិក និងភាពថ្លៃថ្នូរ ក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 2.04.1 (**សម្រាប់អនុកម្មវិធី**) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនសិស្សនិស្សិតចូលរៀនបរិញ្ញាបត្រ បិញ្ញាបត្ររង និងគុណវុឌ្ឍិ១ ២ ៣ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើន | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនសិស្សនិស្សិតស.ហ.ស.ត. ចូលរៀន | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ផលិតនិស្សិតមានសមត្ថភាព និងសិស្សមានជំនាញបច្ចេកទេស ធ្វើការងារបំពេញតម្រូវការទីផ្សារ។ | | | |

<table>
<tr><td>សេចក្តីពណ៌នា៖ ដើម្បីសម្រេចនូវគោលបំណងនៃសូចនាករនេះសាកលវិទ្យាល័យហេង សំរិន ត្បូងឃ្មុំត្រូវ ពង្រឹងសមត្ថភាពស្ថាប័នពង្រឹងគុណភាពផ្ទៃក្នុង កែលម្អកម្មវិធីសិក្សា បំប៉នសមត្ថភាពបុគ្គលិកអប់រំជាពិសេសលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យបង្រៀន ផ្តល់នូវការស្រាវជ្រាវនិងនវានុវត្តន៍ដល់និស្សិត ប្រកបដោយគុណភាពផ្សារភ្ជាប់ក្នុងសកម្មភាពឧស្សាហកម្ម កសិកម្មនិងសង្គម ដែលមានការគាំទ្រដំណើរការអង្គភាពទាំងផ្នែកសម្ភារនិងបរិក្ខារ ព្រមទាំងសេវាកម្មផ្សេងៗទៀត ដើម្បីគាំទ្រដល់ការរៀននិងបង្រៀនតាមបែបសម័យបច្ចេកវិទ្យាឌីជីថល។</td></tr>
<tr><td>ការគណនា៖ យកបញ្ជីបេក្ខជនដែលបានចុះឈ្មោះសិក្សាតាមមហាវិទ្យាល័យនិងវិទ្យាស្ថានមកពិនិត្យផ្ទៀងផ្ទាត់</td></tr>
<tr><td>ប្រភពទិន្នន័យ៖ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ</td></tr>
<tr><td>ថ្ងៃកំណត់នៃទិន្នន័យ៖ ពេលចេញលទ្ធផលប្រឡងចូល</td></tr>
<tr><td>កាលបរិច្ឆេទកែប្រែចុងក្រោយ៖</td></tr>
</table>

<table>
<tr><td>ក្រសួងអប់រំ យុវជន និងកីឡា</td><td>អនុកម្មវិធី២.៥៖<br>លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ</td><td>អង្គភាពទទួលបន្ទុក៖ សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ</td><td>កាលបរិច្ឆេទ៖ ១២ សីហា ២០២២</td></tr>
<tr><td colspan="4">គោលបំណងកម្មវិធី/អនុកម្មវិធី៖ លើកកម្ពស់ការបណ្តុះបណ្តាលសិស្ស និស្សិតកម្រិតឧត្តមសិក្សា និងជំនាញអប់រំ បច្ចេកទេសវិជ្ជាជីវៈឱ្យទទួលបានចំណេះដឹងសមស្របទៅតាមតម្រូវការសង្គម មានសមត្ថភាពបំពេញការងារដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។</td></tr>
<tr><td colspan="2">ប្រភេទសូចនាករ៖<br>☑ សូចនាករលទ្ធផលក្នុងឆ្នាំ</td><td colspan="2">លេខកូដសូចនាករ៖<br>☑ ___ PI 2.05.1 (សម្រាប់អនុកម្មវិធី)</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករវែង៖ ភាគរយនិស្សិតដែលបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅតាមស្ថាប័ននានា។</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករខ្លី៖ ភាគរយនិស្សិតមានការងារធ្វើ។</td></tr>
<tr><td colspan="4">គោលបំណង/សារៈសំខាន់នៃសូចនាករ៖ ជំរុញឱ្យដំណើរការរៀន បង្រៀន ព្រមទាំងការផ្តល់សេវានិស្សិតមានគុណភាពខ្ពស់។</td></tr>
<tr><td colspan="4">សេចក្តីពណ៌នា៖ ដើម្បីលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ សាកលវិទ្យាល័យផ្តោតយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការធ្វើទំនើបកម្មសម្ភាររូបវ័ន្តរៀន និងបង្រៀន ការកែលម្អកម្មវិធីសិក្សា ការសិក្សាស្រាវជ្រាវ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍ ក្នុងនិងក្រៅប្រទេស ដើម្បីធ្វើឱ្យយន្តការនៃការបណ្តុះបណ្តាលដល់សិស្ស-និស្សិតឱ្យមានសមត្ថភាពពេញលេញលើចំណេះដឹង ជំនាញ ព្រមទាំងអភិវឌ្ឍអាកប្បកិរិយាសមស្របជាពលរដ្ឋល្អ ចេះរួមរស់ជាមួយគ្នាដោយសុខដុមរមនា និងមនសិការជាតិ ហើយឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេស តំបន់ និងអន្តរជាតិ។</td></tr>
<tr><td colspan="4">ការគណនា៖ ចំនួននិស្សិតដែលទទួលបានការងារធ្វើ ធៀបជាមួយចំនួននិស្សិតដែលបញ្ចប់ការសិក្សាតាមឆ្នាំនីមួយៗ។</td></tr>
<tr><td colspan="4">ប្រភពទិន្នន័យ៖ របាយការណ៍ស្ទាបស្ទង់ស្តីពីការតាមដាននិស្សិតដែលបានបញ្ចប់ការសិក្សាមានការងារធ្វើ របស់ការិយាល័យធានាគុណភាពផ្ទៃក្នុងនៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ឆ្នាំសិក្សា ២០២២។</td></tr>
<tr><td colspan="4">ថ្ងៃកំណត់នៃទិន្នន័យ៖ ៣១ តុលា ២០២៣</td></tr>
</table>

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ២៩ ធ្នូ ឆ្នាំ២០២៣

| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.៥៖** លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | **អង្គភាពទទួលបន្ទុក៖** សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | **កាលបរិច្ឆេទ៖** ១២ សីហា ២០២២ |
|---|---|---|---|

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលសិស្ស និស្សិតកម្រិតឧត្តមសិក្សា និងជំនាញអប់រំ បច្ចេកទេសវិជ្ជាជីវៈឱ្យទទួលបានចំណេះដឹងសមស្របទៅតាមតម្រូវការសង្គម មានសមត្ថភាពបំពេញការងារដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | **លេខកូដសូចនាករ៖** ☑ ___ PI 2.05.2 (សម្រាប់អនុកម្មវិធី) |
|---|---|

**ឈ្មោះសូចនាករវែង៖** ចំនួនអត្ថបទនៃការសិក្សាស្រាវជ្រាវរបស់បុគ្គលិកអប់រំត្រូវបានបោះពុម្ពប្រចាំឆ្នាំ។

**ឈ្មោះសូចនាករខ្លី៖** ចំនួនអត្ថបទដែលបានបោះពុម្ព។

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ផ្តល់ការជំរុញ លើកទឹកចិត្តដល់បុគ្គលិកអប់រំធ្វើការសិក្សាស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាព និងចងក្រងលទ្ធផលនៃការសិក្សាស្រាវជ្រាវដើម្បីបង្ហាញលទ្ធផលការស្រាវជ្រាវជួយដល់សិស្ស និស្សិត និងសហគមន៍។

**សេចក្តីពណ៌នា៖** ដើម្បីលើកកម្ពស់គុណភាពនៃការស្រាវជ្រាវ សាកលវិទ្យាល័យបានរៀបចំគោលនយោបាយនៃការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ឱកាស និងលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក។ ជាងនេះទៅទៀតសាកលវិទ្យាល័យបានលើកទឹកចិត្តបុគ្គលិកអប់រំ រៀបចំចងក្រង និពន្ធ និងបោះពុម្ពស្នាដៃនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនថែមទៀតផង។

**ការគណនា៖** ចំនួនអត្ថបទស្រាវជ្រាវដែលបានបោះពុម្ព។

**ប្រភពទិន្នន័យ៖** គម្រោងស្រាវជ្រាវរបស់បុគ្គលិកអប់រំ។

**ថ្ងៃកំណត់នៃទិន្នន័យ៖** ២៩ ធ្នូ ឆ្នាំ២០២៣

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ២៩ កុម្ភៈ ឆ្នាំ២០២៤

| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.៦៖** ការអភិវឌ្ឍការបណ្តុះ-បណ្តាល និងស្រាវជ្រាវ | **អង្គភាពទទួលបន្ទុក៖** វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | **កាលបរិច្ឆេទ៖** ១១ សីហា ២០២២ |
|---|---|---|---|

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលលើជំនាញវិស្វកម្ម ផ្តល់ការស្រាវជ្រាវវិទ្យាសាស្ត្រនិងនវានុវត្តជាអាទិភាព និងធានាឱ្យបាននូវការផលិតធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | **លេខកូដសូចនាករ៖** ☑ ___ PI 2.06.1 (សម្រាប់អនុកម្មវិធី) |
|---|---|

**ឈ្មោះសូចនាករវែង៖** ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬបន្តការសិក្សា។

**ឈ្មោះសូចនាករខ្លី៖** ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬបន្តការសិក្សា។

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ដើម្បីធានាភាពមានការងារធ្វើ ឬ ការបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្ររបស់និស្សិតដែលទើបតែបញ្ចប់ការសិក្សាដោយជោគជ័យក្នុងឆ្នាំសិក្សា និងដើម្បីពិនិត្យ និងរៀបចំកែលម្អយុទ្ធសាស្ត្រលើកកម្ពស់គុណភាពអប់រំ និងស្រាវជ្រាវ។

**សេចក្តីពណ៌នា៖** ការបណ្តុះបណ្តាលនិស្សិតឱ្យមានសមត្ថភាពខ្ពស់ប្រកបដោយទេពកោសល្យស្របតាមចក្ខុវិស័យកម្ពុជាមុនឆ្នាំ ២០៣០ ជាអទិភាពចម្បងរបស់វិទ្យាស្ថានដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ភាពមានការងារធ្វើរបស់និស្សិត ការបង្កើនប្រសិទ្ធភាព និងផលិតភាពក្នុងសហគ្រាស។ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ កម្មវិធីសិក្សានីមួយៗរបស់វិទ្យាស្ថានបានពិនិត្យនិងកែលម្អជាប្រចាំជាមួយដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុនសហគ្រាស និងភាគីពាក់ព័ន្ធនានា។ ក្រៅពីនេះ សមត្ថភាពបង្រៀនរបស់សាស្ត្រាចារ្យត្រូវបានលើកកម្ពស់ជាប្រចាំ។ ការអនុវត្តសកម្មភាពស្រាវជ្រាវដែលបានលើកកម្ពស់ក៏បានចូលរួមចំណែកក្នុងការបង្កើនគុណភាពនៃការបណ្តុះបណ្តាលដែរ។ វិទ្យាស្ថានមានកម្មវិធីចុះកម្មសិក្សានៅតាមក្រុមហ៊ុនសហគ្រាស ស្ថានប័នរដ្ឋនិងឯកជននានា ដើម្បីផ្សារភ្ជាប់ការសិក្សាទៅនឹងការអនុវត្តជាក់ស្តែង បង្កើតបណ្តាញទំនាក់ទំនង ផ្តល់ឱកាសឱ្យនិស្សិតបង្ហាញសមត្ថភាពរបស់ខ្លួន ដើម្បីទទួលបានការងារធ្វើភ្លាមៗក្រោយពីបញ្ចប់ការសិក្សា។ ការិយាល័យទំនាក់ទំនងសហគ្រាសរបស់វិទ្យាស្ថានបានរៀបចំពិព័រណ៍ការងារជារៀងរាល់ឆ្នាំដើម្បីជំរុញការទទួលបានការងាររបស់និស្សិត។ ការចូលរួមក្នុងគម្រោងស្រាវជ្រាវរបស់និស្សិតបានលើកកម្ពស់ចំណេះដឹងផ្នែកស្រាវជ្រាវ ការសរសេរនិក្ខេបបទបែបវិទ្យាសាស្ត្រ ការធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ ការសរសេរអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រទាំងក្នុងនិងក្រៅប្រទេស។

**ការគណនា៖** ផលធៀបនៃចំនួននិស្សិតដែលមានការងារធ្វើឬបន្តការសិក្សា និង ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យក្នុងឆ្នាំសិក្សា។

**ប្រភពទិន្នន័យ៖** របាយការណ៍ស្តីពីការសិក្សាស្ថានភាពនិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**ថ្ងៃកំណត់នៃទិន្នន័យ៖** ៣១ តុលា ឆ្នាំ២០២៣

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ២០ ធ្នូ ឆ្នាំ២០២៣

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.៦៖** **ការអភិវឌ្ឍការបណ្តុះ-បណ្តាល និងស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលលើជំនាញវិស្វកម្ម ផ្តល់ការស្រាវជ្រាវវិទ្យាសាស្ត្រនិងនវានុវត្តជាអាទិភាព និងធានាឱ្យបាននូវការផលិតធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

| | |
|---|---|
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | **លេខកូដសូចនាករ៖** ☑ ___ PI 2.06.2 (**សម្រាប់អនុកម្មវិធី**) |

**ឈ្មោះសូចនាករវែង៖** ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ

**ឈ្មោះសូចនាករខ្លី៖** ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ដើម្បីបង្ហាញពីការខំប្រឹងប្រែងរកគម្រោងស្រាវជ្រាវ អនុវត្តគម្រោងស្រាវជ្រាវ និងចងក្រងលទ្ធផលនៃការស្រាវជ្រាវដើម្បីចែករំលែករបកគំហើញស្រាវជ្រាវថ្មីៗទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ

**សេចក្តីពណ៌នា៖** ការអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិ ផ្តើមអាជីវកម្ម និងផ្ទេរបច្ចេកវិទ្យាដើម្បីសុខដុមនីយកម្មនិងការអភិវឌ្ឍមុនឆ្នាំ២០៣០ ជាអទិភាពមួយក្នុងចំណោមអទិភាពធំៗរបស់វិទ្យាស្ថាន។ ក្នុងបរិបទនេះ វិទ្យាស្ថាន បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ដែលជាសេនាធិការឱ្យវិទ្យាស្ថានលើការងារស្រាវជ្រាវ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន បានបង្កើតអង្គភាពស្រាវជ្រាវចំនួន៥អង្គភាព នៅក្រោមចំណុះមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ គឺ (១) បច្ចេកវិទ្យាថាមពលនិងការគ្រប់គ្រង (ETM) (២) បច្ចេកវិទ្យាអាហារនិងអាហារូបត្ថម្ភ (FTN) (៣) មេកាត្រូនិចនិងបច្ចេកវិទ្យាព័ត៌មាន (MIT) (៤) វិទ្យាសាស្ត្ររូបធាតុនិងរចនាសម្ព័ន្ធ (MSS) និង (៥) ធនធានទឹកនិងបរិស្ថាន (WAE)។ ជារៀងរាល់ឆ្នាំ មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍រៀបចំសន្និសីទវិទ្យាសាស្ត្របង្កើតជាវេទិកាចែករំលែករបកគំហើញស្រាវជ្រាថ្មីៗទាំងកម្រិតជាតិ និងអន្តរជាតិ។ លើសពីនេះ មជ្ឈមណ្ឌលក៏បានជំរុញការបោះពុម្ពក្នុងកម្រិតអន្តរជាតិ។

**ការគណនា៖** ចំនួនប្រធានបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ។

**ប្រភពទិន្នន័យ៖** របាយការណ៍ក្រុមប្រឹក្សាភិបាលប្រចាំរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**ថ្ងៃកំណត់នៃទិន្នន័យ៖** ៣០ មិថុនា ឆ្នាំ២០២៣

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ២០ ធ្នូ ឆ្នាំ២០២៣

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.៦៖ ការអភិវឌ្ឍការបណ្តុះ-បណ្តាល និងស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** លើកកម្ពស់ការបណ្តុះបណ្តាលលើជំនាញវិស្វកម្ម ផ្តល់ការស្រាវជ្រាវវិទ្យាសាស្ត្រនិងនវានុវត្តន៍ជាអាទិភាព និងធានាឱ្យបាននូវការផលិតធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

| | |
|---|---|
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | **លេខកូដសូចនាករ៖** ☑ ___ PI 2.06.3 (**សម្រាប់អនុកម្មវិធី**) |

**ឈ្មោះសូចនាករវែង៖** ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត

**ឈ្មោះសូចនាករខ្លី៖** ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** ដើម្បីធានាចំនួនបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិតស្របតាមផែនការដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាលលើជំនាញវិស្វកម្មទាំងកម្រិតវិស្វករនិងថ្នាក់ក្រោយបរិញ្ញាបត្រឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា និងដើម្បីធានាគុណភាពនៃការស្រាវជ្រាវដោយផ្សារភ្ជាប់ជាមួយការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា។

**សេចក្តីពណ៌នា៖** ការកសាងធនធានមនុស្សជាផ្នែកមួយនៃយុទ្ធសាស្ត្រទី២ក្នុងផែនការយុទ្ធសាស្ត្រ២០២១-២០៣០ របស់វិទ្យាស្ថាន។ ការកសាងធនធានមនុស្សថ្នាក់បណ្ឌិតឱ្យស្របតាមផែនការគឺមានភាពចាំបាច់ណាស់សម្រាប់អភិវឌ្ឍវិទ្យាស្ថានទាំងផ្នែកកម្មវិធីបណ្តុះបណ្តាល ផ្នែកស្រាវជ្រាវ និងផ្នែកអភិបាលកិច្ច។ ការបង្កើនធនធានមនុស្សថ្នាក់បណ្ឌិតរបស់វិទ្យាស្ថានតាមរូបភាព៣យ៉ាង គឺ (១) ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតក្នុងវិទ្យាស្ថានផ្ទាល់ (២)បញ្ជូនបុគ្គលិកទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅបណ្តាសាកល

| |
|---|
| វិទ្យាល័យដៃគូ និង (៣)បញ្ជូនបុគ្គលិកទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅបណ្តាសាកលវិទ្យាល័យអន្តរជាតិផ្សេងៗទៀត។ |
| **ការគណនា៖** ផលធៀបនៃចំនួនបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត និងចំនួនសរុបនៃបុគ្គលិកសិក្សាពេញម៉ោង។ |
| **ប្រភពទិន្នន័យ៖** របាយការណ៍ក្រុមប្រឹក្សាភិបាលប្រចាំរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ៣០ មិថុនា ឆ្នាំ២០២៣ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** ២០ ធ្នូ ឆ្នាំ២០២៣ |

| | | | |
|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | **អនុកម្មវិធី២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ វិទ្យាស្ថានជាតិអប់រំ** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ។ អនុក្រឹត្យ ០៤ អនក្រ.បក-១៣.០៣.២០០៤ | | | |
| **ប្រភេទសូចនាករ៖** ☑ **សូចនាករលទ្ធផលក្នុងឆ្នាំ** | | **លេខកូដសូចនាករ៖** ☑ ___ PI 2.07.1 **(សម្រាប់អនុកម្មវិធី)** | |
| **ឈ្មោះសូចនាករវែង៖** ចំនួនគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១) និងគរុសិស្សកម្រិតមូលដ្ឋាន(១២+៤)បានទទួលការបណ្តុះ-បណ្តាលប្រចាំឆ្នាំ | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនគរុនិស្សិតកម្រិតឧត្តម និងគរុសិស្សកម្រិតមូលដ្ឋានបានទទួលការបណ្តុះបណ្តាល | | | |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** បង្ហាញពីធនធានមនុស្សទទួលបានការបណ្តុះបណ្តាលដែលឆ្លើយតបទៅនឹងកម្មវិធីទី២ ស្តីពីការអភិវឌ្ឍឧត្តមសិក្សា និងអនុកម្មវិធី២.៧ ស្តីពីការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការណ្តុះបណ្តាល។ | | | |
| **សេចក្តីពណ៌នា៖** ធនធានមនុស្សដែលជាគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញាបត្រ+១ បានទទួលការបណ្តុះបណ្តាលនឹងចេញទៅបម្រើការនៅតាមវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សានានាទូទាំងប្រទេស។ គរុសិស្ស១២+៤ មានឯកទេសទី១ភាសាបារាំង និងឯកទេសទី២អាចជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ឬជីវវិទ្យា ដែលត្រូវបញ្ចប់ការសិក្សានឹងត្រូវទៅបម្រើការនៅតាមសាលាមធ្យមសិក្សាបឋមភូមិ។ ការវិនិយោគលើធនធានគ្រូបង្រៀន អាចធានាបាននូវការអប់រំប្រកបដោយគុណភាព និងបរិយាបន្នដែលបានចែងនៅក្នុងគោលនយោបាយអប់រំ។ | | | |
| **ការគណនា៖** - រាប់ចំនួនគរុសិស្សតាមឆ្នាំនីមួយៗដែលបានចុះឈ្មោះចូលរៀន ហើយបូកបញ្ចូលគ្នារយៈពេល៤ឆ្នាំ<br>- រាប់ចំនួនគរុនិស្សិតជាក់ស្តែងដែលបានចុះឈ្មោះចូលរៀនក្នុង១ឆ្នាំ | | | |
| **ប្រភពទិន្នន័យ៖** ចំនួនជ្រើសរើស គឺតាមគោលការណ៍កំណត់របស់ក្រសួង | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀននៅដើមវគ្គសិក្សានីមួយៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣ | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** នៅដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣ | | | |

| ក្រសួង៖ អប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.៧៖** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | **អង្គភាពទទួលបន្ទុក៖** វិទ្យាស្ថានជាតិអប់រំ | **កាលបរិច្ឆេទ៖** ១១ សីហា ២០២២ |
|---|---|---|---|

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ។ អនុក្រឹត្យ ០៤ អនក្រ.បក-១៣.០៣.២០០៤

| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | **លេខកូដសូចនាករ៖** ☑ ___ PI 2.07.2 (សម្រាប់អនុកម្មវិធី) |
|---|---|

**ឈ្មោះសូចនាករវែង៖** ចំនួននិស្សិតថ្នាក់បណ្ឌិតបានទទួលការបណ្តុះបណ្តាលតាមឆ្នាំនីមួយៗ (និស្សិតត្រូវរៀនយ៉ាងតិចចំនួន៣ឆ្នាំ ដើម្បីបញ្ចប់ថ្នាក់បណ្ឌិត)

**ឈ្មោះសូចនាករខ្លី៖** ចំនួននិស្សិតថ្នាក់បណ្ឌិតបានទទួលការបណ្តុះបណ្តាល

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** បង្ហាញពីធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល ដែលឆ្លើយតបទៅនឹងអនុកម្មវិធី២.៧ ស្តីពីការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការណ្តុះបណ្តាល និងស្រាវជ្រាវ។

**សេចក្តីពណ៌នា៖** និស្សិតថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំជាធនធានដ៏សំខាន់ក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។ និស្សិតថ្នាក់បណ្ឌិតត្រូវបានជ្រើសដោយយកចិត្តទុកដាក់បំផុតចេញពីមន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ដែលកំពុងបម្រើការនៅតាមស្ថាប័ន និងគ្រឹះស្ថានអប់រំនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ និស្សិតថ្នាក់បណ្ឌិតដែលត្រូវបញ្ចប់ការសិក្សានឹងទទួលបាននូវចំណេះដឹងបន្ថែមទៀតទាក់ទងទៅនឹងការគ្រប់គ្រងអប់រំ ការរៀបចំគោលនយោបាយអប់រំ ដែលអាចជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការធ្វើកំណែទម្រង់។ សកម្មភាពនៅក្នុងផ្នែកនេះឆ្លើយតបទៅនឹងគោលនយោបាយទី២ របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ការគណនា៖** រាប់ចំនួននិស្សិតជាក់ស្តែងដែលបានចុះឈ្មោះក្នុងវគ្គបណ្តុះបណ្តាលនីមួយៗ ហើយបូកបញ្ចូលគ្នា

**ប្រភពទិន្នន័យ៖** ចំនួនជ្រើសរើស គឺតាមគោលការណ៍កំណត់របស់ក្រសួង

**ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀននៅដើមវគ្គសិក្សានីមួយៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** នៅដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣

| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.៧៖** ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | **អង្គភាពទទួលបន្ទុក៖** វិទ្យាស្ថានជាតិអប់រំ | **កាលបរិច្ឆេទ៖** ១១ សីហា ២០២២ |
|---|---|---|---|

**គោលបំណងកម្មវិធី/អនុកម្មវិធី៖** បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ។ អនុក្រឹត្យ ០៤ អនក្រ.បក-១៣.០៣.២០០៤

| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | **លេខកូដសូចនាករ៖** ☑ ___ PI 2.07.3 (សម្រាប់អនុកម្មវិធី) |
|---|---|

**ឈ្មោះសូចនាករវែង៖** ៖ចំនួននិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិធីសាស្ត្របង្រៀនភាសាបារាំង គ្រប់គ្រងអប់រំ ប្រឹក្សាគរុកោសល្យ វិជ្ជាជីវៈនាយកសាលា អធិការអប់រំ និងគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) បានទទួលការបណ្តុះបណ្តាល

**ឈ្មោះសូចនាករខ្លី៖** ចំនួននិស្សិតបានទទួលការបណ្តុះបណ្តាល

**គោលបំណង/សារៈសំខាន់នៃសូចនាករ៖** បង្ហាញពីធនធានមនុស្សដែលទទួលបានការបំប៉នតាមវគ្គនីមួយៗ ហើយធនធានមនុស្សទាំងនេះនឹងចេញទៅបម្រើការនៅតាមអង្គភាពរបស់ខ្លួនវិញ។ វគ្គសិក្សាទាំងអស់ឆ្លើយតបទៅនឹងនុកម្មវិធី២.៧ ស្តីពីការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការណ្តុះបណ្តាលនិងស្រាវជ្រាវ។

**សេចក្តីពណ៌នា៖** ការបណ្តុះបណ្តាលនៅក្នុងផ្នែកនេះ គឺជាការបង្កើននូវកម្រិតគុណវុឌ្ឍិ និងសញ្ញាបត្ររបស់មន្ត្រីអប់រំគ្រប់ប្រភេទ។ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិធីសាស្ត្របង្រៀនភាសាបារាំងបានជ្រើសរើសចេញពីគ្រូបង្រៀនភាសាបារាំងដែលកំពុងបម្រើការនៅតាមគ្រឹះស្ថានអប់រំនានាទូទាំងប្រទេស។ និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំត្រូវបានជ្រើសរើសចេញពីមន្ត្រីអប់រំដែលកំពុងបម្រើការនៅតាមគ្រឹះស្ថានអប់រំ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និស្សិតដែលត្រូវបញ្ចប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នឹងចូលរួមអភិវឌ្ឍការងារគ្រប់គ្រងអប់រំនៅតាមគ្រឹះស្ថាននានាដែលពួកគាត់កំពុងបម្រើការងារ។ និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគរុកោសល្យត្រូវបានជ្រើសចេញពីគ្រូបង្រៀននៅតាមសាលានានាដើម្បីយកមកបណ្តុះបណ្តាលបន្ថែមលើជំនាញប្រឹក្សាគរុកោសល្យ និស្សិតដែលត្រូវបញ្ចប់ការបណ្តុះបណ្តាលនឹងមានជំនាញគ្រប់គ្រាន់លើការងារប្រឹក្សាគរុកោសល្យ ហើយទៅបម្រើការនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសាលារៀននានានៅទូទាំងប្រទេស។ និស្សិតវិជ្ជាជីវៈនាយកសាលាត្រូវបានជ្រើសរើសពីគ្រូបង្រៀននៅតាមសាលានានាដើម្បីបណ្តុះបណ្តាលលើជំនាញគ្រប់គ្រងសាលារៀន និស្សិតដែលនឹងបញ្ចប់ការបណ្តុះបណ្តាលជាធនធានមនុស្សក្នុងការតែងតាំងជានាយកវិទ្យាល័យនាពេលអនាគត។ និស្សិតអធិការអប់រំត្រូវបានជ្រើសរើសចេញពីមន្ត្រីអប់រំគ្រប់ប្រភេទដែលមានក្របខណ្ឌខ្ពស់ និងអតីតភាពការងារលើវិស័យអប់រំយូរឆ្នាំ និស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលនឹងត្រូវប្តូរក្របខណ្ឌ ពីក្របខណ្ឌដើមទៅជាក្របខណ្ឌអធិការអប់រំ ហើយត្រូវទៅបម្រើការនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឬនៅនាយកដ្ឋានធានាគុណភាពអប់រំ។ គ្រូបង្រៀនកម្រិតឧត្តមបរិញ្ញា+២ ជាកម្មវិធីបណ្តុះបណ្តាលថ្មីដែលគុណវុឌ្ឍិដល់និស្សិតដែលនឹងបញ្ចប់ការបណ្តុះបណ្តាល ដើម្បីក្លាយជាគ្រូបង្រៀនកម្រិតឧត្តម ហើយមានកម្រិតសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងផ្នែកនេះ នឹងចូលរួមចំណែកយ៉ាងខ្លាំងដល់កំណែទម្រង់វិស័យអប់រំគ្រប់ជ្រុងជ្រោយទាំងគុណភាព និងប្រសិទ្ធភាព។

**ការគណនា៖** រាប់ចំនួននិស្សិតជាក់ស្តែងក្នុងវគ្គបណ្តុះបណ្តាលនីមួយៗប្រចាំឆ្នាំ ហើយបូកបញ្ចូលគ្នាតាមវគ្គនីមួយៗ

**ប្រភពទិន្នន័យ៖** ចំនួនជ្រើសរើស គឺតាមគោលការណ៍កំណត់របស់ក្រសួង

**ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀននៅដើមវគ្គសិក្សានីមួយៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖** នៅដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣

| ក្រសួងអប់រំ យុវជន និងកីឡា | **អនុកម្មវិធី២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ** | **អង្គភាពទទួលបន្ទុក៖ វិទ្យាស្ថានជាតិអប់រំ** | **កាលបរិច្ឆេទ៖ ១១ សីហា ២០២២** |
|---|---|---|---|
| **គោលបំណងកម្មវិធី/អនុកម្មវិធី៖** បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ។ អនុក្រឹត្យ ០៤ អនក្រ.បក-១៣.០៣.២០០៤ | | | |
| **ប្រភេទសូចនាករ៖** ☑ សូចនាករលទ្ធផលក្នុងឆ្នាំ | | **លេខកូដសូចនាករ៖** ☑ ___ PI 2.07.4 (សម្រាប់អនុកម្មវិធី) | |
| **ឈ្មោះសូចនាករវែង៖** ចំនួនមន្ត្រីគ្រប់គ្រងផែនការថ្នាក់រាជធានីខេត្ត អធិការអប់រំថ្នាក់រាជធានីខេត្ត នាយកវិទ្យាល័យ ប្រធានក្រុមបច្ចេកទេស និងគ្រូបបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ទទួលបានការបំប៉ន ដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ពួកគាត់ | | | |

| |
|---|
| **ឈ្មោះសូចនាករខ្លី៖** ចំនួនមន្ត្រីអប់រំ និងគ្រូបង្រៀនបានទទួលការបំប៉ន |
| **គោលបំណង/សារៈសំខាន់នៃសូចនាករ៖** បង្ហាញពីធនធានមនុស្សដែលទទួលបានការបំប៉ន ការវាយតម្លៃពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ការកែលម្អកម្មវិធីបណ្តុះបណ្តាលដើម្បីឱ្យទាន់ការវិវត្តន៍ថ្មីៗ និងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា។ |
| **សេចក្តីពណ៌នា៖** ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំជាការងារអាទិភាពមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ វិទ្យាស្ថានជាតិអប់រំបានចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំគ្រប់ប្រភេទ។ ការបំប៉នមន្ត្រីគ្រប់គ្រងផែនការថ្នាក់រាជធានី ខេត្ត នឹងជួយអភិវឌ្ឍសមត្ថភាពរបស់គាត់ក្នុងការរៀបចំផែនការអប់រំ និងការរៀបចំផែនការតម្រូវគ្រូបង្រៀនជាដើម។ អធិការអប់រំដែលកំពុងបម្រើការងារនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងនាយកដ្ឋានធានាគុណភាពអប់រំ ត្រូវទទួលការបំប៉នបន្ថែមទៅជំនាញថ្មីៗដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃការអប់រំ ដើម្បីអាចវាយតម្លៃការអប់រំនៅតាមសាលារៀន និងជួយអភិវឌ្ឍការអប់រំគ្រប់កម្រិតថ្នាក់។ ការបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិគឺធានាបាននូវគុណភាពក្នុងការបណ្តុះបណ្តាលបន្តគ្រប់ប្រភេទ។ វគ្គបំប៉ននាយកវិទ្យាល័យគឺជួយនាយកសាលាឱ្យអនុវត្តនូវការគ្រប់គ្រងតាមសាលារៀន និងជំរុញលោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់នៅក្នុងសាលាដើម្បីឱ្យពួកគាត់អាចអនុវត្តការងារបានល្អ។ ការបំប៉នប្រធានក្រុមបច្ចេកទេស និងគ្រូមុខវិជ្ជាវិទ្យាសាស្ត្រនឹងផ្តល់នូវចំណេះដឹងថ្មីៗផ្នែកវិធីសាស្ត្របង្រៀន និងការបង្រៀនពិសោធន៍វិទ្យាសាស្ត្រ។ ការបណ្តុះបណ្តាលបន្តនៅក្នុងផ្នែកនេះគឺជាយន្តការមួយដែលវិទ្យាស្ថានជាតិអប់រំចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងការអនុវត្តការងាររបស់មន្ត្រីអប់រំនៅថ្នាក់ក្រោមជាតិ។ |
| **ការគណនា៖** រាប់ចំនួនសិក្ខាកាមជាក់ស្តែងដែលបានចូលរួមក្នុងវគ្គបំប៉ននីមួយៗ |
| **ប្រភពទិន្នន័យ៖** វិទ្យាស្ថានជាតិអប់រំ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀននៅដើមវគ្គសិក្សានីមួយៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** នៅដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣ |

<table>
<tr><td>ក្រសួងអប់រំ យុវជន និងកីឡា</td><td><u>អនុកម្មវិធី២.៧៖</u><br>ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ</td><td>អង្គភាពទទួលបន្ទុក៖ វិទ្យាស្ថានជាតិអប់រំ</td><td>កាលបរិច្ឆេទ៖ ១១ សីហា ២០២២</td></tr>
<tr><td colspan="4">គោលបំណងកម្មវិធី/អនុកម្មវិធី៖ បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ។ អនុក្រឹត្យ ០៤ អនក្រ.បក-១៣.០៣.២០០៤</td></tr>
<tr><td colspan="2">ប្រភេទសូចនាករ៖<br>☑ សូចនាករលទ្ធផលក្នុងឆ្នាំ</td><td colspan="2">លេខកូដសូចនាករ៖<br>☑ ___ PI 2.07.5 (សម្រាប់អនុកម្មវិធី)</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករវែង៖ ចំនួនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានទទួលការបំប៉នសមត្ថភាពក្នុងនិងក្រៅប្រទេសចុះធ្វើការស្រាវជ្រាវ ពិនិត្យតាមដានវាយតម្លៃលើការអនុវត្តការងាររបស់អតីតគរុនិស្សិត គ្រូបង្រៀនពិសោធវិទ្យាសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាល</td></tr>
<tr><td colspan="4">ឈ្មោះសូចនាករខ្លី៖ ចំនួនបុគ្គលិកទទួលបានការបំប៉នសមត្ថភាព ចុះធ្វើការស្រាវជ្រាវ និងតាមដាន</td></tr>
<tr><td colspan="4">គោលបំណង/សារៈសំខាន់នៃសូចនាករ៖ បង្ហាញពីការយកចិត្តទុកដាក់របស់វិទ្យាស្ថានជាតិអប់រំលើការពង្រឹងសមត្ថភាពបុគ្គលិក និងការស្រាវជ្រាវប្រតិបត្តិ។ សកម្មភាពទាំងនេះទាក់ទាងទៅនឹងអនុកម្មវិធី២.៧ ដែលទាក់ទងទៅនឹងការបណ្តុះបណ្តាល និងការស្រាវជ្រាវ។</td></tr>
</table>

| |
|---|
| **សេចក្តីពណ៌នា៖** ការងារស្រាវជ្រាវ និងចុះពិនិត្យតាមដានវង្វាយតម្លៃជាការងារជាអាទិភាពដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងជំរុញឱ្យមានការអនុវត្ត។ ការស្រាវជ្រាវរបស់បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងទទួលបាននូវលទ្ធផលដែលក្រសួងអប់រំ យុវជន និងកីឡា យកទៅដើម្បីធ្វើជាឯកសារយោង ឬអំណះអំណាងក្នុងការរៀបចំគោលនយោបាយ និងការកែលម្អវិស័យអប់រំ។ ការតាមដានការអនុវត្តការងាររបស់គ្រូបង្រៀន ដែលជាអតីតគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំគឺជាកម្មវិធីដែលចុះជួយអភិវឌ្ឍបន្ថែមដល់ការអភិវឌ្ឍសមត្ថភាពរបស់ពួកគាត់ ហើយម្យ៉ាងវិញទៀតការចុះតាមដាននេះនឹងទទួលបាននូវព័ត៌មានល្អៗដើម្បីយកមកធ្វើជាទុនសម្រាប់កែលម្អកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំឱ្យកាន់តែឆ្លើយតបនឹងតម្រូវការថ្មីៗរបស់សាលាចំណេះទូទៅផងដែរ។ |
| **ការគណនា៖** រាប់ចំនួនបុគ្គលិកវ.ជ.អ ជាក់ស្តែងដែលបានទទួលការបំប៉នតាមផ្នែកនីមួយៗ |
| **ប្រភពទិន្នន័យ៖** វិទ្យាស្ថានជាតិអប់រំ |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** ចំនួននិស្សិតដែលបានចុះឈ្មោះចូលរៀននៅដើមវគ្គសិក្សានីមួយៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣ |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** នៅដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២៣ |

<table>
<tr><td>ក្រសួងអប់រំ យុវជន និងកីឡា</td><td><u>អនុកម្មវិធី២.៨៖</u><br>ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ</td><td>អង្គភាពទទួលបន្ទុក៖ សាកលវិទ្យាល័យស្វាយរៀង</td><td>កាលបរិច្ឆេទ៖ ១១ សីហា ២០២២</td></tr>
<tr><td colspan="4">គោលបំណងកម្មវិធី/អនុកម្មវិធី៖ ផលិតនិស្សិតស្របតាមតម្រូវទីផ្សារការងារ និងការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ</td></tr>
<tr><td colspan="2">ប្រភេទសូចនាករ៖<br>☑ សូចនាករលទ្ធផលក្នុងឆ្នាំ</td><td colspan="2">លេខកូដសូចនាករ៖<br>☑ ___ PI 2.08.1 (សម្រាប់អនុកម្មវិធី)</td></tr>
